01253182



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2016, 15:06
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ:-កោសល្លុប

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី៣៦០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម យ៉ា សុខន

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក សេង លាង

កញ្ញា សុង ឆវិន្ទ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោកស្រី អ៊ីសាប៊ែល ឌុយរ៉ង់ដ៍ *(Ms. Isabelle DURAND)*

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

សាធារណៈ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា សុង ឆរ័ន្ត | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ប្រាក់ យុត (2-TCW-938) | ខ្មែរ |
| លោក ឡាច គ្រី (2-TCCP-844) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ច្រាក់ យុត** (2-TCW-938)

សួរដោយលោកលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ............ ទំព័រ ៣

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ឡាច គ្រី** (2-TCCP-844)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ............ ទំព័រ ៤១

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ............ ទំព័រ ៤៣

សួរដោយកញ្ញា សុង ឆវ័ន្ត ផ្ដើមពី ............ ទំព័រ ៥៩

សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី............ ទំព័រ ៦៦

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី............ ទំព័រ ៧២

សួរដោយលោក លីវ សុវណ្ណា ផ្ដើមពី............ ទំព័រ ៧៣

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី............ ទំព័រ ៧៦

សាធារណៈ

# កិច្ចដំណើរការនីតិវិធី

[០៩:០៦:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ នៅពេលព្រឹក អង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ប្រាក់ យុត ដោយសវនាការអសាធារណៈ ហើយនិងនៅរសៀល អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់ជាសាធារណៈ ស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-844 ពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍។ ហើយអង្គជំនុំជម្រះក៏មានបម្រុងទុកនូវដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-869 ម្នាក់ដែរនៅពេលរសៀលនេះ។ សូមភាគីជ្រាប។ ក្រឡាបញ្ជីសវនាការលោកកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្តនៅថ្ងៃនេះ គឺលោកស្រី ប្រាក់ យុត។ លោកស្រី និងមេធាវីប្រឹក្សាមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការសវនាការនេះ។ ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកផ្ដល់សក្ខីកម្មនៅរសៀលនេះមានរហស្សនាម 2-TCCP-844 តាមរយៈប្រព័ន្ធសោតទស្សន៍។ តាមការបញ្ជាក់ពីផ្នែកបច្ចេកទេសសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេសសម្រាប់ការផ្ដល់សក្ខីកម្មនៅរសៀលនេះបានរៀបចំរួចរាល់ហើយ។ រីឯដើមបណ្ដឹងរដ្ឋប្បវេណីក៏បានត្រៀមរួចជាស្រេចសម្រាប់ការផ្ដល់សក្ខីកម្មនៅរសៀលនេះផងដែរ។ សូមអរគុណលោកប្រធាន។

[០៩:០៨:០៧]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់លោក នួន ជា ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថាដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះជាប្រចាំ មិនអាចអង្គុយយូរបាន និងផ្តល់អនុសាសសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៩:០៧]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ ជាដំបូងនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរសហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំឈ្មោះ វ៉ិចទ័រ កូប៉េ ជាមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។ ខ្ញុំនឹងសួរសំណួរលោកស្រីមួយចំនួន នៅព្រឹកនេះ។ ខ្ញុំសូមចាប់ផ្តើមពិភាក្សាជាមួយលោកស្រីនូវអ្វីដែលលោកស្រីបានឆ្លើយកាលពីព្រឹកម្សិលមិញ គឺនៅម៉ោង០៩:៣០នាទីព្រឹក។ សហព្រះរាជអាជ្ញាបានសួរទៅលោកស្រីនូវសំណួរទាក់ទងនឹងការប្រព្រឹត្តមកលើជនជាតិចាម។ លោកស្រីបានឆ្លើយថា ខ្ញុំសូមដកស្រង់ចេញពីប្រតិចារឹក៖ "ចំពោះជនជាតិចាមទាំងអស់នៅក្នុងស្រុកកំពង់សៀម ទោះបីជាមានបញ្ជាពីថ្នាក់លើ ហើយនិងសេចក្តីសម្រេចរបស់ខ្ញុំ គឺថាខ្ញុំត្រូវតែញែកឱ្យដាច់ពីគ្នា អ្នកណាល្អ អ្នកណាមិនល្អ អ្នកណាប្រឆាំង អ្នកណាយល់ស្រប។ ដូច្នេះមុននឹងការ -- មុននឹងធ្វើការចាប់ខ្លួន ខ្ញុំត្រូវតែធ្វើយ៉ាងម៉េចបញ្ជាក់ឱ្យច្បាស់ថា មានតែសមាសភាពមិនល្អទេដែលត្រូវចាប់ខ្លួន មិនមែនជនជាតិចាម ចាប់ខ្លួនជនជាតិចាមទាំងអស់នោះទេ។" ហើយពីមុននឹងសំណួរនេះ លោកស្រីក៏បានឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា៖ "ខ្ញុំបានរាយការណ៍ថា មានជនជាតិចាមខ្លះត្រូវតែកម្ទេចចោល ហើយចាមខ្លះគឺជាសមាសភាពល្អ ត្រូវតែទុក។ អ្នកខ្លះក៏ត្រូវបានសម្លាប់ចោល អ្នកខ្លះក៏ត្រូវបានចាប់ខ្លួន។ ប៉ុន្តែមិនមានន័យចាមទាំងអស់ត្រូវតែសម្លាប់ចោលនោះទេ គឺថាយើងរែកញែក រែកមុខរកតែសមាសភាពមិនល្អ។" នេះគឺជាសម្រង់ចេញពីចម្លើយរបស់លោកស្រី កាលពីព្រឹកម្សិលមិញ។ តើប្រតិចារឹកនេះ វាត្រឹមត្រូវដូចអ្វីដែលលោកស្រីបានឆ្លើយកាលពីព្រឹកម្សិលមិញទេ?

[០៩:១២:៣៧]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសុំមានចម្លើយ។ គឺខ្ញុំបានឆ្លើយពីម្សិលមិញ ខ្ញុំសុំជម្រាបលោកថា ត្រឹមត្រូវ។

**ស៖** សូមអរគុណលោកស្រីសាក្សី។ ខ្ញុំសូមផ្តោតតែមួយផ្នែកនៃសក្ខីកម្មកាលពីម្សិលមិញ គឺសមាសភាពល្អ និងសមាសភាពមិនល្អ។ សូមលោកស្រីពន្យល់ឱ្យបានទូលំទូលាយបន្តិច ដើម្បីឱ្យយើងខ្ញុំបានយល់ បានច្បាស់រវាងសមាសភាពល្អ និងសមាសភាពមិនល្អ។ សូមពន្យល់ឱ្យបានទូលំទូលាយបន្តិចមក។

**ឆ៖** ខ្ញុំសូមជម្រាប។ បញ្ហាចាម សមាសភាពល្អ មិនល្អ ខ្ញុំសូមជម្រាបថា ក្នុងហ្នឹងវាមានអ្នកល្អគឺមិនមានអីធ្វើឱ្យការលំបាកនៅក្នុងភូមិឃុំ មិនមានប្រឆាំង មិនមានទំនាស់នៅក្នុងភូមិឃុំទេ។ តែមួយ

ដោយឡែកទៀត អ្នកមិនល្អដែលធ្វើឲ្យលំបាកចំពោះប្រជាជនចាមនៅក្នុងភូមិឃុំនេះ ដូចជាមួយគឺគាត់មានការប្រឆាំង តវ៉ា គាត់ជាមួយមេភូមិ មេឃុំអីអ៊ីចឹងទៅ។ ទី១ ក៏គាត់មិនពេញចិត្តចំពោះជាមួយខាងជាមួយអង្គការអីអ៊ីចឹងទៅ ឬជាមួយប្រធានឃុំ ប្រធានភូមិឮ ហ្នឹងគឺគាត់ ហ្នឹងវាបើគិតទៅមិនមែនថាទំនាស់ស្លាប់រស់ទេ ប៉ុន្តែគ្រាន់ថា គាត់ទុកជាអ្នកមិនត្រឹមត្រូវនៅក្នុងភូមិដែរ ព្រោះគាត់មានការប្រឆាំងនៅក្នុងភូមិ ឃុំ។ អ៊ីចឹងយើងទុកជាកម្រិតមួយថា វាពិបាកនៅក្នុងភូមិឃុំដែរ បើកាលណាគាត់ទំនាស់ច្រើន។ ប៉ុន្តែទាំងអស់នេះ មិនមែនថាគាត់ទំនាស់ហើយ យើងចាប់យើងចងគាត់ទេ គ្រាន់ថាយើងពិនិត្យទៅ វាលំបាក។ ការដោះស្រាយនៅក្នុងភូមិឃុំ វាអាចទំនាស់ក្នុងប្រជាជន វាដូចថាប្រជាជនយើង វានៅរួមអ៊ីចឹង ឬក៏ចូលគ្នាអ៊ីចឹង។ អានេះ ខ្ញុំសូមជម្រាបប៉ុណ្ណឹង។

[០៩:១៥:៤៦]

**ស៖** សូមអរគុណលោកស្រីសាក្សី។ [redacted]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

[redacted]

[redacted]

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** [redacted]

[០៩:១៩:០៣]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** [redacted]

**ស៖** តើមានភាពខុសគ្នាដែរទេ ក្នុងការប្រើពាក្យ ទី១គឺ "ជំទាស់នឹងបដិវត្តន៍" និងពាក្យមួយទៀត "ផ្តួលរំលំបដិវត្តន៍" តើពាក្យទាំងពីរនេះ វាមានន័យខុសគ្នា ឬក៏ដូចគ្នា?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ពាក្យទាំងពីរនេះ មួយចង់រំលំ មួយចង់ -- មួយទំនាស់។ ទំនាស់ យើងដោះស្រាយបាន តែរំលំ ដែលថាចង់រំលំបដិវត្តន៍ កុំឲ្យមានរបបហ្នឹងទៀតអីចឹង អាហ្នឹងឧបមា។ តែបើពាក្យ "ទំនាស់" គឺទំនាស់ដោះស្រាយបាន។ ពាក្យ "រំលំ" គឺដោះ -- ដូចៗចង់ធ្វើអីមួយ គឺចង់ឲ្យថាឧទាហរណ៍ខ្ញុំលើកថា នៅក្នុងភូមិហ្នឹង គាត់ចង់កម្ទេច អ៎! គាត់ចង់រំលំសហករណ៍អីចឹងទៅ ខ្ញុំលើកឧទាហរណ៍អីចឹងទៅ។ សហករណ៍ហ្នឹង នៅក្នុងភូមិហ្នឹងគាត់មិនចង់ឲ្យ ចង់ធ្វើស៊ីបាយរួមបាយអីអីចឹងណ៎ា ដូចថា តាមចិត្តគាត់អីចឹង ប៉ុនការពិត អា "រំលំ"ហ្នឹង វាពាក្យធ្ងន់ តែបើនិយាយពីពាក្យ "ទំនាស់" គឺយើងដោះស្រាយបាន យើងអប់រំបាន។ នេះ ខ្ញុំសូមអស់មតិ។

[០៩:២២:១០]

**ស៖** ឥឡូវនេះ លោកស្រីកំពុងតែនិយាយអំពីការដួលរំលំបដិវត្តន៍ ពាក់ព័ន្ធទៅនឹងសហករណ៍

នៅថ្នាក់ភូមិ ឬថ្នាក់ឃុំ។ ពាក្យថា "ផ្តួលរំលំបដិវត្តន៍" ក៏វាទាក់ទងទៅនឹងការទម្លាក់បក្សកុម្មុយនីស្ត កម្ពុជា ឬទម្លាក់គណៈមជ្ឈិម ឬផ្តួលរំលំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ តើៗវាពាក់ព័ន្ធទៅដល់ ចំណុចដែលខ្ញុំលើកឡើងនេះដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

មេធាវីការពារក្តីកំពុងតែសួរនាំមុខសាក្សី។ ទី១ គាត់បង្ហាញពាក្យពេចន៍ទាំងនេះហើយ ទើបសួរ ក្រោយ។ យ៉ាងហោចណាស់ ក៏គាត់ត្រូវតែយកចម្លើយរបស់សាក្សីចេញពីកំណត់ហេតុណាមួយ ដើម្បី យកមកសួរសាក្សីដែរ ជាពិសេស ពាក់ព័ន្ធទៅនឹងជនជាតិចាម។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនបានសួរនាំមុខទេ ខ្ញុំគ្រាន់តែចង់រកឱ្យឃើញថា វាមានកម្រិតខុសគ្នានៅក្នុងឃុំ ថ្នាក់ស្រុកអី ដែរទេ ហើយវាពាក់ព័ន្ធទៅដល់នឹងការទម្លាក់រដ្ឋាភិបាល ផ្តួលរំលំបដិវត្តន៍ដែរឬក៏អត់។ ខ្ញុំមិនបានសួរនាំ មុខសាក្សីទេ ខ្ញុំគ្រាន់តែសុំសួរឱ្យគាត់បញ្ជាក់ឱ្យបានច្បាស់លាស់ទៅនឹងចំណុចនេះតែប៉ុណ្ណោះ។

[០៩:២៤:០៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ឥឡូវនេះ សាក្សីប្រហែលជាភ្លេចសំណួរហើយ សូមរៀបចំសំណួរឱ្យបានសមស្របឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី ការទម្លាក់រដ្ឋាភិបាល ការបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បដិវត្តន៍ តើ ចំណុចដែលលោកស្រីលើកឡើងនេះ មានកើតឡើងនៅរដ្ឋាភិបាលថ្នាក់កណ្តាល ឬក៏កើតឡើងទៅដល់ គណៈមជ្ឈិម រដ្ឋាភិបាលនៅភ្នំពេញដែរទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ការខ្ញុំលើកឡើងនេះ គឺអត់មានកើតទៅដល់ថ្នាក់មជ្ឈិម ថ្នាក់កណ្តាល គឺអត់មានទេ។ គឺ មានតែនៅក្នុងភូមិឃុំទេ បើចំពោះនៅជាមួយខាងលើ គឺអត់មាន។ អត់មានដល់កម្រិតដល់ខាងលើទេ។ នេះសូមជម្រាបខ្លីប៉ុណ្ណឹង។

**ស៖** លោកស្រីសាក្សី ខ្ញុំនឹងចូលមកចំណុចដែលលោកស្រីលើកឡើងនេះ នៅពេលក្រោយ។ ឥឡូវខ្ញុំសូមបន្តទៅនិយាយអំពីស្រុកកំពង់សៀម និងការចាប់ខ្លួនជនជាតិចាម។ លោកស្រីនៅនឹកឃើញថា មានប្រជាជនចាមប៉ុន្មាននាក់ដែលត្រូវបានចាប់ខ្លួន ក្រោយពេលលោកស្រីបានទៅដល់ទីនោះ? ខ្ញុំដឹងថា លោកស្រីមិនចាំចំនួនពិតប្រាកដទេ ប៉ុន្តែតើលោកស្រីអាចផ្តល់តួលេខត្រួសៗបានទេ?

[០៩:២៦:៣១]

**ឆ៖** ខ្ញុំសូមបញ្ជាក់ ការចាប់ចាមនៅស្រុកកំពង់សៀម។ ទី១ ខ្ញុំសូមលើក ខ្ញុំមិនចាំបានទេ ការចាប់មិនដឹងថាប៉ុន្មានគ្រួសារទេ។ ខ្ញុំអត់ចាំអស់ទេ ប៉ុន្តែបើយើងគិតនៅក្នុងស្រុកវាមានទំហំធំដែរ អ៊ីចឹងខ្ញុំមិនអាចបូកសរុបក្នុងការចាប់ចាមនេះ ជូនលោកបានទេ មិនដឹងថាប៉ុន្មាននាក់។ ហើយក៏ធ្វើនេះ វាគិតទៅខ្ញុំមិនមានតួលេខ កាលសម័យនោះយើងមានតួលេខ តែក្រោយមកខ្ញុំមិនបានចាំអស់។ មិនដឹងថាប៉ុន្មាននាក់នៅក្នុង ចាប់ចាមហ្នឹង ខ្ញុំមិនច្បាស់លាស់ដែរ។ វាចាំអស់ និយាយរួម គឺនិយាយខ្លីគឺចាំមិនអស់តែម្តង មិនដឹងចាប់ថ្ងៃទីប៉ុន្មានខែប៉ុន្មាន គឺខ្ញុំអត់ចាំ។

**ស៖** [redacted]

[០៩:២៩:៥៦]

**ប្រធានអង្គជំនុំ៖**

[redacted]

[redacted]

**លោក ខេល លីសាក់៖**

[redacted]

**លោក វ៉ិចទ័រ កូប៉េ៖**

[redacted]

[០៩:៣១:២៨]

**លោក ខេល លីសាក់៖**

[redacted]

**លោក វ៉ិចទ័រ កូប៉េ៖**

[redacted]

*(សម្រាករយៈពេលខ្លី)*

គឺថ្ងៃ១៤ មករា ២០១៦ គឺនៅមុនម៉ោង១៥:០៥:៥២ គឺនិយាយអំពីបញ្ជីមួយ។ ហើយគាត់បាននិយាយថា "សំណួរ៖ ថាតើនេះគឺជាបញ្ជីរបស់ប្រជាជនតែមួយឃុំទេ ឬមួយក៏របស់ស្រុកកំពង់សៀមទាំងមូល? គាត់ឆ្លើយថា៖ ចាស គឺសម្រាប់ស្រុកទាំងមូលតែម្តង"។

**លោក ខេល លីសាក់៖**

ដូច្នេះខ្ញុំចង់សួរថាតើសក្ខីកម្មហ្នឹងជាសក្ខីកម្មនៅឯណា? ហើយថាតើសាក្សីហ្នឹងគាត់ដឹងថាមានបញ្ជីសម្រាប់តែឃុំ ឬក៏ជាបញ្ជីតែមួយសម្រាប់ស្រុកតែមួយប៉ុណ្ណោះ។ ដូច្នេះគាត់ប្រហែលជាមិនអាចដឹង ឬក៏មិនអាចច្បាស់ថាមានបញ្ជីតែមួយ។

[០៩:៣៣:២៥]

**លោក វ៉ិចទ័រ កូប៉េះ៖**

យើងអាចជំទាស់គ្នាបានរហូត ប្រសិនបើយើងចង់ជំទាស់គ្នាមួយថ្ងៃក៏បានដែរ ប៉ុន្តែគាត់បាននិយាយអំពីការរៀបចំនូវបញ្ជា -- បញ្ជីទី២ ប៉ុន្តែបញ្ជីហ្នឹងមិនទាន់បានរៀបចំផងវៀតណាមក៏ចូលមកដល់។ ដូច្នេះហើយយើងមិនគួរធ្វើឱ្យភ័ស្តុតាងហ្នឹងច្របូកច្របល់ទេ ព្រោះអ្វីៗវាច្បាស់លាស់បែបនេះអស់ទៅហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិលើបញ្ហានេះ។ ហើយសំណួរនេះគឺមានមូលដ្ឋានត្រឹមត្រូវដោយផ្អែកលើប្រតិចារឹកដែលសាក្សី យូ វ៉ាន់ បានឆ្លើយចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះសាក្សី -- លោកមេធាវី វ៉ិចទ័រ កូប៉េ តាំងសំណួរសាជាថ្មីម្តងទៀតដើម្បីឱ្យសាក្សីរូបនេះឆ្លើយតបនឹងសំណួររបស់លោកបាន ព្រោះទំនងជាគាត់ភ្លេចសំណួររបស់លោកហើយ។

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងសួរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** អ្នកស្រីសាក្សី យូ វ៉ាន់ បាននិយាយអំពីបញ្ជីមួយដែលនៅក្នុងបញ្ជីហ្នឹង គឺមានឈ្មោះមេភូមិ មេឃុំ និងជនជាតិចាម ព្រមទាំងទាហាន លន់ នល់ ដែលគាត់យកមកជូនលោកស្រី។ ហើយបញ្ជីនេះគឺរៀបរាប់ពីស្រុកកំពង់សៀមទាំងមូលតែម្តង ហើយគាត់និយាយថានៅក្នុងបញ្ជីហ្នឹងគឺមានឈ្មោះប្រហែលជា៣០០នាក់។ គាត់ថាប្រហែលជាមាន២០០ជាង ប៉ុន្តែប្រហែលដល់៣០០។ ដូច្នេះខ្ញុំចង់សួរថាតើចំនួន៣០០ហ្នឹង អាចធ្វើឱ្យលោកស្រីនឹកឃើញបានដែរឬទេ?

[០៩:៣៥:១១]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមឆ្លើយតបសំណួរ។ ខ្ញុំមិនអាចនឹកឃើញទេ ព្រោះខ្ញុំបានសរុបទាំងស្រុក ដល់សរុបមកតាមឃុំ ចំនួននេះខ្ញុំមិនចងចាំអស់ទេ។ ហើយបើសរុបមួយឃើញបី មួយឃើញប៉ុណ្ណេះឃើញប៉ុណ្ណោះ ខ្ញុំសរុបមិនបានទេ ព្រោះខ្ញុំកាន់កាប់តែមួយស្រុក។ អ៊ីចឹងដល់សំណួរពីកន្លែងអ៊ីចឹង ខ្ញុំមិនដឹងថាប៉ុន្មានទេ។ ខ្ញុំក៏មិនច្បាស់លាស់ដែរ និយាយរួមគឺអត់ច្បាស់។ ហើយក៏ខ្ញុំក្តាប់មិនបានដែរ ក្នុងប្រជាជនបានលើកនេះ ខ្ញុំមិនយល់ដែរ ហើយក៏ស្តាប់មិនបានដែរ។ ហើយក៏ក្នុងចិត្តរបស់ខ្ញុំ ក៏គិតទៅ ក៏មិនឃើញថាតាមសំណួរ។ ខ្ញុំគិតមិនឃើញដែរ។ សុំអស់។

**ស៖** [redacted]

[០៩:៣៧:៣១]

**ឆ៖** [redacted]

**ស៖** [redacted]

**ឆ៖** [redacted]

[redacted]

[០៩:៣៩:៥៨]

**សៈ** មិនមានបញ្ហាអ្វីទេ អ្នកស្រីសាក្សី។ អរគុណដែលបានឆ្លើយ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត។ គឺប្រធានបទទាក់ទងទៅនឹងការប្រព្រឹត្តចំពោះអតីតទាហាន និងអ្នករដ្ឋការលន់ នល់។ កាលពីម្សិលមិញខាងព្រះរាជអាជ្ញាសួរអ្នកស្រីនូវសំណួរជាច្រើនអំពីប្រធានបទមួយនេះ ហើយគេសួរអ្នកស្រីអំពីបញ្ហា គឺបញ្ហាទាក់ទងទៅនឹងអតីតទាហាន លន់ នល់ ដែលរស់នៅក្នុងស្រុកកំពង់សៀម នៅពេលដែលអ្នកស្រីមកដល់។ ឥឡូវនេះខ្ញុំសូមអានទៅលើអ្វីដែលអ្នកស្រីបាននិយាយកាលពីម្សិលមិញ។ នៅប្រហែលជាម៉ោង១០:១៥នាទីពេលព្រឹក អ្នកស្រីបានឆ្លើយដូចតទៅនេះ៖ “មានការបញ្ជាឲ្យកំណត់អត្តសញ្ញាណទាហាន លន់ នល់ ដែលគេចាត់ទុកថាមិនល្អ ហើយនិងអ្នកដែលល្អ គឺត្រូវបានគេលើកលែងជីវិត។ គេប្រាប់ខ្ញុំឲ្យកំណត់អត្តសញ្ញាណទាហានជាច្រើនក្រុម ដូចជាអ្នកដែលប្រឆាំងអង្គការ ខ្ញុំត្រូវរកឲ្យឃើញខ្ញុំទៅប្រាប់គាត់ ហើយអ្នកដែលជាសមាសធាតុល្អ គឺគេឲ្យទុកជីវិត។” ហើយក្រោយមកទៀត នៅម៉ោង១០:៥១៖ “គឺថាខ្ញុំបានទទួលបញ្ជា ហើយខ្ញុំកំណត់នូវមនុស្សមួយចំនួនដែលគេចាត់ទុកថាមិនល្អ ហើយរាយការណ៍ទៅថ្នាក់លើ។ នៅពេលនោះខ្ញុំមិនដឹងថា គេធ្វើអ្វីចំពោះអ្នកទាំងអស់នោះទេ។ ចំពោះអ្នកដែលល្អ ខ្ញុំព្យាយាមជួយគេ ដោយអប់រំរៀនសូត្រដោយខ្លួនឯងផ្ទាល់។”ហើយក្រោមបន្តិច អ្នកស្រីបាននិយាយអំពីការស្រង់ប្រវត្តិអ្នកដែលល្អ។ អ្នកស្រីសាក្សី អ្នកស្រីខ្លួនឯង បាននិយាយថា អ្នកស្រីព្យាយាមជួយអប់រំរៀនសូត្រដល់ទាហានលន់ នល់ ដែលល្អ។ ដូច្នេះតើអ្នកស្រីធ្វើអ្វី? តើអ្នកស្រីធ្វើដោយផ្ទាល់ខ្លួន ក្នុងការអប់រំរៀនសូត្រហ្នឹង ឬក៏យ៉ាងម៉េចដែរ? ដូច្នេះខ្ញុំចង់ដឹងថា អ្នកស្រីធ្វើអ្វីជាក់ស្តែង សកម្មភាពដែលអ្នកស្រីថា អប់រំរៀនសូត្រដោយផ្ទាល់នោះ?

[០៩:៤២:៣៨]

**ធៈ** ខ្ញុំសូមឆ្លើយ ការអប់រំចំពោះអតីត ខ្ញុំបានធ្វើជាក់ស្តែងខ្លួនឯងពិតប្រាកដ គឺបានអប់រំ បានហៅធ្វើ ដូចថាសម័យនោះ គេហៅថា សន្និបាតប្រជាជន។ អប់រំគាត់ តាមការនិយាយ តាមការយល់ដឹងរបស់ខ្ញុំ ខ្ញុំផ្សព្វផ្សាយឲ្យគាត់យល់អំពីការខុសការត្រូវ។ ហេតុនេះខ្ញុំបានផ្សព្វផ្សាយឲ្យគាត់បានរៀន

សូត្រ អំពីទី១។ ទី២ ទៀត ជួនកាលខ្ញុំហៅយកមកបើកវគ្គសាលាអីតូចតាចអ៊ីចឹងទៅ នៅក្នុងភូមិឃុំរបស់ខ្ញុំដែលមានហើយ គឺខ្ញុំបានអប់រំតាមភូមិឃុំជាមួយមេឃុំអីអ៊ីចឹងទៅ។ អានេះខ្ញុំសូមជម្រាបអ៊ីចឹង។ មិនមែនថាអប់រំហ្នឹងហើយ យកគាត់ទៅណាទៅណី អត់ទេ។ ព្រោះខ្ញុំយល់ថាគាត់ អប់រំគាត់ឲ្យយល់អំពីច្បាប់យើង ដូចថាច្បាប់បដិវត្តន៍អ៊ីចឹងទៅណា គាត់មក គាត់រស់នៅជាមួយយើង ទាល់ឲ្យគាត់យល់បញ្ហាដែរ។ អ៊ីចឹងខ្ញុំមានការសន្និបាត ជាការអប់រំតូចៗនៅតាមភូមិអីអ៊ីចឹង ខ្ញុំមានការអប់រំ ចំពោះអតីតទាំងអស់នេះ ទាំងស្រី ទាំងប្រុស។ នេះខ្ញុំសូមជម្រាបប៉ុណ្ណឹង។ តែចំពោះអ្នកអាក្រក់ អ្នកល្អ អ្នកអាក្រក់វិញ ក៏មែនអាក្រក់រហូតដល់យើង គាត់ហ្នឹងយក មានធ្វើមួយនៅក្នុងភូមិឃុំទេ តែគ្រាន់ថាជួនកាលវាទំនាស់អ៊ីចេះអ៊ីចុះ តិចតួច បាយរួមបាយអីអ៊ីចឹងទៅ យើងអប់រំគាត់ដែរ។ នេះខ្ញុំសូមជម្រាបខ្លីអ៊ីចឹង។

**ស៖** អ៊ីចឹងបើតាមខ្ញុំយល់ គឺថាអ្នកស្រីខ្លួនឯងផ្ទាល់ ទៅតាមគ្រប់ឃុំទាំងអស់នៅក្នុងស្រុក ហើយនៅក្នុងឃុំនីមួយៗ អ្នកស្រីរៀបចំកិច្ចប្រជុំ។ ហើយនៅក្នុងកិច្ចប្រជុំហ្នឹងគឺអតីតទាហាន លន់ នល់ និងអ្នករដ្ឋការលន់ នល់ ចូលរួម ហើយអ្នកស្រីខ្លួនឯងផ្ទាល់ ពន្យល់ទៅដល់ពួកគេ គឺបានន័យថា អ្នកស្រីអប់រំរៀនសូត្រ។ តើអ៊ីចឹងមែនទេ?

[០៩:៤៥:១០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

មេធាវីកំពុងតែនាំឲ្យសាក្សីយល់ខុស គឺថា គាត់និយាយអំពីការអប់រំអ្នកដែលធ្វើ អ្នកដែលគេចាត់ទុកថាល្អ ប៉ុន្តែសាក្សីមិនបាននិយាយថា គាត់ទៅអប់រំទាហាន លន់ នល់ ទាំងអស់នោះទេ គឺអប់រំតែអ្នកដែលល្អនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន សាក្សីគាត់ឆ្លើយរួចទៅហើយថា “ចាស”។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ្នកស្រីសាក្សី ដូច្នេះថាតើនេះ គឺជាអ្វីដែលអ្នកស្រីតែងតែអនុវត្តនៅក្នុងតំបន់ដែលអ្នកស្រីធ្វើការដែរឬ គឺតំបន់៣៥ កំពតនោះ? តើអ្នកស្រីធ្វើដូចគ្នានៅកំពតដែរឬទេ នៅពេលនុំង គឺអ្នកស្រីទៅ

ជួបនិយាយជាមួយនឹងអតីតទាហាន លន់ នល់ ដែលល្អ ហើយបន្ទាប់មកអប់រំ ឬក៏អប់រំរៀនសូត្រពួកគេ? តើអ្នកស្រីធ្វើដូចគ្នាអ៊ីចឹងដែរទេ?

[០៩:៤៦:១៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា សំណួរគឺបញ្ជាក់ឲ្យច្បាស់ ព្រោះគាត់និយាយថា គាត់សួរសាក្សីអំពីការកើតឡើងនៅកំពត ឲ្យរៀបរាប់អំពីហេតុការណ៍នៅក្នុងតំបន់។ ដូច្នេះគាត់គួរតែសួរថាអ្នកដែលមិនល្អ ត្រូវគេចាប់ខ្លួន ចំណែកអ្នកដែលល្អ ត្រូវបានគេយកអប់រំរៀនសូត្រ។ អ៊ីចឹងដូច្នេះខ្ញុំ គិតថាគាត់គួរតែសាកសួរឲ្យបានច្បាស់លាស់បន្តិច ឬក៏គាត់អាចសួរជាសំណួរបើកចំហ ថាតើមានអ្វីកើតឡើងនៅតំបន់ដទៃទៀត ជាជាងការសួរបែបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមានបញ្ហាទេ ខ្ញុំអាចធ្វើដូច្នេះបាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ្នកស្រីសាក្សី យើងបានរៀបរាប់អំពីការប្រជុំ ក្នុងការអប់រំរៀនសូត្រមន្ត្រីរដ្ឋការ និងទាហានលន់ នល់ ទោះបីថាល្អ មិនល្អ ឬក៏ល្អហ្នឹងក៏ដោយ នៅក្នុងស្រុកកំពង់សៀម។ ដូច្នេះខ្ញុំចង់សួរថានៅក្នុងតំបន់៣៥កំពត តើអ្នកស្រីធ្វើយ៉ាងដូចម្ដេច ជាមួយអតីតទាហាន លន់នល់?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ក្នុងខេត្តកំពត កាលខ្ញុំនៅ ធ្វើដូចនៅស្រុកកំពង់សៀមដែរ ព្រោះគាត់មកនៅតាមភូមិឃុំខ្ញុំធ្វើបានទាំង ធ្វើបានដូចគ្នា អត់មានខុសគ្នាទេ គឺអប់រំដូចគ្នា។

**ស៖** អ៊ីចឹងខ្ញុំអាចនិយាយបានទេថា អ្នកស្រីចម្លងនូវវិធីសាស្ត្រការងារក្នុងការអនុវត្តជាមួយទាហានលន់នល់ ពីខេត្តកំពង់សៀមយកមក តើអ៊ីចឹងមែនទេ?

[០៩:៤៨:៣១]

**ឆ៖** ខ្ញុំសូមជម្រាបសំណួរ ខ្ញុំស្ដាប់អត់បាន។ សូមសួរម្ដងទៀត។

**ប្រធានអង្គជំនុំ៖**

បាទ រៀបសំណួរម្តងទៀត សំណួរហ្នឹងដូចជាផ្ទុយជាមួយនឹងព្រឹត្តិការណ៍ហើយ។ ពិបាកឆ្លើយ អ្នកណាក៏បែបទំនងឆ្លើយមិនចេញទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមានបញ្ហាអ្វីទេ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំចង់សួរអ្នកស្រីសាក្សី បានរៀបរាប់អំពីការទៅតាមឃុំនៅក្នុងស្រុកកំពង់សៀម ដោយអញ្ជើញអតីតទាហាន លន់ នល់ និងអ្នករដ្ឋការ លន់នល់ មកជួបប្រជុំ ព្យាយាមអប់រំរៀនសូត្រ លត់ដំពួកគេ។ ដូច្នេះខ្ញុំចង់សួរថា នេះគឺជាអ្វីដែលអ្នកស្រីបានចម្លងចេញពីការងារនៅកំពត តើមែនទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះ។ ខ្ញុំយកពីស្រុកកំពត ទៅចម្លងនៅកំពង់សៀមបានត្រូវ ព្រោះខ្ញុំនៅកំពត មុនកំពង់សៀម។ អ៊ីចឹងអតីតទាំងអស់នេះ យើងនៅកំពតធ្វើហើយៗ អប់រំហើយ ផ្សព្វផ្សាយហើយ តែខ្ញុំទៅស្រុកកំពង់សៀម ក៏ខ្ញុំយកបញ្ហានេះទៅធ្វើតាមស្រុកកំពត នៅខេត្តកំពតដែរ ព្រោះខ្ញុំនៅកំពតមុនកំពង់សៀម។ សូមបញ្ចាក់។

[០៩:៥០:១៧]

**ស៖** សូមអរគុណអ្នកស្រី។ តើអ្នកស្រីអាចប្រាប់ខ្ញុំបានទេថា ការអប់រំរៀនសូត្រហ្នឹងជាទូទៅចំណាយពេលប្រហែលប៉ុន្មានដែរ? ហើយអ្នកស្រីអាចរៀបរាប់លម្អិតបានទេ អំពីដំណើរការក្នុងការប្រជុំអប់រំរៀនសូត្រនោះ?

**ឆ៖** ខ្ញុំសូមជម្រាបអំពីសំណួរនេះ ការអប់រំ ជួនកាលខ្ញុំអត់បានចុះទៅគ្រប់ឃុំទេ ដូចជានៅតំបន់៣៥អ៊ីចឹង ខ្ញុំឲ្យមេភូមិ មេឃុំគាត់ជួយអប់រំតៗគ្នា។ ហេតុនេះ គឺមិនចំណាយពេល យូរពេលយូរទេ គឺចំណាយមួយថ្ងៃ ចំណាយកន្លះថ្ងៃ ព្រោះការងារយើងត្រូវធ្វើច្រើន។ អ៊ីចឹងយកពេលហ្នឹងអប់រំ ដូចថាមួយថ្ងៃអ៊ីចឹងទៅ កន្លះថ្ងៃអ៊ីចឹងទៅ។ នេះខ្ញុំសូមជម្រាប មិនមែនយកពេលពីរបីថ្ងៃទេ គ្រាន់តែផ្សព្វផ្សាយឲ្យគាត់យល់អំពីបញ្ហារស់នៅក្នុងភូមិមួយៗ ដើម្បីឲ្យចេះសាមគ្គីគ្នា ធ្វើម៉េចកុំទាស់ទែង ទោះបីតែប្រជាជនហ្នឹងយើងជម្លៀសមកថ្មីមែន តែក៏យើងត្រូវជួយៗគាត់ សាមគ្គីជាមួយគាត់ ការហូបចុក ស៊ីចុកនៅក្នុងសហករណ៍អីកុំឲ្យមានការទាស់គ្នា។ អាហ្នឹងខ្ញុំលើកឲ្យឃើញបញ្ហាអ៊ីចឹង។ ហើយនៅកំពង់សៀម

ក៏ខ្ញុំធ្វើដូច្នេះដែរ អត់មានខុសគ្នាទេ ព្រោះការយល់ គាត់ចូលមកថ្មីធម្មតាទេ វាយើងមិនយល់ចិត្តគ្នាទៅវិញទៅមក ទាល់តែមេឃុំ មេភូមិហ្នឹងជួយអប់រំតម្រែតម្រង់គាត់។ នេះខ្ញុំសូមជម្រាបខ្លីប៉ុណ្ណឹងទេ។

**ស៖** អ្នកស្រីសាក្សី ខ្ញុំអាចនិយាយបានទេថា នៅតំបន់៣៥ ហើយក្រោយមកទៀត នៅក្នុងស្រុកកំពង់សៀមក្នុងតំបន់៤១ អតីតទាហាន លន់ នល់ គឺមានអ្នកដែលល្អ ដែលមិនជំទាស់ ដែលមិនប្រឆាំងជាមួយបដិវត្តន៍អាចរស់នៅដោយសុខ នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ តើអ៊ីចឹងមែនទេ?

[០៩:៥៣:១១]

**ឆ៖** ខ្ញុំសូមឆ្លើយ នៅស្រុកកំពង់សៀម អតីតទាហាននេះ អ្នកល្អគឺរស់សុខទាំងអស់គ្នា អត់មានបញ្ហាអីទេ ព្រោះមានការអប់រំពីឃុំ ពីភូមិជាប់របស់គាត់។ អត់មានទាស់អីទេ អត់មានទំនាស់អីទាស់ទែងគ្នាទេ។

**ស៖** ឥឡូវនេះ ខ្ញុំសូមថយក្រោយបន្តិច។ ដូច្នេះខ្ញុំចង់ឲ្យអ្នកស្រីបញ្ជាក់លម្អិតបន្តិចអំពីសំណួរចម្លើយដែលអ្នកស្រីឆ្លើយជាមួយនឹងសំណួររបស់លោកប្រធាន។ លោកប្រធានសួរអ្នកស្រីអំពីការប្រជុំ គឺការប្រជុំពីរបីថ្ងៃនៅភ្នំពេញ គឺក្នុងឆ្នាំ៧៥។ តើការប្រជុំដែលអ្នកស្រីរៀបរាប់កាលពីម្សិលមិញ ដែលតើវាអាចទេដែលថា កើតឡើងនៅក្នុងប្រហែលថ្ងៃ២០ ខែឧសភា ឆ្នាំ១៩៧៥នោះ?

**ឆ៖** ខ្ញុំសូមរៀបរាប់អំពីការប្រជុំ កាលនៅកន្លែងភ្នំពេញ គឺរឿងនេះ ខ្ញុំមិនបាច់រៀបរាប់ថែមទេ ខ្ញុំបានបញ្ជាក់រួចហើយ គឺបានរៀន -- ៧៥ ខ្ញុំបានចូលប្រជុំមែន។ ហេតុនេះ--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ លោក! ប្រាក់ យុត សំណួរនេះសួរអ៊ីចេះទេ សួរថាវាទំនងដែរទេ ថាកិច្ចប្រជុំនុ៎ងដំណើរការនៅក្នុងអំឡុងចាប់ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥។ សួរសំណួរជាក់លាក់មួយ។ ជាក់លាក់គឺថា តើកិច្ចប្រជុំដែលលោកស្រីចូល ទៅចូលរួមប្រជុំនោះ វាទំនងដែរទេថា វាអំឡុងទៅនឹង វាចាប់ផ្តើមពីថ្ងៃទី២០ ខែឧសភា ឬក៏ខែ៥ ឆ្នាំ១៩៧៥។ នេះជាសំណួរដែលត្រូវឆ្លើយ គឺគ្រាន់តែវាទំនងអំឡុងពេលហ្នឹង ឬក៏អត់ មិនចាំតែប៉ុណ្ណឹងទេ។

[០៩:៥៥:៤៣]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** សំណួរហ្នឹងខ្ញុំសូមតបទៅវិញថា បានប្រជុំមែននៅថ្ងៃហ្នឹងខែហ្នឹង ខ្ញុំបានប្រជុំនៅភ្នំពេញមែន។ ហើយវាសមស្របដែលខ្ញុំបានឡើងមកប្រជុំមែន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរគុណអ្នកស្រី។ កាលពីម្សិលមិញ អ្នកស្រីនិយាយថា អ្នកស្រីចាំថាមានមនុស្សប្រហែលជា៣០០នាក់ដែលបានចូលរួម ប៉ុន្តែអ្នកស្រីមិនប្រាកដទេថា មានកងទ័ពបដិវត្តន៍ ឬក៏អ្នកប្រយុទ្ធចូលរួម។ តើអ្នស្រីអាចចាំបានទេ អាចរំឭកនឹកឃើញបានទេថា ក្រៅពីអ្នកតំបន់ ឬក៏អ្នកភូមិភាគហ្នឹង ក៏មានទាហាន ឬក៏កងទ័ពចូលរួមផងដែរ? តើអ្នកស្រីអាចនឹកឃើញទេអំពីហេតុការណ៍នេះ?

**ឆ៖** ការប្រជុំនេះ និយាយរួមខ្ញុំបានចូលប្រជុំជាមួយគណៈតំបន់ហ្នឹង តែមិនបានចាប់អារម្មណ៍ពីរឿងកងទ័ព មិនដឹងថាថ្ងៃហ្នឹងបានចូលរួមអត់។ ខ្ញុំអត់វាអត់ច្បាស់តែម្តង។ និយាយរួមគឺសុំថាមិនច្បាស់ ហើយខ្ញុំនិយាយទៅក៏វាមិនដឹថាចូល មិនចូល ខ្ញុំអត់ហ៊ានថា ព្រោះវាអត់ច្បាស់លាស់ខ្លួនឯង។ មិនដឹងជាចូលមកក្នុងមជ្ឈដ្ឋានណាខ្លះទេ កាលនុ៎ង។ ប៉ុន្តែចំនួនច្រើនមែន តែមិនដឹងមជ្ឈដ្ឋានណា ព្រោះខ្ញុំមិនបានយកចិត្តទុកដាក់ដែរកាលនុ៎ង។ ប៉ុន្តែចំនួន៣០០គឺបានលើក តែចំនួននេះមិនដឹងថាមជ្ឈដ្ឋានណាខ្លះដែលត្រូវចូលក្នុងអង្គប្រជុំនៅភ្នំពេញនេះ។ ខ្ញុំអត់ច្បាស់។ សូមជម្រាបប៉ុណ្ណឹង។

[០៩:៥៨:០០]

**ស៖** មិនមានបញ្ហាអ្វីទេ អ្នកស្រីសាក្សី គឺមិនមានភ័ស្តុតាងអ្វីច្រើននោះទេ ប៉ុន្តែយើងមានភ័ស្តុតាងមួយចំនួនទាក់ទងនឹងការប្រជុំនោះ។ ហើយមានមនុស្សម្នាក់ដែលបានឆ្លើយថា គាត់បានចូលរួមក្នុងកិច្ចប្រជុំហ្នឹងគឺឈ្មោះ ហេង សំរិន។ បច្ចុប្បន្ននេះដែលលោកស្រីដឹងហើយ គាត់ជាប្រធានសភាជាតិ។ ហើយគាត់បានផ្តល់សក្ខីកម្មអំពីអ្វីដែលបានថ្លែងនៅក្នុងកិច្ចប្រជុំនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដោយសារខ្ញុំដឹងថា វាមិនមាននៅក្នុង*អ៊ីនធើហ្វេស* នោះទេ។ ហើយលោកប្រធានក៏បាន កាលពីម្សិលមិញបានសួរអំពីសំណួរទាក់ទងទៅនឹងបញ្ហានេះ។ ប៉ុន្តែដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ធ្វើការដកស្រង់នូវឯកសារ E3/1568 អង់គ្លេសមានលេខ 00651884ជាភាសាអង់គ្លេស, ខ្មែរមានលេខ00713954និងដល់55 និងបារាំងមានលេខ00743356 វាគឺជាការ គឺជាកិច្ចសម្ភាសន៍រវាង ប៊ែន ឃៀរនិន ជាមួយនឹង ហេង សំរិន។ ហើយជាពិសេសគឺនិយាយអំពីដែលគាត់បាននិយាយថា គាត់បានស្តាប់ឮនៅក្នុងកិច្ចប្រជុំ ទាក់ទងទៅនឹងគោលនយោបាយចំពោះអតីតអ្នករដ្ឋការ និងទាហាន លន់ នល់។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ខេល លីសាក់៖**

ខ្ញុំមិនជំទាស់ទៅលើមេធាវីនោះទេ ក្នុងការអនុញ្ញាត ឬក៏មិនអនុញ្ញាតដាក់ឯកសារដែលមិនមាននៅក្នុង*អ៊ីនធើហ្វេស* ប៉ុន្តែអ្វីដែលខ្ញុំចង់ស្នើសុំ គឺថាសូមឲ្យសាក្សីគាត់ដឹងផង ដែលថាវាមានសាក្សីបីនាក់ទៀត ដែល ប៉ែន យៀវនិន សម្ភាស គាត់និយាយផ្សេងពីសាក្សីដែលមេធាវីប្រុងលើកនេះ។ ដូច្នេះត្រូវបញ្ជាក់ឲ្យបានច្បាស់ ថាមានសាក្សីបីនាក់ផ្សេងទៀត គាត់និយាយផ្សេងពីអ្វីដែលមេធាវីចង់លើកឡើង។ ដូច្នេះខ្ញុំសូមផ្តល់ជាព័ត៌មាន។

[១០:០០:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាខ្ញុំគិតថា ព្រះរាជអាជ្ញាមិនគួរប្រាប់ខ្ញុំថា ខ្ញុំត្រូវធ្វើយ៉ាងម៉េចៗក្នុងការសួរដេញដោលរបស់ខ្ញុំនោះទេ។ ខ្ញុំមានវគ្គ ខ្ញុំមានពេលពីរពេលរបស់ខ្ញុំ ដូច្នេះខ្ញុំអាចសួរអ្វីក៏បានដែរ ស្រេចតែខ្ញុំ។ ដូច្នេះខ្ញុំអាចលើកពីអ្វី។ ការពិតទៅ ខ្ញុំនិយាយខុសហើយ គឺឯកសារហ្នឹងមាននៅលើ*អ៊ីនធើហ្វេស*រួចទៅហើយ។ ប្រសិនបើលោកប្រធាន ខ្ញុំនឹងអាននូវសម្រង់នេះ ឲ្យសាក្សីស្តាប់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះលោកសាក្សី ទោះបីតែខ្ញុំដឹងថា កាលពីម្សិលមិញ អ្នកស្រីបាននិយាយថា អ្នកស្រីមិនបានស្តាប់ឮអ្វីពី នួន ជា ឬក៏ ប៉ុល ពត ឬក៏ សោ ភឹម, តាម៉ុក អំពីគោលនយោបាយផ្លូវការពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះទាហាន លន់ នល់ ក៏ដោយ។ ប៉ុន្តែ ហេង សំរិន បាននិយាយ នៅពេលដែលគេពិភាក្សាអំពីប្រធានបទនេះ ហើយគាត់បាននិយាយថា៖ "គេមិនបាននិយាយថា សម្លាប់ កម្ទេច ប៉ុន្តែពួកគេនិយាយថា មិនត្រូវទុកពួកគេឲ្យនៅក្នុងក្របខ័ណ្ឌទេ វាមិនមែនមានន័យ កម្ទេចទេ។" នេះគឺអ្វីដែលគាត់ចាំទៅលើការប្រើពាក្យរបស់ នួន ជា។ ដូច្នេះខ្ញុំចង់សួរថា អ្នកស្រីចាំទេ ថាតើ នួន ជា នៅក្នុងពេលនោះ គាត់ប្រើពាក្យថា "កម្ចាត់អតីតទាហានលន់ នល់"? តើ នួន ជា គាត់ប្រាប់ពាក្យ "កម្ចាត់អតីតទាហានលន់ នល់" ដែរឬទេ?

[១០:០២:៤៩]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ ពាក្យនេះ ខ្ញុំមិនអាចចាំ ព្រោះខ្ញុំមិនចាំតែម្តង ពាក្យគាត់និយាយទាំងអស់ ដែលលើកក្នុងសំណួរហ្នឹង ខ្ញុំអត់បានចាំទេ។ មិនដឹងគាត់និយាយពេលណា ខែណា ខ្ញុំអត់ចាំ។

**ស៖** មិនជាថ្វីទេ លោកស្រីសាក្សីដោយសារថាពេលវេលាវាយូរណាស់មកហើយ។ ប៉ុន្តែលោកស្រីប្រហែលជាអាចនៅចាំអ្វីដែលគេបាននិយាយនៅក្នុងកិច្ចប្រជុំមួយលើក ឬក៏ពីរលើក ដែលលោកស្រីអាចនៅចាំបាន គឺកិច្ចប្រជុំដែលបានធ្វើឡើងនៅក្រុងតាកែវ។ តើលោកស្រីនៅចាំបានទេ ថាភ្លាមៗក្រោយពីកិច្ចប្រជុំនេះ គឺថាមានកិច្ចប្រជុំមួយទៀតធ្វើឡើងនៅភូមិភាគនិរតី ដែលក្នុងកិច្ចប្រជុំនោះ គឺគេនិយាយអំពីគោលនយោបាយ ជាពិសេស និយាយថាតើត្រូវធ្វើចាត់ការយ៉ាងម៉េចជាមួយនឹងអតីត លន់ នល់ ជាពិសេស គឺចាប់ពីឋានន្តរសក្តិ ចាប់ពីស័ក្តិ១ ចុះមកក្រោម?

**ឆ៖** ខ្ញុំលើកបញ្ហាប្រជុំនៅតាកែវ។ លោកបញ្ជាក់ឲ្យខ្ញុំថា បានចាំទេបញ្ហាហ្នឹង។ មានលើកគោលការណ៍អ៊ីចឹង ខ្ញុំគិតទៅ ខ្ញុំអង្គុយគិតក្នុងខ្លួនខ្ញុំនេះ ក៏ខ្ញុំគិតដែរថា ទោះបីលើកសម័យនោះមែនតែមកដល់ថ្ងៃនេះ ខ្ញុំអត់មានការផ្តោតលើបញ្ហាហ្នឹងវិញ ហេតុនេះការចងចាំ ក៏ខ្ញុំភ្លេចដែរ។ នេះខ្ញុំសូមជម្រាបត្រង់អ៊ីចឹងតែម្តង។ ព្រោះវាថ្ងៃនោះមកដល់ថ្ងៃនេះហើយ ខ្ញុំមិនបានផ្តោតលើបញ្ហាហ្នឹងទៀតទេ ខ្ញុំផ្តោតរាល់ថ្ងៃ ខ្ញុំមិនបានផ្តោតទេ។ អ៊ីចឹងការភ្លេច មិនដឹងថានិយាយពីអីៗខ្លះ ខ្ញុំវាមិនបានចាំទេ។ ខ្ញុំសូមជម្រាបដោយត្រង់តែម្តង។

[១០:០៥:៣៦]

**ស៖** ខ្ញុំយល់ហើយលោកស្រីសាក្សី។ ខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោកស្រី។ ពីម្សិលមិញ លោកស្រីបានឆ្លើយយ៉ាងច្រើនអំពី តា ជឹម ដែលលោកស្រីបានស្គាល់យ៉ាងច្បាស់។ តា ជឹម ក៏ត្រូវបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយក៏បានសួរថា តើគាត់បានចូលរួមប្រជុំនោះដែរឬក៏អត់ គាត់ឆ្លើយថា គាត់បានចូលរួមប្រជុំ។ ក្នុងកិច្ចប្រជុំនោះ គឺគេនិយាយអំពីថា ត្រូវចាត់ការយ៉ាងម៉េចចំពោះទាហានពីស័ក្តិ១ ទៅដល់ស័ក្តិ៥។ លោកប្រធាន ឯកសារនេះគឺឯកសារ E329.2.1 នៅម៉ោងដប់ព្រឹក៖ “សួរ៖ លោក ពេជ្រ ជឹម តើវាច្បាស់ទេ សម្រាប់លោក? ច្បាស់ណាស់ គឺថានៅចុងបញ្ចប់នោះគេនិយាយថា ទាហានស័ក្តិ១ទៅដល់--

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

អត់មានការបកប្រែទេ។ អ្នកបកប្រែឮទេ ឬក៏មានបញ្ហាបច្ចេកទេស?

**អ្នកបកប្រែ៖**

បាទៗ។

**ប្រធានអង្គជំនុំ៖**

អ៊ំា?

**អ្នកបកប្រែ៖**

ឮហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សាម្តងទៀត លោក វ៉ិចទ័រ កូប៉េ ដកស្រង់នូវពីប្រតិចារឹកអំមិញសាជាថ្មីឡើងវិញ ត្រង់ចំណុចអំមិញនេះ ព្រោះមានការបកប្រែទៅបានបន្តិច ដាច់តែម្តង។

[១០:០៧:៤៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។

**ស៖** នៅម៉ោងដប់ព្រឹក គឺឯកសារ E1/291.1 ជាសក្ខីកម្មរបស់ ពេជ្រ ជឹម នៅថ្ងៃទី២៩ កុម្ភៈ ២០១៥៖ "សំណួរ៖ លោក ពេជ្រ ជឹម តើវាច្បាស់លាស់ទេ សម្រាប់លោក? ឆ្លើយ៖ ច្បាស់ហើយ នៅចុងបញ្ចប់នៃថ្ងៃប្រជុំ ថាទាហានពីស័ក្តិ១ ទៅដល់ស័ក្តិ៥ហ្នឹង គឺថាកុំប៉ះពាល់គេអី។ ឆ្លើយថា៖ បាទ ហ្នឹងអ្វីដែលយើងយល់។ កាលនៅពេលនោះ យើងយល់ថាអ៊ីចឹង។" លោកស្រីសាក្សី ពេជ្រ ជឹម បានពន្យល់លម្អិតផងដែរ សំណួរ នេះក៏ទាក់ទងទៅនឹងប្រធានបទដដែលនេះដែរ។ លោក ពេជ្រ ជឹម បានឆ្លើយដូចតទៅ៖ "នៅម៉ោងដប់ បួននាទី អ្នកៗដែលមានឋានន្តរស័ក្តិតូចតាច បុណ្យស័ក្តិតូចតាច គឺថានឹងទុកឲ្យរស់រានមានជីវិត។ ហើយអ្នកដែលមានស័ក្តិ ពីស័ក្តិ១ទៅដល់ស័ក្តិ៥ហ្នឹង គឺថាមិនត្រូវប៉ះពាល់គេទេ។ អ៊ីចឹង ពេជ្រ ជឹម គាត់បានបញ្ជាក់ថា ទាហានពីបុណ្យស័ក្តិ ពីស័ក្តិ១ ទៅដល់ស័ក្តិ៥ មិនត្រូវប៉ះពាល់ពួកគេទេ។ ហើយទាហានដែលមានឋានៈកាន់តែទាប ជាងពីស័ក្តិ១ចុះមក ក៏កាន់តែលែងឲ្យប៉ះពាល់ទៅទៀត"។ សំណួររបស់ខ្ញុំសួរថា តើលោកស្រីនៅចាំអ្វីដែលគេបានណែនាំ និងបានបង្គាប់នៅក្នុងកិច្ចប្រជុំនោះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១០:១០:០៩]

**លោក ឌេល លីសាក់៖**

ការជំទាស់របស់ខ្ញុំទៅនឹងសំណួរនេះ គឺថាសាក្សីក៏បានទទួលព័ត៌មាន ហើយមេធាវីការពារក្តីបានអាននូវសេចក្តីណែនាំនៅពេលនោះ ហើយ ពេជ្រ ជឹម ក៏បានផ្តល់សក្ខីកម្មថា នៅពេលនោះគឺក្រោយពីពេលរំដោះប្រហែលជាក្នុងខែមេសា-ឧសភា គឺចៅហ្វាយស្រុកកូនរបស់ តាម៉ុក គឺថាក៏គាត់បានចូលរួមប្រជុំ ថាពីស័ក្តិ១ឡើងទៅត្រូវតែកម្ទេចចោល។ ដូច្នេះការរៀបរាប់ហ្នឹង គឺវាមានលក្ខណៈខុសគ្នាក្នុងអំឡុងពេលខុសៗគ្នា។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនគិតថា គាត់បានឆ្លើយថាយ៉ាងដូច្នេះទេ ឬក៏បញ្ជាក់ន័យថាយ៉ាងដូច្នេះទេ។ ឥឡូវនេះគឺថាសហព្រះរាជអាជ្ញារងអន្តរជាតិកំពុងតែព្យាយាមរំខានទៅដល់ការតាំងសំណួររបស់ខ្ញុំ។ ខ្ញុំកំពុងតែអានសម្រង់ចេញពីសក្ខីកម្មដែលបានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះ ហើយខ្ញុំសួរទៅសាក្សីថាគាត់យល់យ៉ាងដូចម្តេចដែរ។

[១០:១១:២៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី ខ្ញុំនឹងសួរសំណួរនេះឡើងវិញ តើត្រឹមត្រូវទេ ដែលថាមានគោលនយោបាយសម្រាប់ភូមិភាគនិរតី ថាមិនត្រូវឲ្យប៉ះពាល់ទាហាន លន់ នល់ ណាទេ ចាប់ពីកូនទាហានរហូតទៅដល់ៗវរសេនីយ៍ឯកហ្នឹង គឺថាមិនត្រូវប៉ះពាល់ទេ លោកស្រីចាំមានគោលនយោបាយហ្នឹងទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមមានមិត គោលនយោបាយនេះ ខ្ញុំអាចចាំខ្លះ អត់ខ្លះ។ តែបើខ្ញុំសូមលើកថា សំណួររបស់ខាងក្រៅ ខ្ញុំអត់ដឹង។ តែចំពោះខ្ញុំ ខ្ញុំក៏មានគោលការណ៍មួយចំនួនហ្នឹង ក៏ខ្ញុំមានការចាំខ្លះដែរ តែវាអត់ចាំខ្លះ។ នេះ ខ្ញុំសូមនិយាយពីផ្នែកអ៊ីចឹងតែម្តង។ សូមអស់។

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះ យើងបញ្ជាក់ឡើងវិញ គឺនេះជានីតិវិធីនៃការពិភាក្សាដេញដោលតាមផ្លូវតុលាការ វាត្រូវផ្ដូផ្គងរវាងចម្លើយសក្ខីកម្មសាក្សីដែលមានឋានៈ និងទំនងជាអាចជាមានការចូលរួមនៅក្នុងកិច្ចប្រជុំ នៅក្នុងកម្រិតតំបន់ ឬភូមិភាគ ជាមួយនឹងលោកស្រី។ បញ្ហាទី១ គឺថាតើលោកស្រីបានចូលរួមប្រជុំនៅជាមួយហ្នឹងដែរទេ។ ទី២ ព័ត៌មានដែល ពេជ្រ ជឹម បានផ្ដល់អ៊ីចឹង តើវាសមស្រប ឬក៏លោកស្រីធ្លាប់ឮដូចប្រហាក់ប្រហែលគ្នានឹង ពេជ្រ ជឹម ដែរឬទេ ឬក៏លោកស្រីឮផ្សេងពីនេះ នៃការអនុវត្តគោលនយោបាយចំពោះអតីតទាហានរបប លន់ នល់?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមជម្រាបម្ដងទៀត ខ្ញុំសូមជម្រាបត្រង់ថា ការប្រជុំនេះ បើគិតទៅវាមានការប្រហាក់ប្រហែលគ្នា ព្រោះអំមិញខ្ញុំនិយាយថា វាមានប្រហាក់ប្រហែលមែន តែឲ្យខ្ញុំចាំទាំងអស់ ក៏វាមិនចាំដែរ តែវាអាចប្រហាក់ប្រហែលគ្នា។ ការដាក់ផែនការចុះមក គឺដូចគ្នា វាមិនអាចខុសគ្នាបានទេ។ ដូចថាតំបន់តែមួយ ភូមិភាគតែមួយ អ៊ីចឹងទៅយើងទៅរៀនដូចគ្នា។ អ៊ីចឹងវា ខ្ញុំថាអាចប្រហាក់ប្រហែលគ្នាធ្វើផែនការ គឺផែនការដូចគ្នាអ៊ីចឹង។ អ៊ីចឹងវាមិនអាចខុសគ្នាទេ។ នេះខ្ញុំសូមជម្រាបអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី វ៉ិចទ័រ កូប៉េ។ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅលោកមេធាវី វ៉ិចទ័រ កូប៉េ តាំងសំណួរដេញដោលចំពោះសាក្សី អង្គជំនុំជម្រះសូមរំឭកដល់ភាគី ជាពិសេសតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ សូមឲ្យមានការប្រយ័ត្នប្រយែងលើកបញ្ហានៃការជំទាស់។ ប្រសិនបើមេធាវីការពារក្តី គេលើកឡើងនូវប្រតិចារឹកដែលជាកំណត់ហេតុកត់ត្រានូវសក្ខីកម្មរបស់សាក្សីមុនៗ នោះគឺមិនអាចជំទាស់បានទេ។ លោកអាចជំទាស់បាន ក្នុងករណីការដកស្រង់នោះគឺ វាមិនត្រឹមត្រូវទៅតាមខ្លឹមសារនៃកំណត់ហេតុ។ ហើយបញ្ហាទី២ គឺលោកមេធាវី វ៉ិចទ័រ កូប៉េ និងភាគីដទៃទៀត គប្បីមានការបើកទូលាយនូវការតាំងសំណួរទូទៅនៃការយល់ដឹងរបស់សាក្សីជាមុន។ ហើយមុននឹងយកសក្ខីកម្ម ឬក៏យកប្រតិចារឹកពីកំណត់ហេតុការស្តាប់ចម្លើយភាគីដទៃទៀត ឬក៏សាក្សីដទៃទៀតមកផ្ទុះផ្ទុង។ ហ្នឹងដើម្បីជំរុញដល់ល្បឿននៃកិច្ចដំណើរការនីតិវិធី។ ហើយមួយទៀតភាគីទាំងឡាយ នៅក្នុងដំណើរការរឿងក្តីនេះ មិនគប្បីបង្រៀនភាគីម្ខាងទៀត យកវេទិកានេះធ្វើជាសាលាបង្រៀនអំពីទ្រឹស្តីបច្ចេកទេស និងអនុវត្តច្បាប់តុលាការនៅចំពោះមុខយើងទេ។

បាទ ប្រគល់វេទិកាជូនទៅលោកមេធាវី វ៉ិចទ័រ កូប៉េ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[១០:៣៣:២០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្តីសាជាថ្មី លោកស្រីសាក្សី។ ខ្ញុំនឹងលើកឡើងអំពីប្រធានបទ ដែលយើងបានពិភាក្សាគ្នាមុនពេលឈប់សម្រាកឡើយវិញ។ គឺគោលនយោបាយរបស់ភូមិភាគនិរតី ពាក់ព័ន្ធទៅនឹងអតីតទាហាន លន់ នល់ ពីកូនទាហានរហូតដល់ស័ក្តិ៥។ តើលោកស្រីចាំមិនបានច្បាស់លាស់អំពីគោលនយោបាយនេះ ឬក៏យ៉ាងណា? ឥឡូវនេះ ខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោកស្រីបន្តិច។ ខ្ញុំសុំលោកប្រធាន ខ្ញុំសុំអានសម្រង់មួយឲ្យសាក្សីនេះស្តាប់ ប៉ុន្តែគេបានប្រាប់ខ្ញុំថា នេះគឺជាប្រតិចារឹកដែលមិនអាច*អាប់ឡូដ*មកដាក់នៅលើ*អ៊ីនធើហ្វេស*បានទេ គឺជាសក្ខីកម្មសាក្សីម្នាក់បានឆ្លើយជូនអង្គជំនុំជម្រះតុលាការកំពូល។ ដូច្នេះការសំអាងទៅលើឯកសារនេះ ខ្ញុំសូមអានយឺតៗ ដើម្បីឲ្យយើងអាចពិនិត្យមើលឯកសារ គឺនៅថ្ងៃទី០៨ ២០១៥ ប្រតិចារឹក--

**ប្រធានអង្គជំនុំ៖**

លោកៗមេធាវី យើងបានបញ្ជាក់ហើយអំមិញ។ លោក កាលណាលោកចង់ដកស្រង់នូវខ្លឹមសារនៃប្រតិចារឹក ឬក៏កំណត់ហេតុស្តាប់សក្ខីកម្មសាក្សីណាមួយ គឺលោកត្រូវសួរអំពីសារធាតុបើកទូលាយសំណួរទូទៅចំពោះសាក្សីនេះ តើគាត់ដឹងបញ្ហានេះដែរឬទេ? ហើយបើសិនបើគាត់ឆ្លើយបញ្ជាក់អំពីហេតុការណ៍ដែលពាក់ព័ន្ធនឹងចំណុចដែលលោកដកស្រង់យកមកពីប្រតិចារឹកផ្សេងនេះរួចអស់ហើយ រាល់នូវហេតុការណ៍ដែលពាក់ព័ន្ធនុំងហើយ ហើយបើសាក្សីនុំងគាត់ឆ្លើយយ៉ាងម៉េចនោះ គឺអាស្រ័យលើលទ្ធផលនៃចម្លើយរបស់គាត់ ទើបលោកអាចប្រាប់អ៊ីចឹងបាន។ ការធ្វើដូច្នេះ គឺវានឹងមិននាំឲ្យអាចមានឥទ្ធិពល ឬក៏វាខិតជិតទៅនឹងដឹកមុខទេ សំណួរនាំមុខទេ។ ដកស្រង់នូវអ្វីដែលវាមានប្រយោជន៍ហើយ ប៉ុន្តែអត់សួរអីទូទៅទេ សួរទៅជានាំមុខ ឲ្យសាក្សីគាំទ្រនូវអ្វីដែលលោកដកស្រង់។ យើងបានរំឭកហើយអំមិញ យើងរំឭកចំណុចនេះ ច្បាស់លាស់ណាស់។

[១០:៣៦:០៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ហេតុផលដែលខ្ញុំសំអាងទៅលើប្រតិចារឹកនេះ លោកប្រធាន ដោយសារខ្ញុំយល់ឃើញថា មុនពេលឈប់សម្រាក សាក្សីបានឆ្លើយរួចមកហើយ ថាគាត់មិនបានចាំអំពីបរិបទនៃសេចក្តីសម្រេចនេះទេ។ ដូច្នេះសំណួរបើកចំហនោះ គឺសួរឆ្លើយតែម្តង។ អ៊ីចឹងឯងបានជាខ្ញុំយកប្រតិចារឹកដែលជាភ័ស្តុតាងមកពីអង្គជំនុំជម្រះតុលាការកំពូល។ ខ្ញុំក៏អនុវត្តតាមនីតិវិធីដែលលោកប្រធាន ទើបតែបង្គាប់អម្បាញ់-មិញ។ ដូច្នេះបើមិនជាយល់ទាស់អ្វីទេ ខ្ញុំសូមការអនុញ្ញាតអានសម្រង់មួយឲ្យសាក្សីស្តាប់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នេះជាប្រតិចារឹករបស់តុលាការកំពូល តាមដែលខ្ញុំយល់ គឺថាមិនអាច*អាប់ឡូដ*យកមកដាក់លើ*អ៊ីនធើហ្វេស*បានទេ។ គឺជាសវនាការនៅថ្ងៃទី០២ ខែកក្កដា ២០១៥ ឯកសារ F1/1.1។ សាក្សីរូបនោះ គឺឈ្មោះ សៅ វ៉ាន់ ដែលយើងបានសួរកាលពីពីរថ្ងៃកន្លងទៅ ហើយគាត់ក៏បានដកខ្លួនមិនធ្វើជាសាក្សីនៅចំពោះអង្គជំនុំជម្រះសាលាដំបូងទេ។ លោកស្រីសាក្សី ខ្ញុំសូមអាននូវអ្វីដែលសាក្សីរូបនេះ បានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ នៅម៉ោង១១:០៤នាទី នៅថ្ងៃនោះសាក្សីរូបនេះ បាននិយាយអំពីកិច្ចប្រជុំមួយដែលធ្វើឡើងនៅក្រុងតាកែវ ហើយគាត់បានឆ្លើយថា៖ "មានអង្គប្រជុំមួយដែលកម្មាភិបាលទាំងអស់ ក៏ដូចជាកងទ័ពនៅភូមិភាគនិរតីមកចូលរួមទាំងអស់"។ ហើយគាត់បានឆ្លើយថា

ប្រហែលជាម៉ោង ១០:២៨ គាត់បានឆ្លើយដូចតទៅ៖ "ខ្ញុំចាំច្បាស់ណាស់ ថាចាប់ពីកូនទាហានរហូតដល់វរសេនីយ៍ឯក ស័ក្តិ៥ គឺថាមិនត្រូវប៉ះពាល់ពួកគេទេ។ នេះតាមដែលខ្ញុំចងចាំពីអង្គប្រជុំនោះមក"។ ហើយក្រោយមកគាត់ក៏បានឆ្លើយបន្តទៅទៀត នេះគឺនៅម៉ោង ១០:២១ គាត់បានឆ្លើយថា៖ "នៅពេល តាម៉ុក ឡើងនិយាយនៅក្នុងអង្គប្រជុំនោះ មិនត្រឹមតែ តាម៉ុក ទេដែលបានឡើងនិយាយ មាន តាសោម ផងដែរ"។ ហើយគាត់បានឆ្លើយដូចតទៅ៖ "ប៉ុន្តែបីខែក្រោយពេលរំដោះ តាសោម បានហៅកម្មាភិបាលពាក់ព័ន្ធទាំងអស់នៅតំបន់១៣ ដើម្បីផ្តល់យោបល់ និងប្រាប់ទៅកងទ័ពទាំងអស់ថា ទាហាន ពីកូនទាហានរហូតទៅដល់វរសេនីយ៍ឯក មិនត្រូវប៉ះពាល់ពួកគេទេ។ ដោយសារតែទាហានទាំងអស់នោះដែលមានគ្រួសារសាច់ញាតិរបស់គេរស់នៅក្នុងរំដោះ ហើយគេបានចូលរួមរំដោះជាមួយយើងផងដែរ។ ដោយសារតែហេតុផលទាំងនេះ ពួកគេទាំងអស់នោះ មិនត្រូវប៉ះពាល់ពួកគេទេ"។ លោកស្រីសាក្សី ការហាមឃាត់មិនឲ្យប៉ះពាល់ទៅដល់ទាហានទាំងអស់នេះ តើលោកស្រីនៅចាំថា មានហេតុផលបែបនេះបញ្ជាក់នៅក្នុងអង្គប្រជុំនោះទេ?

[១០:៤០:២៣]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំអាចលើកបញ្ហានេះ តាមសំណួរដែលបានលើក។ ខ្ញុំបានប្រជុំនៅតាកែវនេះ បានប្រជុំដូចតាម៉ុក បានលើក។ អ៊ីចឹងការចងចាំរបស់ខ្ញុំវាអាចនៅសល់ នៅមានចាំខ្លះ អត់ខ្លះ។ តែតាមគម្រោងរបស់ការប្រជុំ ឬក៏តាមផែនការ គឺមិនឲ្យប៉ះពាល់ ដូចបានលើកក្នុងឯកសារ។ អ៊ីចឹងការចាំរបស់ខ្ញុំវាមិនអាចទាំងអស់ទេ ប៉ុន្តែខ្ញុំអាចចាំខ្លះ វាអាចមិនចាំខ្លះ។ អ៊ីចឹងការលើករបស់ តាម៉ុក របស់ – ប៉ុន្តែបើ តាម៉ុក, តាសោម ហ្នឹង ខ្ញុំសូមឯកភាពដែរ ព្រោះក្នុងហ្នឹងខ្ញុំបានទៅប្រជុំដែរ។ អ៊ីចឹងគម្រោងទាំងអស់ខ្ញុំឯកភាព។ សូមអស់។

**ស៖** សូមអរគុណលោកស្រីសាក្សី។ ឥឡូវនេះខ្ញុំសូមចូលនិយាយអំពីជនជាតិចាម។ កាលពីម្សិលមិញលោកស្រីបាននិយាយអំពីជនជាតិចាម ទាក់ទងទៅនឹងការអនុវត្តការរៀបការនៅក្នុងតំបន់របស់លោកស្រី លោកស្រីបានឆ្លើយថា ជាការពិតហើយ ចាមអាចរៀបការជាមួយនឹងខ្មែរបាន ប្រសិនណាបើសិនជាពួកគេស្រឡាញ់គ្នា។ លោកនៅចាំ លោកស្រីនៅចាំថាលោកស្រីបានឆ្លើយយ៉ាងដូច្នេះទេកាលពីម្សិលមិញ?

**ឆ៖** ចាំ។ តាមចម្លើយខ្ញុំឆ្លើយម្សិលមិញ គឺការរៀបចំការចាមជាមួយខ្មែរ គឺខ្ញុំនៅចាំតើ។ វាការ

ជាមួយគ្នាបាន។

**ស៖** តើលោកស្រីមានឧទាហរណ៍ណាមួយ យកមកបញ្ជាក់អំពីការរៀបការខ្មែរនិងចាមនៅក្នុងតំបន់៣៥ ខេត្តកំពត? អ៊ីចឹងលោកស្រីនៅចាំទេ ថាមានចាមរៀបការជាមួយចាម ចាមរៀបការជាមួយខ្មែរ ជាឧទាហរណ៍ណាមួយនៅក្នុងតំបន់របស់លោកស្រី តំបន់៣៥ កំពតនោះដែរទេ?

[១០:៤៣:៤០]

**ឆ៖** ចាមការជាមួយខ្មែរ នៅកំពត មានពីរគូដែរតើ ខ្ញុំការឲ្យ។ ការហើយក៏អត់មានបញ្ហាដែរនៅជាប់ទាល់ថ្ងៃនេះ ខ្ញុំនៅតំបន់៣៥ អត់មានបែកបាក់គ្នាទេ គឺសាមគ្គីគ្នាបានល្អ ខ្ញុំបានការឲ្យហើយ។ សូមចប់ប៉ុណ្ណឹង។

**ស៖** ដូច្នេះនៅពេលលោកស្រីនៅឯខេត្តកំពត ឆ្នាំ១៩៧៥ ដល់៧៦ អាជ្ញាធរមូលដ្ឋានគឺថាមិនមានបញ្ហាអ្វីទេ បើសិនណាជាមានការរៀបការជនជាតិចាមបែបនេះ។ អ៊ីចឹងឬ?

**ឆ៖** នៅខេត្តកំពតអត់មានបញ្ហាអីទេ ព្រោះយើងរៀបរយតាមការស្ម័គ្រចិត្តទាំងសងខាង។ ចាមក៏យើងមិនរើស ខ្មែរក៏យើងមិនរើស។ ហើយក្នុងហ្នឹងគឺបានខាងខ្ញុំ គឺអត់មានបញ្ហាទេ គឺឯកភាពជាមួយប្រជាពលរដ្ឋដែលយើងត្រូវគ្នា។ ខ្ញុំអត់មានជំទាស់ទេ។

**ស៖** ខ្ញុំយល់ហើយ ប្រហែលជាសំណួរខ្ញុំមិនច្បាស់ហើយមើលទៅ។ តើវាមិនបញ្ហាអ្វីទេឬចំពោះជនជាតិចាមដែលរស់នៅក្នុងខេត្តកំពត? តើជនជាតិចាមនៅទីនោះ ត្រូវបានគេប្រព្រឹត្តមកលើពួកគាត់ហ្នឹងដូចខ្មែរដែរទេ? តើមានការរើសអើងណាមួយដែរទេ មានការរើសអើងដោយសារតែពួកគាត់ជាជនជាតិចាមដែរទេ?

**ឆ៖** តាមខ្ញុំមើល នៅខេត្តកំពតចាមច្រើន។ ហេតុនេះក៏អត់មានការរើសអើងអីទេ ព្រោះគាត់រស់នៅ គាត់ ចុះប្រជាជនចាម គាត់នៅផ្សេង គាត់មិន ដូចថានៅកំពត ខេត្តកំពត គឺចាមច្រើនតែម្តង។ អ៊ីចឹងដូចថាគាត់នៅកន្លែងគាត់ ប្រជាជនចាមផ្សេងទៅ ប្រជាជនខ្មែរគាត់នៅផ្សេងទៅ។ អត់មានទំនាស់អីគ្នាទេ ព្រោះគាត់នៅតាមជនជាតិ ជាប់សាសនាគាត់។ តាមខ្ញុំមើល អត់មានទំនាស់អីជាមួយយើងទេ។ ខ្ញុំមានមតិប៉ុណ្ណឹង។

[១០:៤៦:៤៦]

**ស៖** ដូច្នេះបើសិនណាជាគេមិនមានបំណងទម្លាក់រដ្ឋាភិបាល បង្រួបបង្រួមរដ្ឋាភិបាលនោះទេ គឺថា ឬក៏ប្រឆាំងបដិវត្តន៍ទេ ចាមទាំងអស់នោះ មិនត្រូវគេធ្វើទុក្ខបុកម្នេញអីទេ។ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយ! លោកស្រីមិនទាន់បានឆ្លើយនូវសំណួរនេះទេ។ អំមិញឆ្លើយ ក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការណ៍។

**លោកស្រី ប្រាក់ យុត៖**

សំណួរមួយណា ខ្ញុំច្រឡំ។

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ តាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីទៀត សាថ្មីឡើងវិញ សាក្សីភ្លេចសំណួរហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនជាអ្វីទេ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី តើត្រឹមត្រូវដែរឬអត់ទេ ដែលថាបើជនជាតិចាមដែលរស់នៅក្នុងតំបន់របស់លោកស្រី នៅក្នុងខេត្តកំពត មិនប្រឆាំងនឹងបដិវត្តន៍ ឬក៏មិនមានបំណងផ្តួលរំលំបដិវត្តន៍ទេ តើនោះពួកគេ គឺថាមិនត្រូវបានធ្វើ គេធ្វើឲ្យប៉ះពាល់ដោយប្រការណាមួយទេ។ អ៊ីចឹងឬក៏អត់ទេ?

[១០:៤៨:២៥]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ចាស។ បើជនជាតិចាមទាំងអស់នៅក្នុង នៅតាមឃុំ តាមស្រុកនៅខេត្តកំពត បើអត់មានធ្វើអីឲ្យប៉ះពាល់ដល់យើង ប៉ះពាល់ដល់បដិវត្តន៍ គឺអត់មានអីដែល មានអីដែលធ្វើឲ្យមានការលំបាកទេ គឺគាត់មានការរស់នៅស្រួល រស់នៅស្រួលតែម្តង។ អត់មានយើងធ្វើបាប ធ្វើទុក្ខអីគាត់ទេ ព្រោះគាត់ការរស់នៅរបស់គាត់គឺស្រួល អត់មានប្រឆាំងអីជាមួយយើងទេ។ នេះសូមបញ្ចប់ប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកស្រីសាក្សី។ ឥឡូវខ្ញុំនិយាយអំពីកិច្ចប្រជុំនៅថ្ងៃទី២០ ឧសភា ១៩៧៥។ កាលពីម្សិលមិញ នៅនាទីចុងក្រោយ ក្នុងការឆ្លើយតបទៅនឹងសំណួររបស់លោកប្រធាន នៅម៉ោង ១៦:០០ គឺថាលោកស្រីហាក់បីដូចជាចាំច្បាស់លាស់ថា នៅក្នុងកិច្ចប្រជុំនុំង មិនមានការនិយាយអំពីគោលនយោបាយណាមួយពាក់ព័ន្ធនឹងជនជាតិចាមទេ។ លោកស្រីបានឆ្លើយថា មិនមានផែនការតឹងរ៉ឹងពាក់ព័ន្ធទៅនឹងជនជាតិចាមនោះទេ តាមដែលខ្ញុំចាំ។ ហើយពីមុននោះ លោកស្រីមិនមានការចងចាំអំពីការ

ប្រព្រឹត្តមកលើអតីតទាហាន លន់ នល់ ទេ។ ប៉ុន្តែត្រង់ចំណុចនេះ លោកស្រីហាក់បីដូចជាចាំច្បាស់។ សំណួរនេះជាសំណួរមួយដែលពិបាក ប៉ុន្តែតើលោកស្រីអាចពន្យល់ជូនអង្គជំនុំជម្រះបានទេ ហេតុអ្វីបានជាលោកស្រីថា លោកស្រីចាំច្បាស់ណាស់គោលនយោបាយពាក់ព័ន្ធទៅនឹងជនជាតិចាម តែគោលនយោបាយពាក់ព័ន្ធទៅនឹងអតីតទាហាន លន់ នល់ លោកស្រីចាំមិនច្បាស់ទេ?

[១០:៥០:៣៤]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមទោសដែលជំទាស់សាជាថ្មី ប៉ុន្តែមេធាវីការពារក្ដីកំពុងទេបញ្ចូកពាក្យពេចន៍នេះចូលទៅក្នុងមាត់សាក្សីហើយ កំពុងតែសួរនាំមុខសាក្សី ថាកន្លែងដែលគាត់ចាំច្បាស់ កន្លែងណាដែលគាត់ចាំមិនច្បាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនជាថ្មីទេ។ សូមអរគុណលោកសហព្រះរាជអាជ្ញារង ដែលបានមករំខានខ្ញុំជាថ្មីម្ដងទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ពីម្សិលមិញលោកស្រីបានឆ្លើយអំពីគោលនយោបាយពាក់ព័ន្ធនឹងជនជាតិចាមគឺ -- ហើយគោលនយោបាយនេះមិនបានលើកយកមកនិយាយម្ដងទៀតនៅកិច្ចប្រជុំថ្ងៃទី២០ ឧសភា ១៩៧៥ នៅភ្នំពេញនោះទេ។ ឥឡូវខ្ញុំសួរសំណួរជាដំបូងសិន លោកស្រី តើលោកស្រីចាំច្បាស់ពិតប្រាកដអំពីចំណុចនេះទេ? សូមលោកស្រីជួយពន្យល់ឲ្យបានលម្អិតបន្តិចត្រង់ចំណុចនេះ។

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** សួរមួយទៀត ចំណុចណាមួយ?

**ស៖** ពីម្សិលមិញលោកស្រីបានឆ្លើយ មិនមានផែនការតឹងរ៉ឹងពាក់ព័ន្ធទៅនឹងជនជាតិចាម ដែលត្រូវបានលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំថ្ងៃទី២០ ឧសភា ១៩៧៥ នៅភ្នំពេញនោះទេ។ តើលោកស្រីច្បាស់ថា គេមិនបានយកបញ្ហានេះមកពិភាក្សាក្នុងកិច្ចប្រជុំនោះមែនឬ?

[១០:៥២:២៤]

**ឆ៖** ក្នុងការពិភាក្សានៅភ្នំពេញ ៧៥ ការប្រជុំនេះ តាមខ្ញុំដឹងដូចជាមិនមានលើកគោលការណ៍តឹងតែងទេ ព្រោះយើងទើបរំដោះថ្មី អាហ្នឹងអ៊ីចឹង។ ហើយអ៊ីចឹងការដាក់ផែនការ ឬក៏គោលការណ៍នេះទៅក្រោមអត់ទាន់ៗតឹងតែងទេ ព្រោះ៧៥ ពួកខ្ញុំមករៀន គឺរំដោះថ្មី។ អ៊ីចឹងគោលការណ៍ហ្នឹងអត់ទាន់

មានផង ហើយអត់ទាន់ដាក់ទៀត តាមខ្ញុំចាំ។ ចំពោះចាម ចំពោះអតីតទាំងអស់ ដែលបានជម្លៀសទៅក្រៅៗហ្នឹង គឺអត់ទាន់បានលើកជាគោលការណ៍នៅឡើយទេ។ ប៉ុន្តែខ្ញុំសូមជម្រាបអ៊ីចឹង ក្រែងលោខាងសាក្សីណាមាន អាហ្នឹងក៏ខ្ញុំមិនដឹងដែរ។ ប៉ុន្តែចំពោះខ្ញុំ ខ្ញុំបានទៅរៀនដែរ តែគោលការណ៍ចំពោះអតីតៗ ចាម អតីតទាហាន គឺអត់ទាន់បានលើកគោលការណ៍ទេ។ នេះតាមខ្ញុំចាំរបស់ខ្ញុំហ្នឹង ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**ស៖** ប៉ុន្តែសំណួររបស់ខ្ញុំ ថាតើលោកស្រីអាចពន្យល់បានទេថាហេតុអ្វីបានលោកស្រីច្បាស់ម្លេះចំណុចនេះ? ហើយហេតុអ្វីបានជាលោកស្រីមិនចាំគោលនយោបាយពាក់ព័ន្ធទៅនឹងអតីតទាហាន លន់ នល់ ដែលថា គេមិនបានយកមកពិភាក្សានៅក្នុងកិច្ចប្រជុំថ្ងៃទី២០ ឧសភា ១៩៧៥នោះ?

**ឆ៖** ថាចាំមិនច្បាស់។ ខ្ញុំច្បាស់ ប៉ុន្តែគោលការណ៍អត់មាន ឲ្យខ្ញុំលើកពន្យល់នៅអង្គប្រជុំមិនកើតដែរ ព្រោះខ្ញុំ បើសិនជាមានគោលការណ៍របស់ខាងលើប្រាប់ខ្ញុំមក ណែនាំខ្ញុំ ខ្ញុំនៅចាំហើយ។ តែបើអត់មានផង ហើយគ្រាន់តែពេលប្រជុំហ្នឹង អត់បានលើក ហើយខ្ញុំយកមកពន្យល់នៅអង្គប្រជុំម៉េចកើតទៀត បើគោលការណ៍ហ្នឹងអត់ទាន់លើកបញ្ហាជាគោលការណ៍ ចំពោះអតីត ចំពោះចាមហ្នឹងឲ្យ លើកមកឲ្យខ្ញុំដឹង គឺខ្ញុំអត់បាន។ អត់ដឹង ខ្ញុំនិយាយក៏កើតដែរ។ តែគ្រាន់ថាខ្ញុំៗចាំ ការលើកក្នុងអង្គប្រជុំហ្នឹងតែដល់ការលើក មិនដឹងលើកជាគោលការណ៍អីខ្លះ។ តែចំពោះចាម ចំពោះអតីតហ្នឹង អត់ទាន់បានលើកទេ។ នេះខ្ញុំសូមជម្រាប។ តែបើមានសំណួរដែលក្រៅពីខ្ញុំឆ្លើយនេះ សុំឲ្យលោកលើកសួរបន្ត។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

[១០:៥៥:៣៦]

**ស៖** វាច្បាស់លាស់ហើយចំណុចនេះ លោកស្រីសាក្សី។ សូមអរគុណច្រើន។ ប៉ុន្តែខ្ញុំនៅសួរសំណួរពាក់ព័ន្ធនឹងប្រធានបទនេះដដែលសិន ខ្ញុំចង់សួរលោកស្រី ថាតើលោកស្រីនៅចាំថា លោកស្រីធ្លាប់បានអានទស្សនាវដ្តីទង់បដិវត្តដែលបានចេញផ្សាយប្រចាំខែ ពាក់ព័ន្ធទៅនឹងគោលនយោបាយចំពោះជនជាតិចាមដែរទេ? លោកស្រីធ្លាប់បានអានទេ?

**ឆ៖** ខ្ញុំសូមជម្រាប ការអានទង់ទស្សនាវដ្តីវាច្រើនមុខណ៎ា។ ហើយការអានមិនដឹងថា ចំរបស់ចាម ឬក៏ចំរបស់ទង់អី ក៏ខ្ញុំមិនចាំបានដែរ ព្រោះខ្ញុំវាអានៗច្រើន។ តែការចាំ វាអត់ចាំ មិនដឹងទង់ណាមួយ ដែលទង់ណាមួយគឺ មកដល់ថ្ងៃនេះ ខ្ញុំមិនបានចាប់អារម្មណ៍ទុក ថាទង់ហ្នឹងគេនិយាយពីអីៗទេ។ ខ្ញុំអត់ចាំដែរ។

**ស៖** ខ្ញុំយល់ លោកស្រី។ ខ្ញុំរៀបសំណួរឡើងវិញទៅចុះ។ តើពិតទេថា មិនមានការនិយាយអំពីគោលនយោបាយពិសេស ពាក់ព័ន្ធទៅនឹងជនជាតិចាមនៅក្នុងៗទស្សនាវដ្តីណាមួយទេ អ៊ីចឹងឬ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១០:៥៧:៣៩]

**លោក ឌេល លីសាក់៖**

មេធាវីការពារក្តីកំពុងសួរនាំមុខសាក្សីទៀតហើយ។ សាក្សីឆ្លើយថា មិនដឹងទេ។ ឥឡូវនេះគាត់យកមកសួរនាំមុខ ដោយមិនមានអ្វីយកមកសំអាង ឬក៏មិនមានឯកសារយោងឡើយ។ នេះជាការសួរនាំមុខសាក្សីហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់តែសួរសំណួរបើកទេ លោកប្រធាន។ ដោយសារពេលស្តាប់ចម្លើយរបស់គាត់មក ខ្ញុំក៏រៀបចំសំណួរសួរទៅគាត់ ដែលសួរថា តើវាពិតមែនទេដែលថា មិនមានគោលនយោបាយណាមួយពាក់ព័ន្ធទៅនឹងជនជាតិចាម លើកយកមកសរសេរនៅក្នុងឯកសារទង់បដិវត្តទេ? ដូច្នេះខ្ញុំយល់ឃើញថា ខ្ញុំមានសិទ្ធិសួរបែបនេះបាន។

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះគឺពិតជាសំណួរនាំមុខ។ អង្គជំនុំជម្រះបដិសេធ -- ទទួលយកនូវសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ ហើយសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរបែបនេះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះខ្ញុំបន្តទៅមុខទៀត។ លោកស្រីសាក្សី នៅពេលដែលលោកស្រីធ្វើជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាពី៧៥ទៅដល់៧៩ តើលោកស្រីធ្លាប់បានស្តាប់ឮតាមការផ្សាយវិទ្យុពីភ្នំពេញ ផ្សាយពាក់ព័ន្ធទៅនឹងគោលនយោបាយណាមួយដែលពាក់ព័ន្ធទៅនឹងជនជាតិចាមដែរទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសុំសំណួរហ្នឹងម្តងទៀត។ ខ្ញុំដូចស្តាប់មិនសូវយល់។

[១០:៥៩:៤៦]

**ស៖** អ៊ីចឹងខ្ញុំសូមសួរអ៊ីចេះសិន តើលោកស្រីធ្លាប់ដែលបានស្តាប់ការផ្សាយចេញពីវិទ្យុផ្សាយសំឡេងទីក្រុងភ្នំពេញ ចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩ដែរទេ?

**ឆ៖** ខ្ញុំសូមអត្ថាធិប្បាយបន្តិចចុះ។ ការផ្សព្វផ្សាយពី៧៥មក៧៩ ខ្ញុំសូមជម្រាបថា ការផ្សព្វ-ផ្សាយ ការចងចាំរបស់ខ្ញុំ មិនដឹងថា ភ្លេច ឬក៏នៅចាំ។ ហេតុនេះ វាមានការផ្សាយ មានផ្សព្វផ្សាយមួយចំនួន ឬក៏មិនបានផ្សព្វផ្សាយ ខ្ញុំវាអត់ចាំទាំងអស់ដែរ។ ព្រោះតាំងពី៧៥ មកដល់៧៩ ប្រហែលជាមានការផ្សព្វផ្សាយ ឬក៏អត់បានផ្សព្វផ្សាយ ខ្ញុំវាអត់ច្បាស់លាស់។ ខ្ញុំសូមជម្រាបអ៊ីចឹង។ ឥឡូវខ្ញុំថាផ្សព្វផ្សាយទៅ ក្រែងលោថាមិនបានផ្សព្វផ្សាយ។ អ៊ីចឹងខ្ញុំសូមនិយាយខ្លីប៉ុណ្ណឹង ថាខ្ញុំចាំមិនបាន។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី។ ដឹងថារយៈពេលនោះវាយូរហើយ ជិត៤០ឆ្នាំកន្លងមកហើយ មិនបញ្ហាអ្វីទេ។ ឥឡូវខ្ញុំសូមបន្តចូលទៅសំណួរផ្សេងទៀត។ តើត្រឹមត្រូវដែរឬអត់ទេ ដែលថានៅពេលណាមួយនោះ ក្នុងឆ្នាំ១៩៧៦ លោកស្រីរួមទាំងប្តីរបស់លោកស្រីផង ត្រូវបានជ្រើសតាំងឲ្យធ្វើជាសមាជិកតំណាងរាស្ត្រ តើត្រឹមត្រូវដែរឬអត់ទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** តើលោកស្រីត្រូវបានបោះឆ្នោតជ្រើសតាំងឲ្យធ្វើជាតំណាងរាស្ត្រ តំណាងឲ្យខេត្តកំពតឬ?

[១១:០២:២៤]

**ឆ៖** ចាស ខ្ញុំធ្វើនៅខេត្តកំពត កាលនោះអត់បានបោះឆ្នោតទេ។ គ្រាន់ថាមានសេចក្តីប្រកាសនៅតាមៗតំបន់ នៅតាមអី -- តាមតំបន់ តាមស្រុកអ៊ីចឹង។ ឧទាហរណ៍ តាចាប គាត់ដឹងបញ្ហាហ្នឹងហើយគាត់ក៏ឲ្យនីរសារអីទៅប្រាប់ខ្ញុំថា ហៅខ្ញុំទៅជួបគាត់ ព្រោះគេចាត់តាំង អើ! គេរៀបរយខាងតំណាងរាស្ត្រ។ តែការនិយាយរបស់ខ្ញុំនេះ ប្រហែលខុសសំណួរមុនទៀត។ នេះខ្ញុំតាមខ្ញុំដឹង។ អ៊ីចឹងខ្ញុំនិយាយទៅវា សំណួរមុនហើយនិងសំណួរឥឡូវខុសគ្នា។ កាលនោះខ្ញុំមិនបានដឹងទេ គឺថាគ្រាន់តែខាងលើហៅទៅជួប ខ្ញុំធ្វើតំណាងរាស្ត្រមែនជាមួយគ្រួសារខ្ញុំ។ តែការធ្វើនេះ ខ្ញុំក៏មិនបានចេះអីឲ្យជ្រៅជ្រះអីតំណាងរាស្ត្រអីក៏មិនច្បាស់លាស់ គ្រាន់តែធ្វើនៅក្នុងភូមិឃុំស្រុកតំបន់ខ្លួនឯងហ្នឹង។ ហ្នឹងសូមជម្រាបខ្ញុំបានធ្វើមែន ពិតប្រាកដ។

**ស៖** មុនពេលដែលខ្ញុំបន្តទៅសំណួរដែលខ្ញុំចង់សួរបន្ថែមទៀតនេះ ឥឡូវនេះខ្ញុំបន្តនៅលើប្រធានបទនេះបន្តិចសិន។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺអង់គ្លេសមានលេខ គឺទំព័រ 01062429, ខ្មែរមាន 00963148 និងបារាំងមានលេខ 0015025 *(ស៊ីក)*។ អ្នកស្រី

បានឆ្លើយដូចតទៅនេះ៖ "ខ្ញុំគិតថា ខ្ញុំស្គាល់មេថ្នាក់លើទាំងអស់ ពួកគេក៏ស្គាល់ខ្ញុំដែរ។ សូម្បីតែឥឡូវហ្នឹងគ្រប់គ្នាស្គាល់ខ្ញុំដែរ។ ខ្ញុំឈ្មោះ ប្រាក់ យុត។ ខ្ញុំស្គាល់ពួកគាត់ទាំងអស់។ ដូច្នេះគេគិតថា ខ្ញុំជាអ្នកនយោបាយជាន់ខ្ពស់។ ទោះបីថាខ្ញុំជាស្ត្រីក៏ដោយ ខ្ញុំជាអ្នកនយោបាយ។ ឧទាហរណ៍ មេទាំងពីរនាក់ហើយនិងកូនចៅរបស់គាត់គិតថា ខ្ញុំជាអ្នកនយោបាយដ៏លេចធ្លោ។" តើអ្នកស្រីមានន័យយ៉ាងម៉េចនៅពេលដែលអ្នកស្រីប្រាប់អ្នកស៊ើបអង្កេតថាអ្នកស្រីជាអ្នកនយោបាយដ៏លេចធ្លោនោះ?

[១១:០៥:២៣]

**ឆ៖** ខ្ញុំសូមជម្រាបបញ្ហាហ្នឹងដែរ មិនមែនថាខ្ញុំយកថាអួតអាងទេ កាលនោះខ្ញុំនិយាយជាមួយសាក្សី -- អ៎ូ! ខ្ញុំនិយាយជាមួយអ្នកស៊ើបអង្កេតមែន។ តែខ្ញុំនិយាយក្នុងភូមិឃុំ ដូចថា ខ្ញុំហ្នឹងពូកែឃោសនា ពូកែធ្វើមិទ្ទីង អីតាមប្រជាជនអីចឹងទៅ ខ្ញុំ។ ដល់ហើយប្រជាជនគាត់ថាឲ្យខ្ញុំថា "យាយហ្នឹងបើនិយាយពីនយោបាយវិញ ខ្ពស់តែម្តង"។ ហើយខ្ញុំចេះតែយកមតិហ្នឹង និយាយទុករហូតដល់ឥឡូវនេះ។ ហើយអីចឹងដល់ពេលខ្ញុំសម្ភាស ខ្ញុំយកមកនិយាយជាមួយអ្នកសម្ភាសដែរ។ តែបើកាលណា អើខ្ញុំមិនមែនថាយកនយោបាយខ្ពស់ដើម្បីខ្ញុំដឹកនាំប្រទេសទេ តែខ្ញុំចង់និយាយពីរឿងនោះ នៅតាមភូមិ ខ្ញុំបានឃោសនាបានធ្វើមិទ្ទីងអីចឹង ដូចជានៅកំពង់ចាមក៏អីចឹង នៅស្រុកឈូកក៏អីចឹង។ ខ្ញុំបានធ្វើមិទ្ទីងតាមភូមិ តាមឃុំអីចឹង គាត់តែងតែនិយាយ គាត់ថា "យាយហ្នឹងពូកែតែម្តងរឿងនិយាយ នយោបាយខ្ពស់ណាស់"។ តែមិនមែនថាចំពោះខ្លួនខ្ញុំហ្នឹង ទៅនិយាយលើការដឹកនាំកំពូលទេ ខ្ញុំសូមជម្រាបឲ្យច្បាស់លាស់បញ្ហានេះ ព្រោះខ្ញុំបានលើកសំណួរមក ខ្ញុំត្រេកអរណាស់នេះ ខ្លាចតែយកខ្ញុំទៅដាក់កំពូលតែការពិតខ្ញុំនិយាយពាក្យសាមញ្ញទេ ប៉ុន្តែដល់ខ្ញុំសម្ភាសទៅវានិយាយថា "ហ៊ឺស! យាយហ្នឹងពូកែណាស់នយោបាយកំពូល"។ "កំពូល" ចង់និយាយថា ការឃោសនា ការអប់រំនៅតាមមូលដ្ឋាន។ នេះខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ កុំឲ្យភ័ន្តច្រឡំថាខ្ញុំអ្នកដឹកនាំកំពូលអីគឺអត់ទេ។ អានេះខ្ញុំសូមជម្រាបត្រង់។

**សៈ** ក្នុងនាមជាអ្នកនយោបាយ ឬក៏អ្នកស្រីប្រើពាក្យអ្នកស្រីថា "អ្នកនយោបាយជើងឆើតនោះ" តើអ្នកស្រីដឹងទេថាមានអ្នកណាម្នាក់ដែលជាសមាជិកសភាផងដែរ ហើយជាអ្នកតំណាងខេត្តកំពង់ចាម ហើយគាត់ជាជនជាតិចាម គាត់ឈ្មោះ ម៉ាត់ លី តើអ្នកស្រីស្គាល់គាត់ទេ?

[១១:០៧:៣៤]

**ឆ៖** អ្នកជើងឆើតអី ឈ្មោះ លី ឈ្មោះអីហ្នឹងមិនបានស្គាល់ទេ។ ខ្ញុំមិនបានស្គាល់គាត់ទេ ព្រោះកាលនោះ។

**ស៖** នៅក្នុងកម្ពុជាប្រជាធិបតេយ្យ តើអ្នកស្រីមានស្គាល់អ្នកបដិវត្តន៍ណាម្នាក់ដែលជាជនជាតិចាមដែរឬទេ?

**ឆ៖** ខ្ញុំសូមលើកបញ្ហាហ្នឹង។ ម៉េចបានថាខ្ញុំហ្នឹង លោកស្រីបានស្គាល់ម្នាក់ដែលជនជាតិចាមក្នុងបដិវត្តន៍ ប៉ុន្តែការពិតខ្ញុំសូមជម្រាបថា ខ្ញុំអីស្គាល់ចាមនៅទូទាំងស្រុក ទូទាំងខេត្ត។ ហើយចាមហ្នឹងខ្ញុំសូមលើកថា យ៉ាងម៉េចបានសួរថា ឲ្យខ្ញុំស្គាល់ជនជាតិចាមម្នាក់ហ្នឹង យ៉ាងម៉េច ខ្ញុំចង់ដឹងរឿងហ្នឹង។ សូមអត់ទោស ខ្ញុំអត់ច្បាស់លាស់ដែរ ព្រោះសួរមិនដឹងថាចង់និយាយពីអី ពីរឿងចាមម្នាក់ហ្នឹង។ ខ្ញុំសូមសួរលោកទៅវិញបន្តិចចុះ ខ្ញុំវាអត់ច្បាស់។

**ស៖** ខ្ញុំអាចពន្យល់បាន ប៉ុន្តែដោយសារតែខ្ញុំមិនមានពេល។ អ្វីដែលខ្ញុំចង់សួរអ្នកស្រី គឺថាអ្នកស្រីមិនស្គាល់ ម៉ាត់ លី ទេឬ? ម៉ាត លី ដែលជាអ្នកបដិវត្តន៍ជនជាតិចាមនោះ? ប៉ុន្តែឥឡូវនេះខ្ញុំចង់សួរថាតើអ្នកស្រីស្គាល់ជនជាតិចាមណាម្នាក់ដែលបានចូលបដិវត្តន៍ ហើយជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

[១១:០៩:៣០]

**ឆ៖** ខ្ញុំអត់បានស្គាល់។ ប៉ុន្តែសមាជិកចាមហ្នឹងចូលសមាជិកបក្សកុម្មុយនីស្តកម្ពុជា ខ្ញុំអត់បានស្គាល់ទេ។ ខ្ញុំឆ្លើយ សូមឆ្លើយខ្លីតែម្តង ព្រោះអត់ស្គាល់ឈ្មោះ ហើយក៏អត់ដឹងទៀត។

**ស៖** មិនថ្វីទេ អ្នកស្រី។ ឥឡូវនេះខ្ញុំបន្តទៅប្រធានបទថ្មីមួយទៀត។ នៅក្នុងចម្លើយរបស់អ្នកស្រីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកស្រីបានទទួលស្គាល់ថា អ្នកស្រីស្គាល់ប្រធានតំបន់ឈ្មោះ ស៊ុម -- ឈ្មោះ សោម ហើយនិងម្នាក់ទៀតឈ្មោះ មាស មុត។ តើត្រឹមត្រូវដែរឬទេ? តើអ្នកស្រីពិតជាស្គាល់ឈ្មោះ សោម ហើយនិងឈ្មោះ មុត ហ្នឹងមែនទេ?

**ឆ៖** ស្គាល់ឈ្មោះ សោម ប៉ុន្តែស្លាប់បាត់ហើយ។ មុត ហ្នឹងខ្ញុំស្គាល់ឈ្មោះ សោម ជាងគេ។ តាមុត ហ្នឹងរាល់ថ្ងៃខ្ញុំដឹងថាគាត់នៅកន្លែងណោះ ហើយខ្ញុំមិនដែលបានទាក់ទងគាត់ទេ តាំងពីបែកបាក់គ្នា។ បើ សោម ខ្ញុំស្គាល់ ប៉ុន្តែគាត់ស្លាប់តាំងពី៧៩។

**ស៖** តើអ្នកស្រីចាំអ្វីច្បាស់លាស់អំពីឈ្មោះ សោម នេះ?

**ឆ៖** ប្រវត្តិ តាសោម នេះខ្ញុំចាំអត់អស់ទេ ព្រោះគាត់មិនមែនរស់នៅក្នុងខេត្តកំពត ខេត្តកំពង់ចាមទេ គាត់នៅកំពង់ឆ្នាំង។ ហេតុនេះ ខ្ញុំអត់ចាំប្រវត្តិគាត់ទេ មិនដឹងថា ពូជពង្សសាវតារគាត់នៅកន្លែងណាទេ។ ខ្ញុំអត់ស្គាល់គាត់ទេ។ ស្គាល់តែពេលកាលនៅជាមួយគ្នា តែក្រោយមក មិនដឹងថាប្រវត្តិគាត់

ម៉ែឪគាត់នៅទីណា ខ្ញុំអត់ស្គាល់។

[១១:១១:៤៥]

**ស៖** ចុះលក្ខណៈរបស់គាត់យ៉ាងម៉េចដែរ? គាត់មានចរិតលក្ខណៈកាចសាហាវ ឬក៏ចិត្តអាក្រក់ ឬក៏ដាច់ខាត ម៉ឺងម៉ាត់ជាដើមនុ៎ង? តើអ្នកស្រីអាចប្រាប់បានទេថា អ្នកស្រីចាំថាគាត់មានចរិតលក្ខណៈបែបណាដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំថា សំណួររបស់មេធាវីគឺនាំមុខ ព្រោះថាគាត់នាំមុខសាក្សីដោយលើកថា គាត់ហ្នឹងជាមនុស្សកាចសាហាវ ឃោរឃៅ។ នេះគឺជាមតិរបស់ខ្ញុំ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមានពេលវេលាច្រើនទេ ខ្ញុំគ្រាន់តែសួរថា តើគាត់ចាំយ៉ាងណាអំពីលក្ខណៈ។ ដូច្នេះខ្ញុំគ្រាន់តែលើកអំពីលក្ខណៈមួយចំនួននៃចរិតលក្ខណៈរបស់មនុស្ស។ ហើយខ្ញុំគិតថា វាជាអាចទទួលយកបានដោយមិនមានបញ្ហាអ្វីនោះឡើយ។ ហើយព្រះរាជអាជ្ញា កាលពីម្សិលមិញ ក៏គាត់ធ្វើដូច្នេះដែរ។ ខ្ញុំគិតថា ខ្ញុំគួរតែត្រូវបានការអនុញ្ញាតឲ្យសួរសំណួរបែបនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ្នកស្រីសាក្សី--

[១១:១៣:០១]

**ប្រធានអង្គជំនុំ៖**

លោកៗ វ៉ិចទ័រ កូប៉េ លោកកែសម្រួលសំណួររបស់លោកទៅ។ បើលោកសួរអត្តចរិតលក្ខណៈអ៊ីចឹង លោកគួរតែសួរនូវអត្តចរិតល្អផងដែររបស់ៗគោលដៅដែលលោកសួរហ្នឹង។ បើលោកសួរ គឺសួរតែរឿងអាក្រក់ តែបើចរិតល្អ សុភាពរាបសាហ្នឹង លោកអត់សួរផងហ្នឹង។ អានេះហើយ ដែលនាំឲ្យគេជំទាស់នោះ។ ប្រសិនបើលោកមានចេតនាសួរឲ្យត្រឹមត្រូវ គឺសួរទាំងៗសងខាងទៅ ទាំងគុណវិបត្តិទាំងគុណវិបត្តិដែលវាល្អ ឬអាក្រក់របស់បុគ្គលទៅ បើសិនជាចង់បញ្ជាក់បញ្ហានេះច្បាស់លាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនថ្វីទេ លោកប្រធាន។ ប៉ុន្តែខ្ញុំនឹងសួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី តើ តាសោម ជាមនុស្សសាហាវ ឬក៏មិនសាហាវ ចិត្តល្អ ឬក៏ចិត្តអាក្រក់ មនុស្សដាច់ខាត ឬក៏មនុស្សទន់ភ្លន់ មានហេតុផល?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ចំពោះ សោម នេះខ្ញុំក៏មិនបានស្គាល់អត្តចរិតគាត់ដែរ។ និយាយរួមគុណសម្បត្តិរបស់គាត់ក៏ខ្ញុំមិនចាប់អារម្មណ៍ ការគុណវិបត្តិ ក៏ខ្ញុំអត់បានការចាប់អារម្មណ៍ មកអំពីការកាលគាត់នៅតាកែវ ខ្ញុំនៅខេត្តកំពត។ ហេតុនេះការទាក់ទងគ្នា វាអត់មាន។ អ៊ីចឹងថាឲ្យខ្ញុំឆ្លើយថា អត្តចរិត គុណសម្បត្តិគាត់ល្អ ក៏ខ្ញុំមិនហ៊ានថា គុណវិបត្តិគាត់អាក្រក់ ក៏ខ្ញុំអត់ហ៊ានថាដែរ ព្រោះការរស់នៅតាំងពី៧០ មកទល់៧៥ គាត់នៅតាកែវ ខ្ញុំមិនបានមកជួបគាត់ទេ។ នេះសូមជម្រាប។ អត់មានយក និយាយរួមគឺមិនបានចាប់តាមដានគាត់ច្បាស់លាស់ទេ ព្រោះគាត់នៅតាកែវនេះ ខ្ញុំនៅកំពតនោះ។ វាមិនបានជួបគ្នាគ្រប់ពេល។ អ៊ីចឹងសូមជម្រាបៗប៉ុណ្ណឹង។ ឲ្យខ្ញុំស្គាល់គាត់តែម្តង អត់ស្គាល់ទេអត្តចរិតនោះ។

[១១:១៥:១០]

**ស៖** អរគុណចំពោះចម្លើយរបស់លោកស្រី។ ខ្ញុំនឹងប្រាប់អ្នកស្រី ហេតុអ្វីបានខ្ញុំសួរសំណួរបែបនេះ។ ខ្ញុំផ្តល់លទ្ធផលដល់អ្នកស្រី ប៉ុន្តែមិនអ្វីនោះទេ។ លោកប្រធាន ខ្ញុំនិយាយយោងទៅលើឯកសារ E3/9118 គឺជាកំណត់ហេតុស្តាប់ចម្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺធ្វើឡើងនៅជាមួយនឹង សៅ វ៉ាន់ គឺអង់គ្លេសមានលេខ 01098758 ហើយខ្ញុំមានតែខ្មែរ ERN ទេគឺ 00957789។ នេះគឺជាកម្មាភិបាលភូមិភាគនិរតី និយាយអំពី តាម៉ុក ក្នុងពេលប្រជុំ ហើយគាត់ឆ្លើយថា ខ្ញុំសូមដកស្រង់៖ "ក្នុងពេលប្រជុំ តាម៉ុក មកនិយាយ មកថ្លែងប្រហែលជាកន្លះម៉ោង ហើយគាត់ប្រាប់យើងឲ្យប្រុងប្រយ័ត្ន។ គាត់ក៏បាននិយាយផងដែរថា និយាយប្រាប់ តាសោម ហើយនិង តាមុត លោកគ្រូ សោម និងលោកគ្រូ មុត ប្រជាជននិយាយថា លោកគ្រូទាំងពីរកាចសាហាវណាស់ ដូច្នេះចង់ឲ្យលោកគ្រូទាំងពីរត្រឡប់ទៅវិញ ហើយសុំទោសប្រជាជន។ សំណួរ៖ តើគាត់និយាយអ៊ីចឹងមែនទេ? ចម្លើយ៖ ចាស គឺគាត់និយាយអ៊ីចឹងមែន គឺថា តាម៉ុក ប្រាប់ថាមិនឲ្យធ្វើតាមគ្រូ សោម ហើយនិងគ្រូ មុត ទេ។" អ្នកស្រីសាក្សី តើអ្នកស្រីយល់ឃើញយ៉ាងម៉េចដែរ ចំពោះចម្លើយរបស់ សៅ វ៉ាន់ ដែលគាត់និយាយបែបនេះ?

[១១:១៧:១៤]

**ធៈ** ខ្ញុំមិនដឹងថា ឆ្លើយចំពោះសំណួរលោកស្រី វ៉ាន់ យ៉ាងម៉េច បើការអនុវត្តគឺខ្ញុំ ហើយគាត់ទៅនិយាយថា សួរខ្ញុំអី ខ្ញុំមិនទទួលខុស អ៎! មិនដឹងដែរ។ ហើយឲ្យខ្ញុំថា ពេញចិត្តជាមួយលោកស្រី សៅ វ៉ាន់ ខ្ញុំមិនពេញចិត្តយ៉ាងម៉េច បើខ្ញុំវាអត់ដឹងរឿង។

**ប្រធានអង្គជំនុំ៖**

លោកស្រីឆ្លើយមិនដឹង ឆ្លើយថាមិនដឹងទៅ មិនបាច់និយាយអីច្រើនទេ។ លោកស្រីនឹងនឿយហត់ណាស់ បើសិនជាលោកស្រីឆ្លើយច្រើនដែលហួសពីវិសាលភាពចាំបាច់ក្នុងការឆ្លើយតបនឹងសំណួរ។

**លោកស្រី ប្រាក់ យុត៖**

**ធៈ** ខ្ញុំមិនអាចឆ្លើយបានទេ សំណួរហ្នឹង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតទៅមុខទៀតលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

មិនថ្វីទេ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** [redacted]

[១១:១៩:៣៦]

**ធៈ** [redacted]

**សៈ** [redacted]

**ធៈ** [redacted]

[redacted]

ស៖ [redacted]

ឆ៖ [redacted]

[១១:២១:៤០]

ស៖ [redacted]

ឆ៖ [redacted]

ស៖ [redacted]

[១១:២៣:៤៣]

ឆ៖ [redacted]

[redacted]

**ស៖** [redacted]

**ឆ៖** [redacted]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១១:២៦:០៣]

**លោក ខេល លីសាក់៖**

គាត់កំពុងតែនាំមុខសាក្សី ហើយគាត់បានលើកឡើងនូវសំណួរដែលមានលក្ខណៈជាអង្គច្បាប់។ ដូច្នេះខ្ញុំមិនប្រាកដ ថាតើការជំទាស់នោះ វាយ៉ាងម៉េចនោះទេ ប៉ុន្តែ--

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ប្រសិនបើក្នុងរយៈពេលប៉ុន្មានសិបឆ្នាំហើយនេះ ខ្ញុំនៅតែមិនអាចសួរសំណួរបែបនេះបាន ខ្ញុំមិនដឹងថាយ៉ាងម៉េចទេ។ ប៉ុន្តែខ្ញុំនៅតែរក្សា ឥឡូវនេះខ្ញុំនឹងមិនប្រើប្រាស់ពាក្យ "ក្បត់ជាតិ" ប៉ុន្តែខ្ញុំប្រើប្រាស់ពាក្យផ្សេងមួយទៀតដែល នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានសួរអំពីមូលហេតុនៃការចាប់ គេសួរគាត់ ថាតើគាត់ចោទថា គាត់ក្បត់ដែរឬទេ? ដូច្នេះខ្ញុំនឹងប្រើប្រាស់ពាក្យ ដែលមិនមែនជា

ពាក្យផ្លូវច្បាប់។ ដូច្នេះ ខ្ញុំសួរថាតើការសង្ស័យថា មានទំនាក់ទំនងជាមួយ សេ.អ៊ី.អា គឺជាការក្បត់ប្រទេសដែរឬទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមឆ្លើយ កាលនោះប្រហែលជាថាក្បត់ប្រទេសដឹង បាន តាម៉ុក ហៅខ្ញុំទៅជួប។ បើសិនជាអត់មានប៉ះពាល់ដល់ប្រទេស ប្រហែលជាអត់ហៅខ្ញុំទៅជួប ដើម្បីចាប់ប្ដីខ្ញុំទេ។ អានេះខ្ញុំយល់ក្នុងចិត្តខ្ញុំទេ។ ប្រហែលជាក្បត់ ចូលក្នុងការក្បត់ជាតិដឹង ហើយម៉េច ខ្ញុំមិនបានយល់ដែរ។ ព្រោះមុននឹងចាប់ហ្នឹង មិនបានហៅខ្ញុំទៅបីបួនប្រាំថ្ងៃ ដើម្បីសំណេះសំណាលឲ្យខ្ញុំយល់ពីបញ្ហាហ្នឹងឯណា។ ដល់ជិតចាប់ហើយ បានហៅខ្ញុំទៅភូមិភាគនិរតី ក៏ខ្ញុំចេះតែទៅ វាមិនដឹងថារឿងចាប់ប្ដីហ្នឹងទៀត។ ស្មាន តាម៉ុក គាត់ហៅទៅមានការអីចាំបាច់។ ទៅប្រាប់ថា ចាប់ប្ដីហ្នឹង ខ្ញុំក៏មិននិយាយអី ប៉ុនថាឲ្យ បើសិនជាវាអត់មានប៉ះពាល់ដល់ប្រទេស ប្រហែលជាមិនចាប់ទេ។ អានេះខ្ញុំយល់អ៊ីចឹង ហើយបើប៉ះពាល់ ប្រហែលជាចាប់។ ប៉ុន្តែគេថា សេ.អ៊ី.អាៗ ខ្ញុំក៏មិនយល់ពាក្យហ្នឹងដែរ ខ្ញុំមិនបានយល់ទេ។ ប៉ុន្តែ តាម៉ុក គាត់ប្រាប់ខ្ញុំក៏មិនបាននិយាយថា សេ.អ៊ី.អា អីដែរ។ ប៉ុន្តែខ្ញុំនិយាយ គឺថាបើខ្ញុំឆ្លើយមកថា សេ.អ៊ី.អា បង្កប់។ ខ្ញុំក៏ចេះនិយាយពាក្យហ្នឹង តរហូតទាល់ថ្ងៃនេះ។ នេះសូមជម្រាបដោយការស្មោះត្រង់។

[១១:២៨:៣៦]

**ស៖** ឥឡូវនេះ ខ្ញុំនឹងឈប់និយាយអំពីប្ដីរបស់អ្នកស្រី និងការចាប់ខ្លួនហើយ។ ហើយឥឡូវនេះខ្ញុំទៅចាប់ផ្ដើមនៅពេលដំបូង នៅឆ្នាំ៧៧ ហើយនិងហេតុផលដែលកម្មាភិបាលមកពីនិរតីត្រូវបានបញ្ជូនទៅខាងឧត្តរ។ អ្នកស្រីបានឆ្លើយថា អ្នកស្រីមិនដឹងអំពីហេតុផលដែលកម្មាភិបាលនិរតីត្រូវគេបញ្ជូនទៅឧត្តរនោះទេ។ ដូច្នេះខ្ញុំចង់សួរថា តើអ្នកស្រីធ្លាប់ឮទេ ថាខាងឧត្តរ ឬក៏កម្មាភិបាលខាងឧត្តរត្រូវបានគេសង្ស័យថា មានជាប់ទំនាក់ទំនងជាមួយនឹងអំពើក្បត់ជាតិដែរឬទេ?

**ឆ៖** ខ្ញុំសូមសំណួរនេះ ជំទាស់បន្តិច តើសួរនៅក្នុងភូមិភាគកណ្ដាល ឬក៏សួរនៅក្នុងភូមិឧត្តរ? ព្រោះខ្ញុំវាអត់យល់បញ្ហានេះ ព្រោះឧត្តរវាផ្សេង ភូមិភាគកណ្ដាលផ្សេង ខុសគ្នា ភូមិភាគឧត្តរផ្សេង។ អ៊ីចឹងមិនដឹងថាលោកសួរខ្ញុំហ្នឹង ក្នុងឋានៈភូមិភាគកណ្ដាល ឬក៏ភូមិភាគឧត្តរ?

**ប្រធានអង្គជំនុំ៖**

បាទៗ សួរ សូមសួរបញ្ជាក់ឲ្យបានច្បាស់លាស់ ហើយអំមិញយើងបានមានការជំទាស់ម្ដងហើយការប្រើពាក្យច្បាប់គឺ “ក្បត់ជាតិ” នោះ។ ហើយលោកបានដូររួចហើយនៅសំណួរមុន ឥឡូវហ្នឹង

លោកតាំងសំណួរបែបនេះសាជាថ្មីម្ដងទៀត ហើយពាក្យពេចន៍នេះ គឺកម្រនៅក្នុងឯកសារ មាននៅក្នុងឯកសារណាស់។ កិច្ចការរបស់យើងគឺមិនទាន់ មិនមានបញ្ហាហ្នឹងកើតឡើងទេ។ សូមលោករៀបចំនូវសំណួរឲ្យបានជាក់លាក់ ហើយគប្បីប្រើពាក្យពេចន៍ដែលសមរម្យ ដែលលោកបាន គេអនុវត្តទូទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលលោកបានប្រើប្រាស់អំមិញរួចហើយ។

[១១:៣០:៤៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដោយសារតែពាក្យហ្នឹងជាពាក្យច្បាប់ មិនមែនមានន័យថា ពាក្យហ្នឹងមានបញ្ហានោះទេ។ ឥឡូវនេះខ្ញុំប្រើពាក្យមួយទៀតដែល ពេជ្រ ជឹម ប្រើគឺពាក្យ "ក្បត់"។ លោកស្រីសាក្សី ខ្ញុំសុំទោស ប៉ុន្តែខ្ញុំត្រូវតែមិនយល់ស្របជាមួយអ្នកស្រី ព្រោះអ្នកស្រីបានចាកចេញពីកំពង់សៀម ហើយអ្នកស្រីទៅខាងឧត្តរ គឺថានៅពេលហ្នឹង អត់ទាន់មានភូមិភាគកណ្ដាលនោះទេ គឺថាភូមិភាគកណ្ដាលត្រូវបានបង្កើតនៅឆមាសទី២ ឆ្នាំ៧៧នោះទេ។ ដូច្នេះលោកស្រីបានចាកចេញពីខេត្តកំពត គឺអ្នកស្រីទៅឧត្តរ។ ដូច្នេះខ្ញុំមិនត្រូវពិភាក្សាអំពីបញ្ហានេះទេ ប៉ុន្តែខ្ញុំនឹងប្រើប្រាស់ឈ្មោះជាប្រវត្តិសាស្ត្រនៅក្នុងតំបន់នៅពេលនោះ។ ដូច្នេះខ្ញុំចង់សួរលោកស្រីថា ហេតុផលដែលអ្នកស្រី និងកម្មាភិបាលដទៃទៀតត្រូវធ្វើដំណើរទៅឧត្តរ គឺដោយសារតែឧត្តរ ពួកឧត្តរជាពួកក្បត់ឬ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរហ្នឹង។ តាមខ្ញុំស្ដាប់មើលសំណួរនេះ បានសួរខ្ញុំច្រើនដង ពីរឿងទៅពីតំបន់៣៥ ទៅភូមិភាគកណ្ដាល។ ហេតុនេះខ្ញុំមកយកកម្មាភិបាលទាំងអស់នេះទៅ ខ្ញុំបានបញ្ជាក់រួចហើយ ក្នុងៗការស៊ើបអង្កេត--

**ប្រធានអង្គជំនុំ៖**

ឥឡូវលោកស្រីឆ្លើយតបនឹងសំណួរ ព្រោះការស៊ើបអង្កេតហ្នឹងវាផ្សេង។ ឥឡូវដេញដោលចំពោះមុខអង្គជំនុំជម្រះហ្នឹង គឺវាផ្សេង។ និយាយឲ្យអង្គជំនុំជម្រះស្ដាប់ អាន៎ុងគឺហៅស៊ើបអង្កេតបឋម។ ឥឡូវនេះដេញដោល គឺជាការស៊ើបអង្កេតផ្លូវការ ដើម្បីអង្គជំនុំជម្រះមានមូលដ្ឋានសម្រេចសេចក្ដី។ យល់អាបញ្ហានេះឲ្យច្បាស់។ ឆ្លើយតបនឹងសំណួរ។

[១១:៣៣:០៤]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** កាលនោះខ្ញុំបាននាំកម្មាភិបាលទាំងអស់ទៅភូមិភាគកណ្ដាល ខ្ញុំអត់បានដឹងថា ភូមិភាគឧត្តរហ្នឹង អត់មានបានចូលភូមិភាគឧត្តរ ប៉ុន្តែដល់ក្រោយមកខ្ញុំដូចជាឃើញថា ខ្ញុំនាំទៅគឺភូមិភាគកណ្ដាលតែម្ដង អត់មានឮថាភូមិភាគឧត្តរទេ អាហ្នឹងខ្ញុំសូមលើកបញ្ហាអ៊ីចឹង។ ហើយយកទៅនេះ ខ្ញុំមិនមិនដឹងថា កម្មាភិបាលនៅកន្លែងភូមិភាគហ្នឹងក្បត់ ឬមិនក្បត់ ខ្ញុំក៏មិនបានដឹងដែរ។ ព្រោះពួកខ្ញុំចូលទៅដល់ ក៏អត់មានៗដឹងថាក្បត់ជាតិ មិនក្បត់ជាតិអីទេ ខ្ញុំសូមជម្រាបត្រង់។ ឥឡូវបើថាលើកភូមិភាគឧត្តរហ្នឹងក៏លើកចុះ តែចំពោះខ្ញុំ តាំងពីបញ្ជូនពីកំពតទៅចូលភូមិភាគកណ្ដាលតែម្ដង ខ្ញុំវាអត់បានស្គាល់ភូមិភាគឧត្តរ។ អ៊ីចឹងលោកលើកមក ខ្ញុំក៏អត់ជំទាស់ដែរ។ តែខ្ញុំយល់ថា ការនាំកម្មាភិបាលទៅ ជាពួកខ្ញុំទៅនេះ លោកបានសួរថា តើនៅកន្លែងហ្នឹងក្បត់អីយ៉ាងម៉េច? ខ្ញុំមិនបានដឹងដែរ មិនដឹងថាក្បត់ ឬមិនក្បត់ ខ្ញុំអត់ដឹងដែរ ព្រោះខាងលើបញ្ជាឲ្យទៅ ខ្ញុំចេះតែទៅ។ ហើយចំពោះខាងហ្នឹងក្បត់ជាតិ មិនក្បត់ជាតិ ខ្ញុំអត់ដឹងទេ ព្រោះចេះតែនាំគ្នាទៅ ទៅនៅភូមិភាគហ្នឹងទៅ។ នេះសូមបញ្ជាក់ខ្លីអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗ លោកមេធាវី វ៉ិចទ័រ កូប៉េ។ បាទ អង្គជំនុំជម្រះអរគុណលោកស្រី ប្រាក់ យុត ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកបន្តផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ថ្ងៃព្រហស្បតិ៍ ទី២១ ខែមករា ឆ្នាំ២០១៦ គឺធ្វើតែមួយព្រឹកទៀតទេ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួន។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះក៏សូមអញ្ជើញលោកមកប្រឹក្សាសាក្សីរូបនេះ ដែលនឹងធ្វើនៅព្រឹកថ្ងៃស្អែក ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួន។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ជូនលោកស្រី ប្រាក់ យុត ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការវិញ នៅព្រឹកថ្ងៃស្អែកដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកនៅម៉ោង ១១:៣៥ នាទី រហូតដល់ម៉ោង ១៣:៣៥នាទី)*

[១៣:៣៤:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅរសៀលនេះ អង្គជំនុំជម្រះធ្វើសវនាការជាសាធារណៈ ស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-844 តាមប្រព័ន្ធសោតទស្សន៍ពីខេត្តព្រៃវែង មកជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់សំឡេង និងរូបភាពចេញពីបន្ទប់សវនាការ ទៅសាធារណជន ទៅកន្លែងអ្នកសារព័ត៌មាន និងសម្រាប់ចែកចាយផ្ទៃក្នុងនៃបុគ្គលិក អ.វ.ត.ក។

ជម្រាបសួរលោក ញ៉ែម សំណាង បុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលបំពេញភារកិច្ចសម្របសម្រួលធ្វើសវនាការតាមៗរយៈប្រព័ន្ធសោតទស្សន៍ពីកន្លែងដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវផ្តល់សក្ខីកម្មជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង បានរៀបចំរួចរាល់ហើយឬនៅ?

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន សូមគោរព លោកប្រធាន។ ការរៀបចំបានរៀបរួចរាល់អស់ហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយដើមបណ្តឹងរដ្ឋប្បវេណី តើលោកត្រៀមខ្លួនរួចហើយឬនៅ?

**លោក ឡាច គ្រី៖**

បាទ សូមគោរព លោកប្រធាន ខ្លួនរួចៗអស់ហើយ។

[១៣:៣៥:៤៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ អរគុណ។ ឥឡូវនេះ យើងចាប់ផ្តើមនីតិវិធីណា ធ្វើសវនាការ។ តើដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក ឡាច គ្រី៖**

**ឆ៖** បាទ ខ្ញុំបាទ ឈ្មោះ ឡាច គ្រី នៅភូមិពោធិ៍ចិន្តាំ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។

**ស៖** បាទ អរគុណ។ ហើយលោកកើតនៅថ្ងៃខែឆ្នាំណា លោកចងចាំដែរទេ?

**ឆ៖** បាទ ខ្ញុំបាទចាំ។ កើតនៅឆ្នាំ១៩៤៧ កើតនៅថ្ងៃទី១៥ ខែ០៣។

**ស៖** បាទ អរគុណ។ ហើយលោកកុំអាលទាន់ឆ្លើយវិញលឿនពេកណ៎ា អង់បន្តិចក៏បានដែរ ដើម្បីឱ្យមានការបកប្រែសម្ដីរបស់លោកបានច្បាស់លាស់ ព្រោះត្រូវការប្រើប្រាស់ភាសាអង់គ្លេស និងភាសាបារាំងទៀតណ៎ា។ តើលោកប្រកបមុខរបរអី លោក ឡាច គ្រី សព្វថ្ងៃនេះ?

**ឆ៖** បាទ ខ្ញុំបាទ ៗជាអ្នកស្រែ ធ្វើស្រែចម្ការ លោកប្រធាន។

**ស៖** បាទ អរគុណ។ ហើយលោក ឡាច គ្រី តើឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

[១៣:៣៧:០៤]

**ឆ៖** បាទ ឪពុកខ្ញុំបាទ ឈ្មោះ ប្រិច ឡាច។ ម្ដាយឈ្មោះ គួយ ឡាត់។

**ស៖** បាទ អរគុណ។ ហើយចុះភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ ភរិយាទី១ដែលស្លាប់ទៅហ្នឹងឈ្មោះ ឌឿក ចន មានកូនប្រាំនាក់។

**ស៖** ចុះបច្ចុប្បន្ននេះ តើលោកមានភរិយាទី២ ឈ្មោះអីដែរ? ហើយមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ សព្វថ្ងៃកូន -- ភរិយាទី២ ឈ្មោះ សៀម សារ៉ន មានកូនពីរនាក់ ស្រីមួយប្រុសមួយ។

**ស៖** បាទ អរគុណលោក ឡាច គ្រី។ ហើយជាចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោកក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងនេះ លោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ដល់ថ្ងៃ០៦ ខែមករា ឆ្នាំ៧៩ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

ហើយលោក ឡាច គ្រី តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងអំឡុងពេលកន្លងមក?

**ឆ៖** បាទ លោកប្រធាន ពេលកន្លងមកបានសម្ភាសបានបីដង នៅផ្ទះខ្ញុំបាទនោះម្ដង នៅឯសាលាច្បាប់នេះម្ដង ហើយនៅឯកន្លែងអី លោកអីទេ ខ្ញុំបាទសុំអត់ទោសវាមិនបានស្គាល់កន្លែងនោះ។

**ស៖** ហើយនៅមុនពេលដែលលោកអង្គុយនៅទីនេះ នៅកន្លែងផ្តល់សក្ខីកម្មពីកន្លែងនោះមកនោះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មដែលលោកបានធ្វើជាមួយនឹងអ្នកស៊ើបអង្កេតកាលពីមុន ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ បានពិនិត្យហើយ លោកប្រធាន។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹងបាន តើលោកអាចបញ្ជាក់បានដែរទេថាចម្លើយដែលលោកបានអាន កំណត់ហេតុដែលលោកបានអាន ដើម្បីរំឭកការចងចានោះ វាសមស្រប វាស៊ីចង្វាក់គ្នាទៅនឹងសក្ខីកម្មរបស់លោកដែលលោកបានផ្តល់ឲ្យចំពោះអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

**ឆ៖** បាទ លោកប្រធាន គឺបានពិតប្រាកដមែនហើយ គឺថាតាមឯកសារហ្នឹងពិតមែន។

[១៣:៣៩:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី លោកស្តាប់ខ្ញុំឮច្បាស់ទេលោក?

**លោក ឡាច គ្រី៖**

**ឆ៖** ឮច្បាស់។

**ស៖** ជម្រាបសួរលោក។ ខ្ញុំនឹងចាប់ផ្តើមសួរសំណួរទៅកាន់លោក ដោយសូមឲ្យលោកឆ្លើយបញ្ជាក់អំពីគ្រួសាររបស់លោក។ ជាដំបូងខ្ញុំចង់ដឹងថា តើលោកមានបងប្អូនប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ខ្ញុំមានបងប្អូនប្រាំនាក់។

[១៣:៤១:០៥]

**ស៖** ហើយប្រាំនាក់ហ្នឹង ស្រីប៉ុន្មាន ប្រុសប៉ុន្មាន ហើយឈ្មោះអីខ្លះ?

**ឆ៖** បាទ ប្រាំនាក់ហ្នឹង បងឈ្មោះ ឡាច នី, បន្ទាប់មកឈ្មោះ ឡាច ណាត់ (ស្រី) បន្ទាប់មកទៀតឈ្មោះ ឡាច ណាក (ស្រី) បានមករូបខ្ញុំបាទហ្នឹង ឡាច គ្រី បានមកប្អូនមួយទៀតឈ្មោះ ឡាច ណាង។

**ស៖** អ៊ីចឹងប្រុសប៉ុន្មាន ស្រីប៉ុន្មានដែរលោក?

**ឆ៖** បាទ ប្រុសពីរ ស្រីបី។

**ស៖** លោកបាននិយាយអំពីឈ្មោះ ឡាច នី ជាបងប្រុសរបស់លោក។ តើបងប្រុស ឡាច នី នេះនៅមានជីវិតទេសព្វថ្ងៃនេះ?

**ឆ៖** បាទ ឡាច នី បានស្លាប់ហើយ។

**ស៖** គាត់ស្លាប់នៅឆ្នាំណាដែរលោក?

**ឆ៖** នៅឆ្នាំ នៅៗឆ្នាំ២០០៦។

**ស៖** សូមអរគុណ។ ពេលដែល ឡាច នី នៅរស់នោះ តើលោកមានទំនាក់ទំនងយ៉ាងម៉េចជាមួយគាត់? លោកមានភាពជិតស្និទ្ធអីជាមួយគាត់ទេ?

**ឆ៖** បាទ ចំពោះ ឡាច នី ហើយខ្ញុំ គឺថាផ្ទះជាប់គ្នាៗ។ ហើយក្នុងការទំនាក់ទំនងអី គឺថាតាំងពីបែកមកហ្នឹង គឺថាមានការនិយាយនឹករឭកដល់គ្នា*(ឮមិនច្បាស់)* បងប្អូនជាច្រើនដែរ។

**ស៖** ឡាច នី នេះគាត់អាយុបងលោកប៉ុន្មានឆ្នាំដែរ?

**ឆ៖** បាទ បងខ្ញុំបាទ៩ឆ្នាំ។

[១៣:៤៣:៥១]

**ស៖** លោកឆ្លើយថា លោកបានជជែកគ្នាជាមួយនឹងបងលោកអំពីបទពិសោធន៍នៅក្នុងរបបខ្មែរក្រហម។ ចុះលោកធ្លាប់និយាយជាមួយគាត់អំពីការកាត់ទោសខ្មែរក្រហមនៅក្នុងតុលាការនេះទេ?លោកធ្លាប់ជជែកសំណេះសំណាលជាមួយគាត់អំពីរឿងហ្នឹងទេ?

**ឆ៖** បាទ កាលខ្ញុំជជែកវែកញែកនុ៎ង គឺថាមិនបាននិយាយពីតុលាការទេ អត់មានបាននិយាយទេ។ និយាយតែពីរឿងការនឹករឭកមាតាបិតាប៉ុណ្ណឹងទេ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកបានសម្រេចបន្តភាពជាដើមបណ្ដឹតរដ្ឋប្បវេណីរបស់បងប្រុសរបស់លោក ខ្ញុំសូមយោងទៅលើឯកសារ E3/6927។ តើលោកអាចពន្យល់បានទេថា ហេតុអ្វីបានជាលោកបន្តសកម្មភាពជាដើមបណ្ដឹងរដ្ឋប្បវេណីពីបងប្រុសរបស់លោក?

**ឆ៖** បាទ ពេលដែលខ្ញុំបាទបន្តពីបងប្រុសរបស់ខ្ញុំបាទ ពីព្រោះបងប្រុសស្លាប់ហើយ ដូច្នេះមុនដែលដាក់ពាក្យបណ្ដឹង ក៏គាត់បានផ្ដាំខ្ញុំដែរ។ ផ្ដាំថាបើសិនជាអត់ពីគាត់ទៅ ត្រូវស្នងត្រកូលពីគាត់ ពាក្យបណ្ដឹងពីគាត់។ បានខ្ញុំបានដាក់ពាក្យបណ្ដឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំនិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងភូមិពោធិ៍ចិន្ដាំដែលលោករស់នៅកាលពីសម័យនោះ។ ជាដំបូងខ្ញុំចង់ដឹងថា តើបងប្រុស ឡាច នី ហ្នឹងនៅសម័យខ្មែរក្រហមរស់នៅជិតលោកទេ?

[១៣:៤៥:៥៨]

**ឆ៖** បាទ បងឈ្មោះ ឡាច នី ហ្នឹងរស់នៅជាប់ផ្ទះ ជាប់គ្នា ជាប់ខ្ញុំ។

**ស៖** គាត់រស់នៅក្នុងផ្ទះក្បែរលោករហូត ឬក៏គាត់រើទៅនៅភូមិ នៅកន្លែងណាផ្សេងនៅក្នុងភូមិ?

**ឆ៖** បាទ ពេលកន្លងមក គឺនៅជាប់គ្នារហូត ទើបឥឡូវ បែកហើយហ្នឹង គាត់រើទៅនៅ ឆ្ងាយពីខ្ញុំប្រហែលជា៥០០ម៉ែត្រ ភូមិថ្មី។

**ស៖** ចុះអំឡុងក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គាត់រស់នៅផ្ទះជាប់លោករហូត ពេញមួយរបបនុំង មែនទេ?

**ឆ៖** បាទៗ មែន។

**ស៖** តើបងរបស់លោកនៅភូមិពោធិ៍ចន្ដាំរហូត ឬក៏គាត់ត្រូវគេបញ្ជូនទៅធ្វើការនៅកន្លែងណាផ្សេង?

**ឆ៖** បាទ អត់មានទេ នៅភូមិពោធិ៍ចិន្ដាំរហូត។

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្ដឹងរដ្ឋប្បវេណី រំឮកលោកម្ដងទៀត លោក ឡាច គ្រី សូមលោកដកឃ្លាបន្តិចឃ្លារវាងនៅក្នុងការតាំងសំណួរ ហើយនិងលោកឆ្លើយ ដើម្បីទុកលទ្ធភាពឲ្យអ្នកបកប្រែ គឺបកប្រែទៅជាភាសាអង់គ្លេស និងភាសាបារាំងទៀត ទី១។ ទី២ ពាក្យពេចន៍ដែលលោកឆ្លើយហ្នឹង សូមឲ្យ ក៏ឃើតដែរ

ឲ្យយឺតជាងនេះបន្តិច ដើម្បីឲ្យការដែលលោកនិយាយហ្នឹង គឺអ្នកបកប្រែអាចតាមទាន់លោក ឡាច គ្រី។

[១៣:៤៨:០០]

**លោក ឡាច គ្រី៖**

បាទៗ អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទៗ អញ្ជើញបន្តដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី បងប្រុសរបស់លោកនោះធ្លាប់មករស់នៅ និងធ្វើការនៅទីក្រុងភ្នំពេញទេ?

**លោក ឡាច គ្រី៖**

**ឆ៖** បាទបងរបស់ខ្ញុំឈ្មោះ ឡាច នី ហ្នឹងពីសង្គមបានធ្លាប់មកនៅធ្វើការនៅក្រុងភ្នំពេញហ្នឹង។

**ស៖** លោកចាំទេ គាត់មកភូមិកំណើតវិញហ្នឹង នៅឆ្នាំណាដែរ?

**ឆ៖** បាទ គាត់វិលមកភូមិកំណើតវិញ នៅឆ្នាំ១៩៦៨។

**ស៖** ពេលនោះគាត់មានប្រពន្ធហើយឬនៅ?

**ឆ៖** បាទ គាត់មានហើយ។

[១៣:៤៩:២០]

**ស៖** លោកចាំទេថា តើលោកជួបប្រពន្ធគាត់ហ្នឹងនៅពេលណាដែរ ក្នុងកាលៈទេសៈអីដែរ? ហើយលោកនៅចាំឈ្មោះប្រពន្ធរបស់លោកទេ -- ប្រពន្ធរបស់គាត់ទេ គឺបងថ្លៃលោកហ្នឹង?

**ឆ៖** បាទ ខ្ញុំបាទចាំ។

**ស៖** គាត់ឈ្មោះអីដែរ?

**ឆ៖** បាទ គាត់ឈ្មោះ សំ សាន។

**ស៖** ពេលបងប្រុសត្រឡប់ទៅភូមិវិញហ្នឹង បងរបស់លោកហ្នឹង ទៅជាមួយនឹងប្រពន្ធគាត់ទេ? ហើយពេលទៅហ្នឹងមានកូន មានអីប៉ុន្មាននាក់ទេ ពេលទៅភូមិពោធិ៍ចិន្ដាំវិញហ្នឹងណា?

ធ៖ បាទដែលគាត់វិលទៅស្រុកវិញ គឺគាត់យកប្រពន្ធទៅ គឺមានកូនមួយ កូនប្រុសមួយ។

ស៖ ប្រពន្ធគាត់ចេះនិយាយភាសាខ្មែរទេ?

ធ៖ បាទ ប្រពន្ធគាត់ចេះនិយាយភាសាខ្មែរ។

ស៖ ពេលដែលបងប្រុសលោកនិងបងថ្លៃលោក ត្រឡប់មករស់នៅភូមិពោធិ៍ចិន្តាំវិញហ្នឹង ពេលនោះលោកស្គាល់ដើមកំណត់របស់បងថ្លៃលោកទេ?

ធ៖ ខ្ញុំបាទដឹងៗពីបងខ្ញុំឈ្មោះ ឡាច នី ហ្នឹងគាត់ប្រាប់ថា ប្រពន្ធរបស់គាត់ហ្នឹង គឺនៅខេត្តបាត់ដំបង។ ប្រពន្ធរបស់ ឡាច នី ហ្នឹង នៅខេត្តបាត់ដំបង។

[១៣:៥១:៣៧]

ស៖ លោកធ្លាប់ឮបងថ្លៃរបស់លោកឈ្មោះ សាន ហ្នឹងនិយាយភាសាវៀតណាមទេ?

ធ៖ បាទ ខ្ញុំបាទធ្លាប់ឮ។

ស៖ លោកអាចពន្យល់បានទេថា នៅក្នុងឱកាសអីដែរដែល សាន ហ្នឹងគាត់និយាយភាសាវៀតណាមនៅក្នុងភូមិហ្នឹង?

ធ៖ បាទ ព្រោះគាត់ទៅនៅ វិលទៅនៅអីខាងព្រៃវែងហ្នឹង គាត់រកស៊ីរបរលក់បន្លែ លក់បន្លែ ដូច្នេះបើវៀតណាមអីគាត់ទៅទិញបន្លែទិញអីផ្សេង គាត់ច្រើននិយាយជាមួយបងប្អូនដែលទៅទិញហ្នឹងជាភាសាវៀតណាម។

ស៖ លោកបានឆ្លើយថាបងថ្លៃរបស់លោកនៅបាត់ដំបង។ អ៊ីចឹងលោកដឹងទេថា ឪពុក ឬក៏ម្ដាយរបស់បងថ្លៃលោកហ្នឹងជាជនជាតិវៀតណាមដែរមែនទេ?

ធ៖ បាទ ដែលខ្ញុំបាទដឹង គាត់ទៅនៅព្រៃវែងហើយបានគាត់និយាយប្រាប់ខ្ញុំបាទ។ ឪពុកហ្នឹងគឺខ្មែរ ម្ដាយវៀតណាម។

ស៖ លោកដឹងថាមានអ្នកណាខ្លះទៀតជាជនជាតិវៀតណាមនៅក្នុងភូមិពោធិ៍ចិន្តាំ?

ធ៖ ខ្ញុំបាទបានដឹងនៅក្នុងភូមិពោធិ៍ចិន្តាំមានវៀតណាមបីគ្រួសារ។

ស៖ លោកអាចរៀបរាប់លម្អិតអំពីគ្រួសារវៀតណាម ទាំងបីនេះទេ? ហើយនៅក្នុងគ្រួសារទាំងបីហ្នឹង អ្នកណាខ្លះដែលមានដើមកំណើតវៀតណាមសុទ្ធសាធតែម្ដងនោះ?

[១៣:៥៣:៤៩]

ធ៖ បាទ ខ្ញុំសូមជម្រាបជូន ទី១ ឈ្មោះ វ៉ាន់ ង៉ាង ឪពុកវៀតណាម ម្ដាយក៏វៀតណាម។

ទី២ ឈ្មោះ ជុយ, បាទ ជុយ នុ៎ងគឺប្រពន្ធខ្មែរ។ ហើយទី៣ ហ្នឹងគឺប្រពន្ធ ឡាច នី ហ្នឹង។

**ស៖** លោកចាំទេ នៅឆ្នាំណាដែលខ្មែរក្រហមចូលមកនៅភូមិពោធិ៍ចិន្តាំនេះ?

**ឆ៖** ពេលដែលខ្មែរក្រហមចូលមកនៅភូមិពោធិ៍ចិន្តាំ ឆ្នាំ១៩៧០, ៧០ – ឆ្នាំ៧០។

**ស៖** អ៊ីចឹងពេលឆ្នាំ៧០ហ្នឹង មានការវាយប្រយុទ្ធគ្នាទេ ឬក៏ពេលហ្នឹងអត់មានវាយប្រយុទ្ធអីទេ គឺខ្មែរក្រហមចូលមកកាន់កាប់តែម្តង?

**ឆ៖** បាទ កាលហ្នឹងគឺនៅទាហានជំនាន់ទាហាននល់ នល់ ហ្នឹងគឺនៅៗក្នុងភូមិពោធិ៍ចិន្តាំហ្នឹង។ ដល់នេះខ្មែរក្រហមមកៗ អត់មានៗទាន់វ៉ៃទេ រយៈពេលមួយខែក្រោយមកបានមានវ៉ៃជាមួយទាហានពួកខ្មែរក្រហមហ្នឹង វ៉ៃនៅភូមិពោធិ៍ចិន្តាំហ្នឹង។

**ស៖** លោកចាំទេថាឆ្នាំណាដែរដែលខ្មែរក្រហមឡើងមកកាន់ធ្វើជាអាជ្ញាធរភូមិ ឃុំ? ឆ្នាំ៧០ ហ្នឹងគឺភ្លាមៗតែម្តង ឬក៏ក្រោយមកទៀត?

**ឆ៖** បាទ ក្រោយរយៈពេលពីរឆ្នាំកន្លងមកបានមានៗវៀតណាមមកនៅនឹងភូមិខ្ញុំបាទហ្នឹង។ ពីរឆ្នាំក្រោយមក។

**ស៖** ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ លោកថាពីរឆ្នាំក្រោយមកគឺមានន័យថាឆ្នាំ៧២ វៀតណាមបានចូលមករស់នៅក្នុងភូមិលោកៗឆ្លើយអ៊ីចឹងមែនទេ?

**ឆ៖** បាទៗ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំអត់ទទួលបានការបកប្រែជាភាសាបារាំងទេ។

[១៣:៥៦:៤៨]

**ប្រធានអង្គជំនុំ៖**

ទំនងជាមានបញ្ហាហើយ អាចតាំងសំណួរសាជាថ្មីម្តងទៀតមើល៍។ តើដើមបណ្តឹងរដ្ឋប្បវេណីទទួលសំណួរបានទេ? លោកៗ ឡាយ នី តើលោកស្តាប់យើងបានទេលោកឡាយ នី -- លោក ឡាច គ្រី?

**លោក ឡាច គ្រី៖**

បាទៗ ស្តាប់បានៗ លោកប្រធាន ស្តាប់បាន។

**ប្រធានអង្គជំនុំ៖**

បាទៗ អរគុណ។ ហើយបន្តរៀបចំសំណួរសាជាថ្មីម្តងទៀត អំមិញវាមានបញ្ហាបច្ចេកទេស

ឧបករណ៍ណ៎ា។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោក ឡាច គ្រី ខ្ញុំសួរលោកឡើងវិញ។ លោកថាខ្មែរក្រហមបានចូលមកភូមិរបស់លោកនៅឆ្នាំ៧០ បន្ទាប់មកទៀតមានការវាយប្រយុទ្ធគ្នាជាមួយទាហានលន់ នល់ លោកថាពីរឆ្នាំក្រោយមកទៀត។ អ៊ីចឹងខ្ញុំចង់ដឹងថាតើខ្មែរក្រហមហ្នឹងមកកាន់អំណាចនៅក្នុងភូមិ ឃុំហ្នឹងនៅឆ្នាំណាដែរ?

**លោក ឡាច គ្រី៖**

**ឆ៖** បាទ ខ្មែរក្រហមហ្នឹងមកកាន់អំណាចហ្នឹងគឺថាក្នុងការចាត់តាំងក្នុងមូលដ្ឋានហ្នឹងនៅឆ្នាំ៧១, ៧០ហ្នឹង ជិតពី៧០មករហូតមកតែម្តង។ ដល់កាន់កាប់ហើយ ខ្មែរក្រហមហ្នឹងចាត់តាំងតាមមូលដ្ឋានហ្នឹងតែម្តង ចាត់តាំងជារដ្ឋអំណាចឲ្យក្តាប់នៅក្នុងភូមិនីមួយៗហ្នឹង។

[១៣:៥៨:២៥]

**ស៖** អ៊ីចឹងពេលដែលខ្មែរក្រហមមកកាន់អំណាចនៅក្នុងភូមិហ្នឹង ជីវិតប្តីប្រពន្ធបងរបស់លោកគឺ ឡាច នី និងប្រពន្ធគាត់ហ្នឹងមានការប្រែប្រួលទេ?

**ឆ៖** បាទ ចំពោះ ឡាច នី និងគ្រួសារគាត់ក្នុងឆ្នាំ៧០ អត់មានការប្រែប្រួលអីទេ ធម្មតាដូចយើងប្រជាជនធម្មតា។

**ស៖** ចុះមានប្រែប្រួលស្ថានភាពអ្វីទេ? ហើយបើមាន តើមានរឿងហេតុអ្វីកើតឡើងចំពោះសាន?

**ឆ៖** បាទ ពេលដែលចំពោះ សាន ហ្នឹង ចំពោះខាងវៀតណាមវិញគឺថា ក្នុងការប្រែប្រួល អត់មានការប្រែប្រួលអីទេ រហូតមកទាល់ឆ្នាំ៧៧ហ្នឹងបានមានការប្រែប្រួល។

**ស៖** សូមអរគុណ។ លោកអាចជម្រាបបានទេ ថានៅក្នុងឆ្នាំ១៩៧៧ តើមានរឿងហេតុអ្វីកើតឡើងចំពោះ សាន?

**ឆ៖** បាទ ក្នុងឆ្នាំ៧៧ហ្នឹង គឺគ្មានរឿងរ៉ាវអីដែលធ្វើឲ្យប៉ះពាល់ដល់សតិអារម្មណ៍របស់ សាន ហ្នឹងទេ អត់មានសោះ ដូចប្រជាជនយើងធម្មតា។

**ស៖** តើគេមានចាប់ខ្លួន សាន ទេ នៅឆ្នាំ៧៧ហ្នឹង?

**ឆ៖** បាទ ក្នុងឆ្នាំ៧៧ហ្នឹង ខែ១១ៗ គេត្រូវចាប់ប្រពន្ធ ឡាច នី ឈ្មោះ សាន ហ្នឹងហើយ ព្រមទាំងកូន កូនប្រាំនាក់ ហើយប្រពន្ធនោះមួយទៅ ក្នុងខែ១១។

**សៈ** លោកឃើញការចាប់ខ្លួន សាន ហ្នឹងដោយផ្ទាល់ភ្នែកទេ? ហើយបើឃើញនោះ លោកអាចរៀបរាប់បានទេ ពេលនោះគេធ្វើយ៉ាងម៉េចខ្លះ?

[១៤:០១:០៦]

**ឆ៖** ខ្ញុំបាទ ចាប់ប្រពន្ធ ឡាច នី ខ្ញុំបាទនៅនុំង កំពុងច្រូតៗ នៅក្បែរផ្ទះ ឡាច នី ហ្នឹង នៅក្បែរក្រោយផ្ទះខ្ញុំហ្នឹង គេចាប់។ បាទចាប់ បើកូនទៅនៅធ្វើការនៅឆ្ងាយពីៗម្ដាយហ្នឹងចំនួន២គីឡូ កូនធំឈ្មោះ នីន កូនហ្នឹង។ ហើយប្រពន្ធនៅផ្ទះ នៅជាប់ផ្ទះហ្នឹង ផ្ទះដែលខ្ញុំបាទនៅហ្នឹង កំពុងច្រូត។ ច្រូតទៅ គឺមានឈ្លបបីនាក់មក ឈ្លប។ បាទឈ្លប ខ្ញុំបាទស្គាល់ឈ្មោះច្បាស់គឺ អួង ង៉ុយ តែម្ដងឈ្លបហ្នឹងប្រធានឈ្លបឃុំ ឈ្មោះ អួង ង៉ុយ។ ហើយពីរនាក់ទៀត ខ្ញុំបាទអត់ស្គាល់ទេ។

**សៈ** ដើម្បីឲ្យច្បាស់ ខ្ញុំចង់សួរលោកថា លោកឃើញឈ្លបទាំងបីហ្នឹងចាប់ខ្លួន សាន ហ្នឹងដោយផ្ទាល់ភ្នែកតែម្ដង មែនទេ?

**ឆ៖** ពេលដែលហៅទៅហ្នឹង គឺហៅគ្រាន់តែហៅ ហៅទៅថាឲ្យទៅរៀនសូត្រ ពេលដែលហៅទៅ ឲ្យទៅរៀនសូត្រ។ ហើយពួកខ្ញុំទាំងអស់គ្នាកំពុងច្រូតកាត់ហ្នឹង ឃើញឈរមើលទៅ ឈរមើល សាន ហ្នឹងដែលគេអញ្ជើញគាត់ហ្នឹងទៅឡើងរទេះសេះនោះ ចេះតែឆ្ងល់ថា មូលហេតុអីបានជាត្រូវហៅ សាន ហ្នឹងឡើងរទេះសេះ បានខ្ញុំបាទមើលឃើញច្បាស់ផ្ទាល់នឹងភ្នែកតែម្ដង។

**សៈ** ចុះកូនៗរបស់ សាន លោកនិយាយថា កូននុំងធ្វើការចម្ងាយ២គីឡូម៉ែត្រពីហ្នឹង អ៊ីចឹងពេលដែលគេចាប់ខ្លួន សាន ហ្នឹងមានកូនណាខ្លះនៅពេលនុំង នៅជាមួយនឹង សាន? ហើយពេលគេចាប់ សាន ហ្នឹង កូនៗហ្នឹងគេចាប់ដែរទេ?

**ឆ៖** ពេលដែលគេចាប់ សាន ហ្នឹងទៅ ឲ្យឡើងរទេះសេះ បានកូនៗទាំងអស់ហ្នឹងឡើងរទេះសេះចំនួនបួននាក់ កូនហ្នឹងអត់ទាន់យក មីបងទៅនៅធ្វើការឆ្ងាយ ហើយឲ្យឈ្លបទៅយកមីបងហ្នឹង ឲ្យមកៗ។ ហើយ សាន ហើយនិងកូនបួននាក់ហ្នឹង គឺដាក់រទេះសេះទៅមុន។ ហើយកូនដែលនៅ២គីឡូដីហ្នឹង ឈ្លបទៅយក ទៅតាមក្រោយ។

[១៤:០៤:០៣]

**សៈ** សូមអរគុណ។ លោកថា ឈ្លបបីនាក់បានមកចាប់ សាន និងកូនទាំងបួន។ លោកបាន

ប្រាប់ឈ្មោះឈ្លបមួយ ឈ្មោះ ង៉ុយ។ ខ្ញុំចង់ដឹងថា ង៉ុយ នេះមកពីណាដែរ ហើយមានមុខនាទីអីដែរ?

**ឆ៖** បាទ ឈ្មោះ ង៉ុយ នេះជាប្រធានសន្តិសុខរបស់ឃុំ ឃុំស្វាយអន្ទរហ្នឹង។ ហើយពីរនាក់ទៀត ខ្ញុំបាទអត់ស្គាល់ទេ ដឹងមកពីណា អត់ស្គាល់ ពីរនាក់ទៀតនោះ។

**ស៖** លោកថា បានឃើញគេចាប់ សាន ពីព្រោះថាលោកនៅក្រោយផ្ទះកំពុងធ្វើស្រែ។ អ៊ីចឹងពេលនុ៎ងគឺមានតែលោកម្នាក់ដែរ មានតែលោកម្នាក់ទេ ឬក៏មានអ្នកផ្សេងទៀតធ្វើការនៅជាមួយលោកដែរ ពេលដែលគេមកចាប់ សាន និងកូនៗនោះ?

**ឆ៖** បាទ ដែលនៅជាមួយខ្ញុំបាទហ្នឹង គឺមួយក្រុមហ្នឹងជាប់ប្រហែល២០នាក់ កំពុងច្រូតហ្នឹង មិនមែនតែរូបខ្ញុំម្នាក់ទេ គឺប្រហែល២០នាក់ បានឃើញទាំងអស់គ្នា។

**ស៖** ចុះបងប្រុសរបស់លោក ឡាយ នី ហ្នឹងគាត់នៅទីនុ៎ងទេ នៅថ្ងៃនុ៎ង?

**ឆ៖** បាទ ពេលដែលគេចាប់ប្រពន្ធហ្នឹងទៅ បងឈ្មោះ ឡាច នី ហ្នឹងគាត់នៅទីនោះដែរ គាត់ដួលសន្លប់ គេចាប់ប្រពន្ធយកទៅហ្នឹងគឺ ឡាច នី សន្លប់ ដួលសន្លប់នៅក្នុងស្រែៗហ្នឹង។ ក្រោយមកទៀតបានគាត់ដឹង ក៏ចេះដើរទៅឆ្ងាយ ទៅពីកន្លែងស្រែច្រូតហ្នឹងប្រហែលរាប់២គីឡូជាង ដើរ ចេះតែដើរស្មានទៅតែម្តង អត់ដឹងទិសដៅទៅណា។

**ស៖** ខ្ញុំនឹងនិយាយអំពីបងប្រុសរបស់លោកនៅពេលក្រោយ ឥឡូវនេះខ្ញុំចង់សួរលោកថា ពេលឃើញឈ្លបមកចាប់ សាន ហើយនិងកូនៗទាំងបួន លោកមានការភ្ញាក់ផ្អើលទេ?

**ឆ៖** បាទ ចំណែកខ្ញុំ ក៏ដូចជាបងខ្ញុំ ក៏ដូចជាអ្នកជិតខាងទាំងអស់ដែលឈរមើលហ្នឹង គឺមានការភ្ញាក់ផ្អើលជាទីបំផុត ដោយស្មានមិនដល់ថា គេចាប់ហ្នឹងដោយមានមូលហេតុអី អត់ដឹង។

[១៤:០៦:៥៤]

**ស៖** មុនពេលដែលឈ្លបមកចាប់ខ្លួន សាន នោះលោកដឹងជាមុនថា សាន នឹងត្រូវចាប់ខ្លួនទេ?

**ឆ៖** បាទ អត់ដឹងទេ។

**ស៖** លោកចាំថា មានការប្រជុំ ហើយលោកបានចូលរួម ហើយក្នុងពេលប្រជុំហ្នឹង គេមានប្រកាសថានឹងចាប់ខ្លួន សាន អីទេ?

**ឆ៖** បាទ អត់មានទេ អត់មានប្រជុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបដើមបណ្តឹងរដ្ឋប្បវេណី!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ដើមបណ្តឹងរដ្ឋប្បវេណី គាត់បានឆ្លើយតបទៅនឹងសំណួរអំពីការចាប់ខ្លួន សាន ហើយខ្ញុំគិតថា ក្នុងការឆ្លើយហ្នឹង គាត់បានប្រើប្រាស់ពាក្យ “ចាប់ខ្លួន” ហើយគាត់ក៏បាននិយាយផងដែរថា យកទៅរៀនសូត្រ។ ខ្ញុំដឹងថា ភាគីយល់យ៉ាងម៉េចចំពោះពាក្យនេះ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី គាត់បាននិយាយអំពីវគ្គរៀនសូត្រ។ ដូច្នេះការប្រើប្រាស់ពាក្យចាប់ខ្លួន ដើម្បីយកទៅប្រជុំ ហើយដោយមិនបានគិតដល់អ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា សាន បានត្រូវរៀនសូត្រហ្នឹង គឺជាការមិនត្រឹមត្រូវ។ ដូច្នេះខ្ញុំសូមជំទាស់ទៅលើចំណុចនេះ។

[១៤:០៨:៤១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ពាក្យ “ចាប់ខ្លួន” នេះត្រូវបានប្រើប្រាស់ដោយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះផ្ទាល់។ ខ្ញុំអាចរៀបចំសំណួរឡើងវិញបាន ដើម្បីឆ្លើយតបទៅនឹងការជំទាស់របស់មេធាវី កូប៉េ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកចាំថា លោកមានបានចូលរួមក្នុងកិច្ចប្រជុំណាមួយ ហើយក្នុងពេលប្រជុំហ្នឹង គេបានជជែកគ្នា និយាយអំពីជោគវាសនារបស់ សាន? លោកធ្លាប់ចូលប្រជុំអីចឹងទេ?

**លោក ឡាច គ្រី៖**

**ឆ៖** ខ្ញុំបាទ អត់បានដឹងទេៗ។ ពេលប្រជុំ ហៅប្រជុំ ខ្ញុំបាទអត់ដឹងទេ អត់ដឹងសោះ។

**ស៖** ខ្ញុំសួរសំណួរនេះ ពីព្រោះថានៅក្នុងឯកសារមួយ ដែលយើងមាននៅក្នុងសំណុំរឿង គឺឯកសារ E3/5630 ដែលជាព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសូមអានឲ្យលោកស្តាប់ និងសុំឲ្យលោកឆ្លើយតប។ នៅឆ្នាំ៧៧ គឺនៅកថាខណ្ឌទី៥ ERN ជាភាសាបារាំងគឺ 00891890, ERN ជាភាសាអង់គ្លេសគឺ 00678289 និងERN ជាភាសាខ្មែរគឺ 00895419។ ពេលនុ៎ងគេមានសរសេរនៅក្នុងឯកសារនោះថា៖ “នៅក្នុងឆ្នាំ១៩៧៧ នៅមុនពេលប្រពន្ធ និងកូនៗរបស់ ឡាច នី ត្រូវគេចាប់ខ្លួន គេមានកិច្ចប្រជុំប្រចាំភូមិ ដែល ឆែម បានបញ្ជាឲ្យ ង៉ុយ នាំយកកូនៗនិងប្រពន្ធរបស់ ឡាច នី ទៅកសាង។ អ្នកភូមិទាំងអស់ រួមទាំងខ្លួនខ្ញុំមានវត្តមាននៅក្នុងកិច្ចប្រជុំនេះដែរ។ ខ្ញុំមិនបានចាំកាលបរិច្ឆេទនៃកិច្ចប្រជុំ

នោះទេ។ នៅក្នុងកិច្ចប្រជុំដូចគ្នានេះផងដែរ មានគ្រួសារចំនួនបីគ្រួសារត្រូវបានគេបញ្ជាឲ្យយកទៅកសាងផងដែរ។" ដូច្នេះលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសួរលោកម្តងទៀត លោកចាំថាមានការប្រជុំបែបនេះទេ ឬក៏លោកភ្លេចទៅហើយ?

**ឆ៖** ខ្ញុំបាទកាលនោះ ប្រហែលជាខ្ញុំភ្លេចមិនដឹង ពីព្រោះអង្កាល់នុំង ដូចខ្ញុំនេះវាភ្លេចភ្លាំងដែរ វាយូរឆ្នាំហើយ វាភ្លេចហើយ។ បាទ សូមអត់ទោស។

[១៤:១១:៣៤]

**ស៖** លោកបានឆ្លើយថា លោកឃើញគេចាប់ខ្លួន សាន និងកូនៗទាំងបួនដោយផ្ទាល់ភ្នែក ហើយគេប្រាប់ថា គេនាំយកទៅរៀនសូត្រ។ ដូច្នេះលោកដឹងទេថា ក្រោយពីគេចាប់ខ្លួនមកនោះ ដឹងថាមានរឿងអ្វីកើតឡើងចំពោះ សាន និង កូនៗទេ?

**ឆ៖** ខ្ញុំបាទដែលធ្លាប់នៅក្នុងជាមួយគាត់នុំង គឺគ្មានរឿងអីមួយដែលធ្វើឲ្យថ្នាំងថ្នាក់ចំពោះអ្នកដឹកនាំហ្នឹងទេ អត់ដែលមានទេ។

**ស៖** ក្រោយពីគេចាប់ខ្លួន សាន ហើយនោះ លោកដឹងថា គេយក សាន ហ្នឹងទៅធ្វើអីទេ?

**ឆ៖** ខ្ញុំបាទ អត់ដឹងទេ ដាក់រទេះសេះទៅៗបាត់តែម្តង មិនដឹងទៅអីណា ប៉ុន្តែចុងក្រោយបង្អស់ដែលអ្នកដឹករទេះសេះហ្នឹង គឺនៅក្បែរផ្ទះខ្ញុំ ចម្ងាយប្រហែលជាជាង១០០ម៉ែត្រ អ្នកបររទេះសេះហ្នឹងគាត់នុំងមានការជិតស្និទ្ធជាមួយខ្ញុំណាស់។ ដល់ចុងក្រោយមក ខ្ញុំគ្រាន់តែសួរគាត់ សួរដើម្បីនឹង សួរក្នុងការខ្លាចទេ ខ្ញុំសួរថា ដែលបងដឹកយកទៅ យកទៅឯណា? គាត់ថា មិនបាច់សួរទេអូន ពីព្រោះពេលទៅដល់កន្លែងក្បែរព្រៃនុំង គាត់ឲ្យគេអ្នកនុំងគេមកទទួល មកទទួលឈ្មោះ សាន ហ្នឹង ហើយគាត់ក៏បររទេះត្រឡប់មកវិញមក។ ហ្នឹងក៏គាត់គ្រាន់តែប្រាប់ខ្ញុំប៉ុណ្ណឹងទេ។

**ស៖** អ្នកបររទេះហ្នឹង គាត់មានប្រាប់លោកច្បាស់ៗថា កូន ហើយនិង សាន និងកូនៗហ្នឹងត្រូវបានគេយកទៅណា? គេធ្វើអីចំពោះអ្នកទាំងអស់ហ្នឹងទេ?

**ឆ៖** បាទ គាត់គ្រាន់តែប្រាប់ថា ទៅដល់ព្រៃមួយនុំង សន្តិសុខនុំងមកទទួល គ្នាពីរនាក់មកទទួលៗឈ្មោះ សាន ហើយនិងកូនហ្នឹង ហើយគាត់ក៏វិលត្រឡប់មកផ្ទះវិញ។ ប៉ុន្តែត្រង់កូននុំងមិនដឹងយកទៅឯណា ត្រង់ណា គឺគាត់អត់បានដឹងដែរ។

[១៤:១៤:១៩]

**ស៖** លោកចាំឈ្មោះអ្នកបររទេះសេះហ្នឹងទេ? ហើយចុះព្រៃហ្នឹងឈ្មោះអីដែរ?

**ឆ៖** បាទ ព្រៃហ្នឹងឈ្មោះន៎ត្រពាំងព្រីង – ព្រៃត្រពាំងព្រីង។ ហើយអ្នកបររទេះសេះ គឺខ្ញុំបាទស្គាល់ច្បាស់គឺឈ្មោះ ទ្រី។ ទ្រី ហ្នឹងឥឡូវគេសម្លាប់ចោលដែរ ទ្រី ហ្នឹង រយៈពេលមួយខែក្រោយមកគេសម្លាប់ ទ្រី ចោលដែរ។

**ស៖** ទ្រី ហ្នឹងជាម្នាក់ក្នុងចំណោមឈ្លបទាំងបីហ្នឹង ឬក៏ជាអ្នកទី៤?

**ឆ៖** ខ្ញុំបាទដឹងច្បាស់ ទ្រី ហ្នឹងគឺប្រជាជនយើងធម្មតា ប្រជាជនយើងធ្វើស្រែធ្វើអីហ្នឹង ប៉ុន្តែអានេះគាត់មានរទេះសេះសម្រាប់ប្រធានកង គាត់រកទៅ ក៏ដឹកទៅ។ គឺវាចាប់អ៊ីចឹង វាចាប់ហើយឲ្យគាត់ដឹកទៅ។

**ស៖** ចុះក្រោយមកទៀតហ្នឹង លោកធ្លាប់ឃើញ សាន និងកូនៗទៀតទេ ក្រោយពីខែកញ្ញា ឆ្នាំ៧៧ មកនោះ?

**ឆ៖** បាទ មិនដែលឃើញទេ អត់ឃើញ។

**ស៖** មុននេះលោកបាននិយាយអំពីប្រតិកម្មរបស់បងប្រុសរបស់លោក គឺគាត់សន្លប់ ហើយក្រោយមកដើរទៅ២គីឡូ។ អ៊ីចឹងលោកអាចរៀបរាប់អំពីបងប្រុសរបស់លោកបានទេ ក្រោយពីគេចាប់ខ្លួនប្រពន្ធ ហើយនិងកូនរបស់គាត់ទៅនោះ?

[១៤:១៦:២២]

**ឆ៖** ខ្ញុំបាទអាចរៀបរាប់អំពីបងឈ្មោះ ឡាច នី ហ្នឹងបាន។ ព្រោះ ឡាច នី ហ្នឹងដល់ដួលសន្លប់ហើយ គាត់ដើរប្រហែល២គីឡូ ដល់យប់ប្រហែលជាម៉ោងប្រាំមួយល្ងាច គាត់វិលត្រឡប់មកវិញ មកផ្ទះវិញ។ មកផ្ទះគាត់ហ្នឹង ទៅជាហៅថា វិកលចរិត។ វិកលចរិតអស់រយៈ៥ខែ ក៏វិកលចរិត ហើយដើរឱបតែប្រពន្ធគេ ដើរឱបតែកូនគេ។ គាត់ឆ្កួតគាត់ គាត់អត់ដឹងឯណាលិចកើតទេ។ ដូច្នេះ ឡាច នី ហ្នឹងគឺថារយៈពេល៥ខែ គឺត្រូវវិកលចរិត៥ខែ។

**ស៖** នៅពេលដែលលោកថា គាត់ឱបប្រពន្ធ និងកូនៗគេហ្នឹង លោកចង់បានន័យថាម៉េច? លោកអាចរៀបរាប់ឲ្យបានលម្អិតបន្តិចបានទេ។

**ឆ៖** ដើរអ៊ីចេះ គឺពេលដែលគាត់នឹកពេក កូន ចេះតែហៅកូនៗ។ ប្រពន្ធគេ អូន ប្រពន្ធអ៊ីចឹង។ ហើយកូន កូនៗអ៊ីចឹង ប៉ុន្តែពួកនោះគេដឹងៗ គេមិនប្រកាន់គាត់ទេ ព្រោះដឹងថាគាត់វិកលចរិត វិកលអីព្រោះគេយកប្រពន្ធកូនទៅអស់ហើយ គាត់ចង់វិកលចរិត។ ដូច្នេះហើយ គឺថាគេមិនប្រកែប្រកាន់គាត់ទេចំពោះ ឡាច នី ហ្នឹង។

**ស៖** តើលោកមានដឹងថា បងប្រុសលោកហ្នឹង ព្យាយាមសួរនាំគេថា គេយកប្រពន្ធ និងកូនគាត់ទៅណាទេ?

**ឆ៖** គាត់ ដល់ពេលរយៈពេល៥ខែ គឺគាត់លែងដឹងខ្លួន លែងដឹងថា សួរគេថាយកប្រពន្ធកូនទៅណា អត់ដឹងទេ។ ដល់ក្រោយរយៈពេល៥ខែមក ក៏បានដឹងថា កូនខ្ញុំទៅណាមកណា ដឹង ដឹងខ្លួនមក អាចដឹងថាយកប្រពន្ធខ្ញុំទៅណា យកកូនខ្ញុំទៅណា។ គាត់អាចសួរគេអ្នកជិតខាងដែរ សួរទាំងម្ដាយឪពុកខ្ញុំដែរ។

[១៤:១៨:៤៤]

**ស៖** ៥ខែក្រោយមកនោះ គាត់ដឹងថាប្រពន្ធ និងកូនគាត់នៅឯណាទេ?

**ឆ៖** ៥ខែកន្លែងមក គាត់មិនអាចដឹងថាប្រពន្ធកូននៅឯណាទេ។ គាត់សន្និដ្ឋានខ្លួនគាត់ ថាប្រហែលជាគេយកទៅសម្លាប់ ដែលគាត់និយាយផ្ទាល់ខ្ញុំថា អូនហើយ ប្រហែលជាគេយកប្រពន្ធបងកូនបង ទៅសម្លាប់អស់ហើយ បានអត់ឃើញមកវិញ រយៈពេល៥ខែហើយ។ ហ្នឹងគាត់បាននិយាយជាមួយខ្ញុំបាទផ្ទាល់អ៊ីចឹង។

**ស៖** ហើយក្រោយពីនុំងមកនុំង បងរបស់លោកមានយកប្រពន្ធថ្មីទៀតទេ?

**ឆ៖** បាទ ក្រោយមកឆ្នាំ៧៨ ៗហ្នឹងខាងអង្គការហ្នឹង គេរៀបការឲ្យៗប្រពន្ធមួយ យកប្រពន្ធក្រោយទៀត។ បានរៀបការឲ្យ។

**ស៖** ជាភាសាបារាំង ខ្ញុំឮឆ្នាំ៧៨ ហើយនិងឮពាក្យអង្គការ។ ដូច្នេះដូចជាមិនស៊ីចង្វាក់គ្នា លោកដើមបណ្ដឹងរដ្ឋប្បវេណី។ អ៊ីចឹងខ្ញុំសួរម្ដងទៀត ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បងប្រុសរបស់លោកមានយកប្រពន្ធទៀតទេ?

**ឆ៖** បាទ យកៗប្រពន្ធមួយទៀត។

**ស៖** គាត់យកប្រពន្ធហ្នឹង ប្រពន្ធដែលគាត់រើសដោយខ្លួនឯង ឬក៏អង្គការជាអ្នករើសឲ្យគាត់?

**ឆ៖** បាទ ប្រពន្ធហ្នឹង គឺអ្នកអង្គការអ្នករៀបចំឲ្យគាត់ទេ គឺថ្ងៃហ្នឹង គឺការ២០គូ ការថ្ងៃហ្នឹងនៅវត្តស្វាយអន្ទរ។ ការ២០គូ អង្គការហៅទៅប្រជុំទៅ បានរៀបការឲ្យតែម្ដងថ្ងៃនុំង។

[១៤:២១:២១]

**ស៖** ក្រោយពីរៀបការរួច បងប្រុសលោកមាននិយាយអំពីរឿង សាន និងកូនៗប្រាប់លោកទៀតទេ?

01253241



**ឆ៖** ពេលដែលការហើយហ្នឹង គាត់ក៏នៅអាឡោះអាល័យកូនប្រពន្ធរបស់គាត់ខ្លាំងណាស់ គឺក្នុងការយកប្រពន្ធក្រោយហ្នឹង គឺស្រឡាញ់ដែរ ប៉ុន្តែស្រឡាញ់ប្រហែល៧០ភាគរយ ប៉ុណ្ណឹងទេ។ គាត់នៅអាឡោះអាល័យប្រពន្ធដើមរបស់គាត់និងកូនណោះ មិនទាន់អស់មិនទាន់ហើយផង។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះខ្ញុំចង់ត្រឡប់មកនិយាយអំពីរឿងមួយដែលលោកបាននិយាយហើយ ហើយខ្ញុំសុំការបំភ្លឺពីលោក លោកនិយាយអំពីកូនច្បងរបស់ សាន ដែលធ្វើការនៅចម្ងាយ២គីឡូម៉ែត្រ នៅថ្ងៃដែលឈ្លបមកយក សាន និងកូនៗ។ អ៊ីចឹងថ្ងៃនុំងលោកមានបានឃើញឈ្លបហ្នឹង ត្រឡប់មកហើយនាំកូនច្បងរបស់ ឡាច នី និង សាន ហ្នឹងមកទេ?

**ឆ៖** បាទ ខ្ញុំបាទឃើញ គឺឈ្លបឈ្មោះ ង៉ុយ ហ្នឹង – ឈ្មោះ ង៉ុយ អ្នកទៅយក ហើយពីរនាក់ដែលខ្ញុំបាទអត់ស្គាល់ហ្នឹង គឺអ្នកនាំរទេះសេះទៅ។ ហើយឈ្មោះ ង៉ុយ ហ្នឹងអ្នកទៅយកកូនបងហ្នឹង កូនបងឌុបៗកង់ ឌុបកង់មក ហើយតាមក្រោយ។ ប៉ុន្តែ*(ឮមិនច្បាស់)*ប្រហែលជាទៅឆ្ងាយហើយ បានកូនទៅៗតាមក្រោយ។ ឃើញច្បាស់ បាទខ្ញុំបាទឃើញច្បាស់។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះលោកឆ្លើយថា មានពីរគ្រួសារទៀតដែលៗជាជនជាតិវៀតណាម នៅក្នុងភូមិពោធិ៍ចិន្តាំ។ ដូច្នេះខ្ញុំចង់ដឹងថា លោកដឹងថាមានរឿងអ្វីកើតឡើងចំពោះគ្រួសារវៀតណាមទាំងពីរហ្នឹងទេ?

[១៤:២៣:៤០]

**ឆ៖** បាទខ្ញុំបាទដឹង។ ដែលខ្ញុំបាទដឹងគឺថាឈ្មោះ វ៉ាន់ ង៉ាង ហ្នឹង ពេលដែលគាត់កំពុងធ្វើស្រែៗហ្នឹងគឺឃុំ ឃុំហ្នឹងបញ្ជាឲ្យភូមិហ្នឹងទៅហៅ វ៉ាន់ ង៉ាង ហ្នឹងដើម្បីទៅរកកាប់រពាក់ៗយកមកធ្វើបង្គី គឺទៅពីផ្ទះទៅចម្ងាយប្រហែល៣០គីឡូ ឲ្យទៅៗៗកាប់រពាក់ហ្នឹងយកមកធ្វើបង្គី ហើយទៅគឺថាបាត់តែម្តង បាត់ទាល់ៗឥឡូវ។

**ស៖** ម៉េចបានជាលោកដឹងអំពីរឿងរ៉ាវដែលកើតឡើងចំពោះឈ្មោះ ង៉ាង ហ្នឹង? អ្នកណាជាអ្នកនិយាយប្រាប់លោក?

**ឆ៖** បាទខ្ញុំបាទ គ្មានអ្នកណានិយាយប្រាប់ទេ ប៉ុន្តែខ្ញុំបាទអាចដឹងពីព្រោះនៅភូមិជាមួយខ្ញុំបាទប្រចាំៗថ្ងៃ រាល់ ជួបគ្នារាល់ថ្ងៃ។

**ស៖** ដូច្នេះមានន័យថា លោកឃើញ ង៉ាង ហ្នឹងជារៀងរាល់ថ្ងៃនៅក្នុងភូមិ ហើយក្រោយមកពេលបាត់ខ្លួន ទើបលោកដឹងអំពីរឿងដែលកើតឡើងចំពោះ ង៉ាង ហ្នឹងអ៊ីចឹងមែនទេ?

**ឆ៖** បាទ។ ពីព្រោះន័ែ ប្រធានភូមិហ្នឹងគាត់ហៅឈ្មោះ ង៉ាង ហ្នឹង ហៅឈ្មោះ ង៉ាង ឲ្យទៅកាប់រពាក់យកមកធ្វើបង្គី។ ហើយពេលមិត្ត ង៉ាង ហ្នឹងទៅហ្នឹង គឺខ្ញុំបាទក៏បានឃើញដែរ ឃើញដើរទៅគ្នាខ្មែរខ្លះ វៀតណាមខ្លះ គឺដើរទៅៗមានៗខោអាវ បង្វេចខោអាវហ្នឹងដើរទៅ ដើរឃើញផ្ទាល់តែម្តងដើរទៅ។

**ស៖** លោកអាចជម្រាបបានទេ នៅពេលនុ៎ងម៉េចបានជាលោកឃើញ ង៉ាង ហ្នឹងចេញទៅកាប់រពាក់ហ្នឹង? លោកអាចរៀបរាប់ឲ្យបានលម្អិតបន្តិចបានទេ អំពីអ្វីដែលលោកបានឃើញនៅពេលនោះ?

[១៤:២៦:១៧]

**ឆ៖** បាទ ខ្ញុំជម្រាប។ ពេលដែលខ្ញុំបាទបានឃើញ ង៉ាង ហ្នឹង ពីព្រោះរដ្ឋអំណាចភូមិនោះ រដ្ឋអំណាចភូមិនោះគាត់អ្នកទៅហៅឈ្មោះ វ៉ាន់ ង៉ាង ហ្នឹង។ ហៅ វ៉ាន់ ង៉ាង ពីព្រោះខ្ញុំបាទនៅនុ៎ងដែរ នៅនុ៎ង មិនមែននៅអីទេ នៅដើរឆ្លងកាត់ដើម្បីទៅច្រូតស្រូវនៅឆ្ងាយពីផ្ទះខ្ញុំប្រហែលជាបីបួនរយម៉ែត្រ។ ដល់ឃើញ វ៉ាន់ ង៉ាង ដើរទៅ ខ្ញុំបាទក៏សួរៗប្រធានភូមិហ្នឹង សួរថា អ្ហែ!ពួកគេទៅណា? គេថាពួកយើងទៅម្នាក់ដែរ ឈ្មោះ វ៉ាន់ ង៉ាង ទៅគេឲ្យកាប់រពាក់។ ខ្ញុំសួរប្រធានភូមិហ្នឹង ប្រធានភូមិគាត់ទៅមកៗជួបតែគ្នារាល់ថ្ងៃ បានមិនចាប់អារម្មណ៍ថាគេយក វ៉ាន់ ង៉ាង ទៅណាៗ ខ្ញុំបាទមិនដឹងទេ ប៉ុន្តែការពិតហ្នឹងគឺយកទៅកាប់រពាក់ ទៅបាត់ទាល់ឥឡូវទៅ។

**ស៖** លោកនិយាយអំពីគ្រួសារមួយទៀតដែលជាគ្រួសារវៀតណាមនៅក្នុងភូមិ។ ដូច្នេះខ្ញុំចង់ដឹងថាតើលោកដឹងអំពីរឿងហេតុដែលកើតឡើងចំពោះគ្រួសារវៀតណាមហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំបាទដឹងឈ្មោះៗ ជុយ។ គាត់ ជុយ ហ្នឹងមិនខុសប្លែកពី វ៉ាន់ ង៉ាង ទេ។ រយៈពេល វ៉ាន់ ង៉ាង ទៅប្រហែលមួយខែក្រោយមក បានគេហៅ ជុយ – ឈ្មោះ ជុយ ហ្នឹង។ ជុយ ហ្នឹងទៅៗទៀតដើម្បីទៅរកកាប់ឈើកាប់ព្រៃអីចឹង។ កាលហ្នឹង ជុយ ហ្នឹងគេឲ្យទៅកាប់ផ្ទៀរនង្គ័ល គេហៅយាមនង្គ័ល កាប់យាមនង្គ័លអីៗនៅព្រៃក្របៅហ្នឹងដែរ។ បាទមិនខុសពី វ៉ាន់ ង៉ាងទេ ដូច វ៉ាន់ ង៉ាង អីចឹងប្រធានភូមិទៅហៅដូចគ្នាអីចឹងៗ។ ហើយដល់នេះគ្រួសារ ជុយ ហ្នឹងគឺគាត់នៅក្រុមជាមួយខ្ញុំៗដើម្បីបង្កបង្កើនផល ប៉ុន្តែដឹងៗថាប្តីរបស់គាត់ហ្នឹងប្រធានភូមិគាត់ហៅទៅកាប់ឈើបាត់ហើយ។ ហ្នឹងប្រពន្ធនិយាយប្រាប់ខ្ញុំផ្ទាល់អីចឹង។

[១៤:២៨:៣៥]

**ស៖** គ្រួសាររបស់ ជុយ ហ្នឹងជាអ្នករៀបរាប់រឿងហ្នឹងប្រាប់លោកមែនទេ?

**ឆ៖** បាទ គ្រូសារ ជុយ ហ្នឹងជាអ្នករៀបរាប់ប្រាប់ខ្ញុំបាទ ពីព្រោះនៅក្រុមៗបង្កបង្កើនផល ជាមួយគ្នា។

**ស៖** សូមអរគុណ។ លោកចាំទេអំពីហេតុការណ៍ដំបូងនោះដែលលោកបានឃើញ គឺកើតឡើង មុន ឬក៏ក្រោយពេលដែលបាត់ខ្លួន សាន?

**ឆ៖** ពេលដែលបាត់ខ្លួន សាន ហ្នឹងខ្ញុំបាទ ពេលមុនគឺអត់មានអ្វីសោះ គ្មានមូលហេតុអ្វីសោះ ដូចប្រជាជនយើងធម្មតា គ្មានដឹងដំណឹងថា សាន គេយកទៅយ៉ាងម៉េចៗក៏អត់ដឹងដែរ អត់មានទាស់។ ដល់ពេលល្ងាចមកយកទៅបានដឹងថា សាន ហ្នឹងមូលហេតុថាអង្គការថាយកទៅរៀនសូត្រ ថាអង្គការ ហៅទៅរៀនសូត្រ។ ប៉ុន្តែការពិតហ្នឹង គឺថាខ្ញុំបាទមុនហ្នឹងអត់ដឹងទេ អត់ដឹងមូលហេតុយ៉ាងម៉េចបាន ហៅ សាន ទៅរៀនសូត្រទេ អត់ដឹង។

**ស៖** លោកបាននិយាយអំពីហេតុកាណ៍ពីរផ្សេងទៀត។ ដូច្នេះខ្ញុំចង់ដឹងថា តើប្ដីប្រពន្ធរបស់អ្នក ពីរនាក់ដែលគេចាប់ខ្លួនទៀតនោះ ង៉ាង ហើយនិង ជុយ នោះ គេមានចាប់ទៅទាំងប្ដីប្រពន្ធទេ?

**ឆ៖** បាទ គេអត់ចាប់ទេ។ អាហ្នឹងលក្ខណៈវាមានពីរៗចំណែក។ ទី១ បើសិនជាប្ដីហ្នឹង វៀតណាម គេយកតែប្ដីទេ អត់មានយកប្រពន្ធទេ ប៉ះពាល់ប្រពន្ធទេ។ បើសិនជាប្រពន្ធហ្នឹងវៀតណាម គឺគេយកទាំងកូន ទាំងប្រពន្ធ។

**ស៖** សូមអរគុណ។ ដូច្នេះអ្វីដែលលោកបាននិយាយនេះ ជាការសង្កេតផ្ទាល់របស់លោក ឬក៏ លោកស្ដាប់ពួកម្នាភិបាលគេនិយាយអ៊ីចឹង?

[១៤:៣១:១៧]

**ឆ៖** ខ្ញុំបាទ តាមខ្ញុំសង្កេតមើល មិនមែនៗកម្មាភិបាលនិយាយទេ គឺថាខ្ញុំបាទប្រជាជនក៏ដូចរូប ខ្ញុំបាទដែរ អាចដឹងៗថា បើសិនជាប្ដីហ្នឹងខ្មែរ គឺអត់មានយកកូនទៅជាមួយៗទេ អត់មានទេ។ ហើយបើ ប្រពន្ធហ្នឹងវៀតណាម គឺទាំងកូន ទាំងប្រពន្ធ យកទៅ។ ហើយបើសិនជាប្ដីហ្នឹងវៀតណាម ប្រពន្ធនុំង ខ្មែរ គឺយកតែប្ដីទេ អត់មានយកកូនទេ។

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរចុងក្រោយ។ លោកបានឆ្លើយ ថា លោកបានរស់នៅក្នុងរបបខ្មែរក្រហម នៅក្នុងផ្ទះជាប់គ្នាជាមួយនឹងបងរបស់លោក ហើយខ្ញុំដឹងថា បងរបស់លោករៀបការម្ដងទៀត ក្នុងអំឡុងរបបខ្មែរក្រហម។ ចុះខ្ញុំចង់ដឹងថា លោកនេះ លោកនៅភូមិ ពោធិ៍ចិន្ដាំហ្នឹងរហូត ឬក៏លោកចេញទៅភូមិណាផ្សេង នៅពេលណាមួយ?

**ឆ៖** ខ្ញុំបាទរស់នៅភូមិពោធិ៍ចិន្តាំហ្នឹង តាំងពីម៉ែឪដូនតាខ្ញុំបាទនៅតែហ្នឹងតែម្តង អត់ដែលទៅណាទេ នៅភូមិពោធិ៍ចិន្តាំហ្នឹង។ កកើតនៅហ្នឹងតែម្តង នៅភូមិពោធិ៍ចិន្តាំហ្នឹង។

**ស៖** ចុះអ្នកភូមិ គេមានបានជម្លៀសចេញទេ ក្នុងរបបខ្មែរក្រហម?

**ឆ៖** បាទ ក្នុងរបបខ្មែរក្រហមហ្នឹងឆ្នាំ៧៨ ខែ១០ បានជម្លៀសចេញទៅច្រើន ទៅចង់អស់ នៅសល់ប្រហែលជា២០ភាគរយទេ ដែលនៅក្នុងភូមិពោធិ៍ចិន្តាំហ្នឹង។ ដូច្នេះ៨០ភាគរយ ត្រូវជម្លៀសចេញទៅនៅខេត្តបាត់ដំបង នៅៗគេហៅស្រុកមោង – មោងឫស្សីហ្នឹង ខេត្តបាត់ដំបងហ្នឹង គឺថានៅខាងអាងទំពែង។ អាងទំពែង ផ្លូវចូលតាមកាឡោមភ្លុក ទៅស្រម៉ម៉ាស ហើយទៅអាងទំពែងហ្នឹង។ បាទ ត្រូវរួមរស់នៅក្នុងព្រៃនោះ។

[១៤:៣៣:៤៩]

**ស៖** ចុះលោក គេមានជម្លៀសលោកអត់ នៅឆ្នាំ៧៨នុ៎ង?

**ឆ៖** ខ្ញុំបាទជម្លៀស។ ខ្ញុំបាទទៅទាំងប្រពន្ធ ទាំងកូន ទាំងម្តាយ ទាំងប្អូន។ បាទទៅគឺថា បានស្លាប់ឪពុក ស្លាប់ម្តាយ ប្រពន្ធ កូនខ្ញុំ ប្អូនខ្ញុំ និងកូនក្មួយមួយទៀត គឺទាំងអស់ សរុបទៅទាំង ឡាច នី ផង ១១នាក់ ត្រូវស្លាប់ ទាំងប្រពន្ធ ឡាច នី ផង។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះ ផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោក ណាច គ្រី។ ណាច គ្រី លោកស្តាប់ខ្ញុំឮទេ?

[១៤:៣៥:០៤]

**លោក ឡាច គ្រី៖**

**ឆ៖** បាទ ញូៗ។

**ស៖** ចាស មុននេះលោកបានឆ្លើយនឹងសំណួរ ថាតើមានបងប្អូនសាច់ញាតិរបស់លោកស្លាប់សរុបប៉ុន្មាននាក់? ហើយលោកឆ្លើយថា១១នាក់។ លោកអាចជួយរៀបរាប់ប្រាប់តុលាការបានទេថា អ្នកទាំង១១នាក់នោះមានអ្នកណាខ្លះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ ១១នាក់ហ្នឹងគឺកូន ឡាច នី ហ្នឹងប្រាំនាក់ ប្រពន្ធមួយទៀត ប្រាំមួយនាក់។ ម្ដាយឪពុកខ្ញុំនេះពីរនាក់ទៀត វាប្រាំបីនាក់។ ខ្ញុំពីរនាក់ទៀត វា១០ ហើយប្អូនខ្ញុំមួយទៀត។

**ស៖** តើមានរឿងអ្វីកើតឡើងចំពោះឪពុកម្ដាយរបស់លោកដែរ?

**ឆ៖** ខ្ញុំបាទ ឪពុកម្ដាយហ្នឹងក៏បានគេជម្លៀសទៅនៅបាត់ដំបង។ នៅបាត់ដំបង គេសម្លាប់ចោលនៅខេត្តបាត់ដំបង នៅមោងហ្នឹង។

**ស៖** អ្នកណាជាអ្នកសម្លាប់ឪពុកម្ដាយរបស់លោក ហើយនៅក្នុងឆ្នាំណាដែរ? ហើយដោយសារមូលហេតុអ្វី?

**ឆ៖** ពេលដែលសម្លាប់ឪពុកម្ដាយខ្ញុំ គឺខ្ញុំបាទមិនស្គាល់ឈ្មោះទេ អត់ស្គាល់ឈ្មោះទេ នៅក្នុងខេត្តបាត់ដំបង នៅស្រុកមោង អត់ស្គាល់ឈ្មោះទេ។ ប៉ុន្តែដែលសម្លាប់ឪពុកម្ដាយខ្ញុំហ្នឹង គឺក្នុងឆ្នាំ៨៩ បាទ៨៩ ខែ១២ ស្លាប់ឪពុកម្ដាយខ្ញុំហ្នឹង។ ហើយគ្រួសារខ្ញុំហ្នឹង ក៏ខែ១២ដែរ សម្លាប់ខែ១២ដែរ ហើយប្អូនខ្ញុំបាទហ្នឹង ក៏ខែ១២ ស្លាប់ទៅថ្ងៃតែមួយហ្នឹង។ ប៉ុន្តែឪពុក--

[១៤:៣៧:០០]

**ស៖** លោក ណាច គ្រី -- ចាស សូមទោសដែលកាត់លោកមុននេះ។ លោកមុននេះនិយាយថាក្នុងឆ្នាំណាដែរ ឪពុកម្ដាយរបស់លោកត្រូវគេសម្លាប់ហ្នឹង? លោកនិយាយថា១៩៨៩ ខែ១២ ឬក៏យ៉ាងម៉េច ខ្ញុំសូមឲ្យលោកបញ្ជាក់ចំណុចនេះ?

**ឆ៖** បាទ ដែលសម្លាប់ឪពុកម្ដាយខ្ញុំ ក្នុងឆ្នាំ៨៩ ប៉ុន្តែខែ១០ សម្លាប់ហ្នឹងខែ១០ ដែលខ្ញុំបាទនៅនុំង ខែ១០ ហើយប្រពន្ធខ្ញុំហ្នឹងក៏ ក្រោយគ្នាប្រហែលជាពីរបីថ្ងៃប៉ុណ្ណឹងទេ។

**ស៖** លោក ណាច គ្រី ប្រពន្ធ និងឪពុករបស់លោកហ្នឹងត្រូវសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺរបបខ្មែរក្រហមហ្នឹង ឬក៏ក្រោយហ្នឹង?

**ឆ៖** បាទ កំពុងគេជិតរំដោះហ្នឹង ក្នុងប្រជាធិបតេយ្យហ្នឹង។

**ស៖** ជិតបែក ជិតបញ្ចប់កម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៧៩ហ្នឹងមែនទេលោក?

**ឆ៖** បាទ ជិតៗហ្នឹង ពីព្រោះបែកថ្ងៃ០៧ មករា ដល់នេះគាត់ស្លាប់ប្រហែលខែ១០ហ្នឹង ខែ១០ ហ្នឹង គឺគាត់ស្លាប់។

**ស៖** ចាស អ៊ីចឹង ១៩៧៩ មិនមែន១៩៨៩ទេ មែនទេលោក?

**ឆ៖** បាទ មិនមែនទេ ៧៩មិនមែន៧៩ គឺ៨៩ ប៉ុន្តែខែ -- ៨៩ ខែ១០ អ្នូ៨៩ ខែ១០។ ដល់ឆ្នាំ៩០ នេះវាបែក០៧ មករា។ គិតទៅ ខុសត្រូវគ្នាប្រហែលពីរបីខែប៉ុណ្ណឹងទេ ពេលបែក ពេលរំដោះបាន ០៧ មករាហ្នឹង។

[១៤:៣៨:៥៧]

**ប្រធានអង្គជំនុំ៖**

លោក ឡាច គ្រី គឺលោកមានការភ័ន្តច្រឡំទេដឹង ព្រោះរំដោះ០៧ មករា ខែ១ ឆ្នាំ១៩៧៩។ ហើយបើសិនជាកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីរបីខែមុនពេលរំដោះ ថ្ងៃរំដោះ០៧ មករា ៧៩ ទំនងជាឆ្នាំ ខែ១២ ឬក៏ថា១០ ឬ១១, ១២ ១៩៧៨ទេដឹង ឬក៏យ៉ាងម៉េច? លោកគិតឲ្យបានច្បាស់លាស់ ព្រោះលោកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ វាមិនមែនលោកលេង និយាយឲ្យតែបានៗ នោះទេ។ ហើយសូមបញ្ជាក់សហមេធាវី -- សហព្រះរាជអាជ្ញារងជាតិ គាត់ឈ្មោះ ឡាច គ្រី បើហៅៗ ឲ្យចំ ត្រកូលគាត់ "ឡាច" មិនមែន "ណាច" ទេ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ឆ្លើយៗលោក ឡាច គ្រី! ឆ្លើយបញ្ជាក់មើល សំណួរចម្លើយរបស់លោកហ្នឹង គឺមានភាពច្របូកច្របល់ ហើយយើងក៏អត់យល់ដែរ។ អង្គជំនុំជម្រះអត់យល់ថា ចម្លើយរបស់លោកហ្នឹងយ៉ាងម៉េចទេ ព្រោះអានេះជាកាលវេលាដែលវាត្រូវតែសមស្របជាមួយនឹងស្ថានភាពជាក់ស្តែងដែរ។

**លោក ឡាច គ្រី៖**

**ឆ៖** បាទៗ។ ខ្ញុំបាទ សូមអភ័យទោស ព្រោះ៨៨ទេ មិន៨៩ទេ ៨៨ ខែ១០ ឆ្នាំ៨៨--

**ប្រធានអង្គជំនុំ៖**

៨៨ ឬក៏៧៨ ព្រោះបើ៨៨ របបរដ្ឋកម្ពុជាហើយ។ លោក ៧០ហ្នឹងមុន ឬក៏៧០ក្រោយ? ៧០វា

៨០វាក្រោយឆ្នាំ៧០។ អំឡុងហ្នឹង៧០ហ្នឹងវាផ្សេង។ អំឡុងរបបកម្ពុជាជាធិបតេយ្យពីឆ្នាំមួយពាន់ – ១៧ មេសា ៧៥ ដល់ថ្ងៃទី០១ មករា ១៩៧៩។

[១៤:៤០:៥៦]

**លោក ឡាច គ្រី៖**

**ឆ៖** បាទ។

**ប្រធានអង្គជំនុំ៖**

លោកឆ្លើយសំណួរអំមិញឲ្យបានច្បាស់លាស់បញ្ជាក់មើល កាលៈទេសៈដែលមានបញ្ហាកើតឡើងចំពោះគ្រួសាររបស់លោក ឪពុកម្តាយ ញាតិសន្តានរបស់លោកនុ៎ង នៅស្រុកមោងឫស្សី នៅពេលណា?

**លោក ឡាច គ្រី៖**

**ឆ៖** បាទ អរគុណលោកប្រធាន។ កាលគេ ខ្ញុំសូមលើកឡើងពីដើមបន្តិច ពី៧៥ហ្នឹង ខែ១១ គឺគេជម្លៀសខ្ញុំបាទទៅ។ ជម្លៀសពី១ស្វាយអន្ទរទៅនៅមោង ស្រុកមោង។ ហើយដល់ទៅខែ១០ ឆ្នាំ៧៨ បាទ សូមទោស៧៨ ដល់៧៨ហ្នឹង គឺឪពុកម្តាយខ្ញុំស្លាប់នៅឆ្នាំ៧៨ សូមអត់ទោស ឆ្នាំ៧៨ លោកប្រធាន គឺខែ១០ ឆ្នាំ៧៨ ឪពុកម្តាយខ្ញុំត្រូវស្លាប់ ប្រពន្ធកូន។

**ប្រធានអង្គជំនុំ៖**

បាទៗ បានហើយ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាករយៈពេលពីនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ។ លោក ឡាច គ្រី ឥឡូវនេះ ដល់ពេលសម្រាកហើយ សូមលោកបន្តផ្តល់សក្ខីកម្មនៅវេលាម៉ោងបីទៀតណា៎។ លោកបន្តនៅម៉ោងបី ឥឡូវសម្រាកប្រហែលជា២០នាទី។

សម្រាកសិនចុះ!

**លោក ឡាច គ្រី៖**

បាទៗ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសួស្តីលោក ឡាច គ្រី តើលោកត្រៀម បានត្រៀមខ្លួនរួចហើយឬនៅ?

**លោក ឡាច គ្រី៖**

បាទ បានត្រៀមហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះផ្តល់វេទិកាជូនទៅខាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចាស សូមអរគុណលោកប្រធាន។ ជម្រាបសួរម្តងទៀត លោក គ្រី។

**លោក ឡាច គ្រី៖**

**ឆ៖** បាទៗ។

**ស៖** មុននឹងសម្រាកនេះ យើងបានពិភាក្សាគ្នាដល់សមាជិកគ្រួសាររបស់លោកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម។ មុននេះលោកនិយាយដល់ឪពុកម្តាយរបស់លោក ហើយចុះកូនៗរបស់លោកហ្នឹងស្លាប់នៅក្នុងឆ្នាំណាដែរ? ហើយប៉ុន្មាននាក់ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

**ឆ៖** បាទ កូនខ្ញុំស្លាប់ៗតែមួយ ម្នាក់ – ប្រពន្ធនិងកូន នៅឆ្នាំជាមួយម្តាយខ្ញុំ ជាមួយគ្នាហ្នឹង ៧៩ ដូចគ្នា។

[១៥:០២:៥៥]

**ស៖** លោកថាគាត់ត្រូវគេសម្លាប់ហ្នឹង នៅកន្លែងជាមួយគ្នានៅស្រុកមោងឫស្សីខេត្តបាត់ដំបងហ្នឹង ឬក៏នៅទីតាំងផ្សេងពីគ្នា?

**ឆ៖** ស្លាប់នៅអាងទុំលែងជាមួយគ្នា។

**ស៖** ចាសអរគុណ។ លោក គ្រី ខ្ញុំចង់ពិភាក្សាត្រឡប់ក្រោយបន្តិចទាក់ទងទៅនឹងប្រជាជន និងគ្រួសារវៀតណាមនៅក្នុងភូមិដែលលោក ភូមិកំណើតរបស់លោក។ តើមុនខ្មែរក្រហមមកដល់ឆ្នាំ

១៩៧០, ៧១ ដែលលោកបានប្រាប់តុលាការមុននេះ តើមានគ្រួសារ ឬក៏ជនជាតិវៀតណាមរស់នៅក្នុងភូមិរបស់លោកដែរឬទេ?

**ឆ៖** បាទ មុនឆ្នាំ៧០មាន ដល់ពេលឆ្នាំ៧០ហ្នឹង គឺគាត់រត់ទៅនៅប្រទេសវៀតណាមអស់ប្រហែលជា១០គ្រួសារ រត់ទៅនៅប្រទេសវៀតណាម។ ដល់រំដោះហើយបានត្រឡប់មកវិញ ឥឡូវត្រឡប់មកវិញហើយ។

**ស៖** ចុះមុនឆ្នាំ៧០ហ្នឹង តើប្រជាជន ឬក៏គ្រួសារវៀតណាមដែលរស់នៅក្នុងភូមិរបស់លោកហ្នឹង គាត់រស់នៅជាធម្មតាទេ ឬក៏មានស្ថានភាពលំបាកក្នុងការរស់នៅដែរ ឬក៏រស់នៅអាចចុះសម្រុងជាមួយនឹងប្រជាពលរដ្ឋកម្ពុជាយើងដែរ?

**ឆ៖** បាទ គាត់រត់ទៅនៅប្រទេសគាត់វិញ ដោយសារមិនមែនទេ គាត់ថាខ្លាចពិបាក ខ្លាចអីចឹង ដល់នេះគាត់ទៅ នាំគ្នាទៅវិញអស់ទៅ គាត់នៅរយៈពេលបួនដប់ឆ្នាំអីអីចឹងទៅ គាត់រត់ទៅនៅប្រទេសគាត់វិញអស់ទៅ។

[១៥:០៤:៤៣]

**ស៖** អ៊ីចេះទេលោក គ្រី ខ្ញុំចង់សួរលោកថា នៅក្នុងអំឡុងពេលមុនខ្មែរក្រហមចូលមកដល់ភូមិរបស់លោក លោកថា៧០, ៧១ហ្នឹង ប្រជាជនវៀតណាម ឬក៏គ្រួសាររបស់វៀតណាមដែលរស់នៅក្នុងភូមិលោកហ្នឹង គាត់រស់នៅប្រកបរបរធម្មតាទេ ការរស់នៅស្ថានភាពជាមួយនឹងប្រជាពលរដ្ឋខ្មែរយើងហ្នឹងចុះសម្រុងនឹងគ្នាដែរឬទេ ឬក៏មានការលំបាកអីដែរអត់ទេ?

**ឆ៖** បាទ ចំពោះវៀតណាមដែលរស់ក្នុងភូមិរបស់ខ្ញុំបាទហ្នឹងគឺធម្មតា រាប់អានគ្នាធម្មតា ចុះសម្រុងគ្នាធម្មតា។ ហើយគាត់រកស៊ីច្រើនលក់ត្រី លក់បន្លែអីនាយអាយអីចឹង ធម្មតាដូចប្រជាពលរដ្ឋខ្មែរដែរ។

**ស៖** ចុះក្រោយពីរបបខ្មែរក្រហមបានដួលរលំឆ្នាំ១៩៧៩ហើយ លោកថាពួកគាត់ហ្នឹងមានត្រឡប់មកវិញ ហើយក្រោយពីពួកគាត់ត្រឡប់មកវិញហ្នឹង ការរស់នៅរបស់ពួកគាត់ជាមួយប្រជាពលរដ្ឋខ្មែរហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** បាទ ត្រឡប់មកវិញ គឺថាកន្លែងដីរបស់គាត់ដែលគាត់នៅពីមុនឆ្នាំ៧០មក ដីរបស់គាត់ដែលគាត់ទិញបានពីជំនាន់ពីសង្គមរាស្ត្រនិយមគឺថាបាន។ ទិញបានហើយ គាត់មកនៅកន្លែងដីគាត់វិញ គេអត់មានតោងទាមយកទេដីនុំង។ គឺគាត់មកនៅតាមសម្រួល តាមកូនតាមចៅគាត់វិញធម្មតាវិញ អត់

មានពិបាកអីទេ ហើយក៏រកស៊ីហ្នឹងគឺថាលក់ត្រីបន្លែអីជាមួយបងប្អូនខ្មែរធម្មតា រាប់អានគ្នាស្រឡាញ់គ្នាធម្មតាជាមួយខ្មែរយើងហ្នឹង។

[១៥:០៦:១៤]

**ស៖** ចាស ឥឡូវខ្ញុំចង់និយាយរឿងជនជាតិវៀតណាម ឬក៏គ្រួសារវៀតណាមនៅក្នុងអំឡុងរបបខ្មែរក្រហមហ្នឹងគឺពី១៧ មេសា ៧៥ ដល់៧៩នោះ នៅក្នុងចន្លោះអំឡុងឆ្នាំពេលហ្នឹង តើមានប្រជាជនវៀតណាមរស់នៅក្នុងភូមិរបស់លោកហ្នឹង លោកដឹងទេថាមានប្រហែលប៉ុន្មានគ្រួសារដែរ?

**ឆ៖** បាទនៅក្នុងភូមិរបស់ខ្ញុំមានតែបីគ្រួសារហ្នឹង អត់មានច្រើន មានតែបីគ្រួសារហ្នឹងទេដែលរស់នៅហ្នឹង។ ហើយវៀតណាមក្នុងរបបប៉ុល ពត ហ្នឹងគឺអត់មាន -- ទាហានៗដើរឆ្លងកាត់លិចកើតៗហ្នឹង ត្រង់ឲ្យមាននេះ អត់មានទេ អត់មានដែលនៅមកនៅផង កន្លែងខ្ញុំ។

**ស៖** ចាស បីគ្រួសារហ្នឹង លោកបានពិភាក្សាមុនហ្នឹងបន្តិចហើយ គឺឈ្មោះអួង -- ឈ្មោះ ង៉ាង ឈ្មោះ ជុយ ហើយនិងបងថ្លៃរបស់លោកឈ្មោះ សាន ហើយអ៊ីចឹងមែនទេ?

**ឆ៖** បាទៗមែន ពិតមែន។

**ស៖** ឈ្មោះ ជុយ ហ្នឹងលោកថាជាជនជាតិវៀតណាម ហេតុអីបានជាលោកដឹងថាគាត់ជាជនជាតិវៀតណាម? ហើយគាត់កាត់ទៅខាងណា ឬក៏មានប្រភពមកពីខាងណាដែរ មកពីវៀតណាមសុទ្ធ ឬក៏មានឪពុកម្ដាយជាវៀតណាម?

**ឆ៖** បាទ ដែលខ្ញុំបាទដឹងពីព្រោះ ជុយ ហ្នឹងប្រពន្ធ ជុយ ហ្នឹងជាជីដូនមួយរបស់ខ្ញុំ។ ដូច្នេះ ជុយ ហ្នឹងកាលគាត់មកហ្នឹងគាត់រកស៊ី អ្នករកស៊ីទេ រកស៊ីមកនៅប្រទេសកម្ពុជាយើងហ្នឹង មកនៅកន្លែងភូមិរបស់ខ្ញុំបាទហ្នឹង។ ហើយដល់ក្រោយមកគាត់មានប្រពន្ធឈ្មោះ ដួង អឿន ហ្នឹងជាប្រពន្ធរបស់គាត់។ បានហើយគាត់ហ្នឹងនិយាយភាសាហ្នឹងនិយាយអត់ច្បាស់ដូចខ្មែរ ប៉ៃឡាំ ភាសាវៀតណាម និយាយប៉ៃឡាំៗ។ បានខ្ញុំបាទដឹងគាត់ថាគាត់វៀតណាម ហើយគាត់ការពិតគាត់ច្រើននិយាយវៀតណាមមែនគាត់ហ្នឹង។

**ស៖** ហើយមុននេះ លោកក៏បានប្រាប់តុលាការដែរថា ជុយ ហ្នឹងត្រូវមេភូមិហៅទៅ ហើយហៅទៅកាប់ឈើ។ ហើយក្រោយមកទៀតហ្នឹងលោកមានដែលបានជួប ជុយ ទេ? ហើយមានរឿងអីកើតឡើងចំពោះ ជុយ?

**ឆ៖** ខ្ញុំបាទមិនដែល -- អត់មានរឿងអីកើតឡើងទេ គឺថាបាត់សូន្យតែម្ដង ទៅកាប់ឈើហ្នឹង

បាត់សូន្យតែម្តង។ មិនដឹងទៅណាៗ អត់ដឹងដែរ ថាទៅកាប់ឈើៗទៅបាត់តែម្តង។

**ស៖** ចុះប្រពន្ធ និងកូនរបស់ ជុយ?

**ឆ៖** បាទ ប្រពន្ធកូនរបស់ ជុយ នៅសព្វថ្ងៃហ្នឹង ដូង អឿន កូនមានកូនមួយ កូនស្រីមួយ។

**ស៖** ចុះក្រុមគ្រួសាររបស់ វ៉ាន់ ង៉ាង ហ្នឹង គ្រួសាររបស់គាត់ហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** បាទ ចំពោះគ្រួសារ វ៉ាន់ ង៉ាង ហ្នឹងគឺប្រពន្ធទៅនៅសៀមរាបបាត់ហើយ ខ្ញុំបាទអត់ដឹងដំណឹងយ៉ាងម៉េចៗទេ អត់ដែលៗមកផង ទៅនៅសៀមរាបហើយប្រពន្ធ វ៉ាន់ ង៉ាង ហ្នឹង។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស អរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ សូមផ្ទេរវេទិកានេះឲ្យទៅសហការីអន្តរជាតិរបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។ សូមអរគុណដើមបណ្តឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះ អញ្ជើញ សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៥:០៩:៤៧]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី នៅក្នុងរបបនោះ ថាលោកធ្លាប់សង់ផ្ទះដែរឬទេ?

**លោក ឡាច នី៖**

**ឆ៖** ខ្ញុំបាទ ក្នុងរបបនោះបានសង់ផ្ទះ ប៉ុន្តែផ្ទះនៅលើៗដំបូក កាប់ដំបូក ទៅធ្វើផ្ទះទាបតូចៗមួយ ប្រហែលជាទទឹង១,៥ម៉ែត្រហ្នឹង បណ្តោយ២ម៉ែត្រប៉ុណ្ណឹងទេ ផ្ទះតៀមតូចៗ នៅៗអាងទុំលែងស្រុកមោង។

**ស៖** តើលោកធ្លាប់ឃើញមានអ្វីកើតឡើងចំពោះប្រជាជនដទៃទៀតទេ នៅពេលដែលលោកសង់ផ្ទះនោះ?

**ឆ៖** ពេលបានពួកខ្ញុំជម្លៀសទៅហ្នឹង ទៅនៅ ខ្ញុំបាទមានអ្នកសង់ផ្ទះហ្នឹង ប្រជាជនន៎ុងគឺថាបានធ្វើស្រែ ធ្វើអី ច្រូតស្រូវ ច្រូតអីន៎ុង សកម្មភាពរបស់ប្រជាជនន៎ុង ដូចជាធម្មតា អត់ៗមានបញ្ហាអី។

**ស៖** សូមអរគុណ។ តើលោកខ្លួនលោកផ្ទាល់ ធ្លាប់ឃើញគេសម្លាប់មនុស្សដែរឬទេ នៅក្នុងរបបនោះ?

**ឆ៖** ខ្ញុំបាទមិនដែលឃើញទេសម្លាប់ផ្ទាល់ ប៉ុន្តែគ្រាន់ថា ពេលដែលខ្ញុំបាទរត់ចេញពីៗន៎ុងមក

ផ្លាប់ឃើញសពនៅលើភ្លឺស្រែច្រើន បាទ--

[១៥:១១:៣៤]

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ តើលោកឃើញសាកសពហ្នឹង គឺលោកឃើញនៅតំបន់ណាដែរ?

**ឆ៖** បាទ ខ្ញុំបាទឃើញសាកសពនៅក្នុងៗស្វាយដូនកែវ បាទខ្ញុំរត់ចេញមក នៅក្បែរស្វាយដូនកែវ ខាងជើងស្វាយដូនកែវប្រហែលជា២គីឡូ ដែលខ្ញុំបាទឃើញ។

**ស៖** តើលោកអាចប្រាប់បានទេថា នៅក្នុងខេត្តអ្វីដែរ?

**ឆ៖** បាទ ស្រុកមោងនុំង ស្រុកមោងប្រហែលជាខេត្តពោធិ៍សាត់ ខ្ញុំបាទមិនៗសូវស្គាល់ច្បាស់ដែរ។ បាត់ដំបងមិនដឹង ពោធិ៍សាត់មិនដឹង ពីព្រោះកន្លែងហ្នឹងជាៗកន្លែងព្រំប្រទល់ៗខេត្ត មិនដឹងថាខេត្តបាត់ដំបងមិនដឹង ខេត្តពោធិ៍សាត់មិនដឹង ខ្ញុំបាទអត់ៗដឹង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីដើម -- នែ៎មេធាវី ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ការពិតទៅ មិនមែនជាការជំទាស់អីទេ គឺថាទោះបីសាក្សីគាត់ឆ្លើយមិនច្បាស់ពីរឿងទីតាំងខេត្តនៃស្រុកមួយ។ ប៉ុន្តែអ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺហាក់ដូចជាមានសំឡេងពីក្នុងហ្នឹង បញ្ជាក់ប្រាប់ទៅដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ដូច្នេះបានខ្ញុំគិតថា គួរតែកុំឲ្យមានការឆ្លើយប្រាប់បែបនេះ។ សូមអរគុណ។

[១៥:១៣:១៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក ញ៉ែម សំណាង អត់មានអ្នកណាមកបោះ*ព្រុយយ៉ុង*អីក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទេណ៎ា។ លោក ញ៉ែម សំណាង!

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទៗ អត់មានឲ្យមាននរណាមក ជ្រៀតជ្រែកកិច្ចការទេ ណះ!

សូមអញ្ជើញបន្តទៀតសហព្រះរាជអាជ្ញាអន្តរជាតិ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ទៅកន្លែងមួយដែលមានឈ្មោះថា ឈ្នាង ដែរឬទេ?

**លោក ឡាច គ្រី៖**

**ឆ៖** បាទ ខ្មោចឈ្នាង នុំងកន្លែងក្បែងអាងទុំលែងហ្នឹង--

**កញ្ញា សុង ឆវ័ន្ត៖**

ខ្មោចឈ្នាង គាត់អានត្រូវហើយលោក។

**លោក ឡាច គ្រី៖**

**ឆ៖** ខ្មោចឈ្នាង គេហៅថា ខ្មោចឈ្នាងត្រង់នុំង កន្លែងអាងទុំលែង នៅក្បែរអាងទុំលែង ដែលរូបខ្ញុំបាទទៅនៅក្បែរនោះ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើលោកទេថា នៅទីនោះមានកន្លែងកប់សាកសពមនុស្ស?

[១៥:១៤:៣៤]

**ឆ៖** បាទ កន្លែងខ្មោចឈ្នាងនុំង ដែលខ្ញុំបាទដើរកាត់ខាងមុខ គឺឃើញខ្មោចកប់ច្រើននៅលើទួលនោះ ទួលខ្មោចឈ្នាង។

**ស៖** លោកសាក្សី តើលោកអាចប្រាប់បានទេថា តើនៅក្នុងឆ្នាំៗណាមួយ?

**ឆ៖** ក្នុងឆ្នាំដែលខ្ញុំបានទៅរស់នៅហ្នឹង គឺឆ្នាំ៧៨។

**ស៖** ដូច្នេះគឺហេតុការណ៍ហ្នឹង កើតឡើងក្រោយពេលដែលគេបញ្ជូនលោកទៅបាត់ដំបង មែនទេ?

**ឆ៖** បាទ កាលហ្នឹងដែលគេបញ្ជូនខ្ញុំទៅបាត់ខេត្តដំបងហ្នឹង ហេតុការណ៍ដែលកើតឡើងហ្នឹងគឺមុនហ្នឹងខ្ញុំបាទទៀត។ ខ្ញុំទៅក្រោយទេ ក្រោយហេតុការណ៍ហ្នឹងទេ។ ដល់នេះខ្ញុំទៅ ទៅៗឃើញហេតុការណ៍នៅកន្លែងនុំង វាមុនខ្ញុំបាទទៅទៀត។

**ស៖** តើលោកអាចប្រាប់បានទេ ថាលោកឃើញសាកសពហ្នឹង គឺឃើញសាកសពនៅកណ្តាលវាលតែម្តង ឬមួយក៏យ៉ាងម៉េចដែរ? លោកអាចពន្យល់ឲ្យលម្អិតបន្តិចបានទេ។

**ឆ៖** បាទ ពេលដែលខ្ញុំរត់ចេញពីៗអាងទុំលែងហ្នឹង បានខ្ញុំមកដល់ស្វាយដូនកែវហ្នឹង ឃើញ

សាកសពនៅតាមវាលស្រែហ្នឹង គឺថាដែលខ្ញុំរត់ពីយប់មើលមិនសូវច្បាស់ផង ប៉ុន្តែខ្ញុំរត់កាត់នុំង សាកសពប្រហែលជាសាមសែសិបនាក់ នៅៗនឹងងាប់កណ្ដាលវាលស្រែនុំង។ ហើយរត់ៗទៅ រត់ឆ្លងខ្មោចហ្នឹង បានខ្ញុំបាទចេះមកៗឯកើតមក មកដល់ពោធិ៍សាត់។

[១៥:១៦:៤៨]

**ស៖** សូមអរគុណ។ ខ្ញុំសូមទុកប្រធានបទនេះមួយអន្លើមួយសិន។ ហើយខ្ញុំឥឡូវនេះខ្ញុំត្រឡប់មកនិយាយពីអ្វីដែលលោកបានប្រាប់សហការីរបស់ខ្ញុំ។ លោកបានប្រាប់សហការីរបស់ខ្ញុំថា នៅក្នុងឆ្នាំ ៩០ -- នៅក្នុងឆ្នាំ៧០ គឺមានទំនាក់ទំនងរវាងវៀតណាម ហើយនិងប្រជាជន។ ហើយនៅក្រោយឆ្នាំ៧៩ គឺមានជនជាតិវៀតណាមត្រឡប់មកភូមិវិញ ហើយក៏មានទំនាក់ទំនងល្អឡើងវិញជាមួយនឹងប្រជាជនខ្មែរ នៅក្នុងភូមិរបស់លោក។ ដូច្នេះខ្ញុំចង់សួរលោក ថាតើលោកអាចពន្យល់បានទេ ហេតុអ្វីបានជាប្រជាជនខ្មែរនៅក្នុងភូមិរបស់លោកត្រូវបានគេសម្លាប់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ពេលដែលវៀតណាមមកនៅក្នុងភូមិរបស់ខ្ញុំបាទហ្នឹង ពេលកន្លងមកហ្នឹង អត់មានសម្លាប់ទេ អត់មានសម្លាប់វៀតណាមដែលចូលមកបែកហើយហ្នឹងទេ។ ហើយដល់សកម្មភាពផ្សេងដែលកើតឡើងហ្នឹង គឺថាខ្ញុំបាទអត់ដឹងទេ មិនដឹង អត់ដឹង។ ពីពេលកន្លងមកហ្នឹង គឺថាក៏វៀតណាមចូលមកនៅក្នុងភូមិរបស់ខ្ញុំបាទមែន ប៉ុន្តែសកម្មភាពវាធម្មតា វាអត់ទាមទារសម្លាប់អីទេ។ ដល់ក្រោយមកទៀត គឺប្រជាជនវៀតណាម ហើយនិងប្រជាជនខ្មែរ គឺថារួមរ័ក្សគ្នា រាក់ទាក់គ្នាមិនដែលចេះទំនាស់អ្វី ធ្វើឲ្យបែកបាក់សាមគ្គីអីទេ ពេលកន្លងមកហ្នឹង។

[១៥:១៨:៣២]

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរឲ្យលោកជួយយើងបន្តិច គឺលោកនិយាយអំពីទំនាក់ទំនងល្អរវាងខ្មែរ និងវៀតណាមនៅក្នុងភូមិរបស់លោក ទាំងនៅមុនកម្ពុជាប្រជាធិបតេយ្យ ទាំងក្រោយកម្ពុជាប្រជា-ធិបតេយ្យ។ ហើយលោកបានបញ្ជាក់ផងដែរថា នៅក្នុងឆ្នាំ៧៧, ៧៨ ប្រជាជនវៀតណាមនៅក្នុងភូមិលោកទាំងអស់ត្រូវបានសម្លាប់។ ដូច្នេះក្នុងអំឡុងពេលនុំង ថាតើមេភូមិមានពន្យល់អ្វីដែរឬទេ ថាតើយើងត្រូវចាត់ទុកវៀតណាមថាយ៉ាងម៉េច? តើពួកគេមាននិយាយអំពីវៀតណាមយ៉ាងម៉េច?

**លោក វិចទ័រ កូប៉េះ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំទាន់អាលឆ្លើយតប លោក គ្រី!

អញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក ឡាច គ្រី៖**

បាទ។

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតបណ៎ា!

**លោក ឡាច គ្រី៖**

បាទ។

[១៥:១៩:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងសំណួរនេះ ព្រោះថាដើមបណ្ដឹងរដ្ឋប្បវេណី គាត់មិនដែលនិយាយអំពីប្រជាជនទាំងបីក្រុម ឬក៏ទាំងបីគ្រួសារត្រូវបានសម្លាប់នោះឡើយ។ គាត់គ្រាន់តែឃើញ ហើយគាត់សន្មតថា ពួកគាត់ត្រូវបានគេសម្លាប់ ប៉ុន្តែគាត់មិនដឹង។ ដូច្នេះយើងមិនអាច មេធាវីមិនអាចយកពាក្យ "សម្លាប់" មកបញ្ចូលទៅក្នុងពាក្យសម្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឡើយ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំរីករាយក្នុងការកែតម្រូវ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកបាននិយាយអំពីបងប្រុសរបស់លោក ប្រពន្ធបងប្រុសរបស់លោកត្រូវបានគេយកទៅជាមួយនឹងកូនៗ។ ហើយលោកបាននិយាយអំពីវៀតណាមពីរនាក់ទៀត នៅក្នុងភូមិរបស់លោក ក៏ត្រូវបានគេយកទៅដែរ គឺយកដោយពួកអាជ្ញាធរក្នុងភូមិហ្នឹង ហើយមិនដែលឃើញទេនៅពេលក្រោយមក។ ដូច្នេះខ្ញុំចង់សួរថា តើអាជ្ញាធរនៅក្នុងភូមិរបស់លោកធ្លាប់បាននិយាយអំពីវៀតណាម ឬក៏ហេតុអ្វីបានជាគេធ្វើបែបនេះដាក់ប្រជាជនវៀតណាមនៅក្នុងភូមិរបស់លោកដែរឬទេ?

**លោក ឡាច គ្រី៖**

**ឆ៖** បាទ រឿងអស់ទាំងហ្នឹង ខ្ញុំបាទអត់ដែលឮនិយាយៗទេ អត់ដែល ខ្ញុំបាទអត់ដែលឮនិយាយ

ផង។ អត់ដែលឮនិយាយទេ។

[១៥:២១:០២]

**ស៖** លោកចាំទេថា តើបងប្រុសរបស់លោកមានកូនប៉ុន្មាននាក់នៅពេលដែលគេយកគាត់ទៅ?

**ឆ៖** ពេលបងប្រុសខ្ញុំ គេយកប្រពន្ធ កូនទៅ គឺថាគាត់មានកូនប្រាំនាក់ ហើយប្រពន្ធមួយទៀត ប្រពន្ធ ហើយនិងកូនប្រាំនាក់យកទៅហ្នឹង។

**ស៖** លោក ថាតើនៅពេលក្រោយមក លោកដែលឃើញបងប្រុសរបស់លោក ឬក៏ក្មួយៗរបស់លោកហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដែលដឹងអីទេ រឿងក្មួយៗក៏មិនដឹងដែរ អត់ដឹងសោះ។ គេយកទៅបាត់តែម្តង អត់ដឹង។

**ស៖** តើលោកចាំទេថា ក្មួយៗរបស់លោក កូនបងប្រុសរបស់លោកហ្នឹងមានកូនស្រីប៉ុន្មាន កូនប្រុសប៉ុន្មានដែរ?

**ឆ៖** បាទ ចំពោះកូនរបស់ ឡាច នី ហ្នឹង មានកូនប្រាំនាក់ ស្រីទាំងប្រាំ។

**ស៖** តើលោកដឹងទេ នៅពេលដែលគេយក សាន ទៅហ្នឹង ថាតើ សាន គាត់មានផ្ទៃពោះ ឬក៏អត់ទេ?

**ឆ៖** បាទ ពេលដែលពេលគេយកប្រពន្ធ ឡាច នី ហ្នឹងទៅ គឺថា សាន អត់មានផ្ទៃពោះទេ គឺកូនក៏នៅរយៈពេលប្រហែល២ឆ្នាំទេ កូនតូច។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានសំណួរអ្វីបន្ថែមទៀតទេ។ សូមអរគុណ។

[១៥:២៣:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីជនជាប់ចោទ ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយដំបូងនេះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរតែពីរបីប៉ុណ្ណោះ។ សំណួរទី១របស់ខ្ញុំ គឺដូចតទៅនេះ លោកបានរៀបរាប់អំពីពេលដែល សាន ហើយនិងកូនរបស់គាត់ ត្រូវបានគេដាក់ គេយកដាក់លើរទេះគោ ហើយយកទៅរៀនសូត្រនៅក្នុងខែកញ្ញា ឆ្នាំ៧៧។ តើលោកចាំទេថា នៅក្នុងពេលហ្នឹង ឬក៏ប្រហែលមុនបន្តិច ឬក៏ក្រោយបន្តិចហ្នឹង តើលោកមានបានឮអំពីសំឡេង ឧទាហរណ៍ថា ដូចជាសំឡេងកាំភ្លើងធ្លោង ឬក៏សំឡេងអីបង្ហាញថាមានសង្គ្រាម ឬក៏ការផ្ទុះគ្រាប់បែកពីតំបន់ ឬក៏ពីដែនដីវៀតណាម ចូលមកដែនដីកម្ពុជាដែរឬទេ?

**លោក ឡាច គ្រី៖**

**ឆ៖** បាទ ខ្ញុំបាទអត់ឮទេ អត់ឮ។

[១៥:២៥:០៦]

**ស៖** សូមអរគុណលោក។ សំណួររបស់ខ្ញុំបន្តទៀត តើលោកដឹងទេថា តើ ជុយ គឺមនុស្សម្នាក់ដែលលោកបាននិយាយមុននេះ គឺធ្លាប់ជាទាហានរបស់វៀតណាម?

**ឆ៖** បាទ ខ្ញុំបាទ អត់បានដឹងទេ ត្រង់ទាហាន ឬមួយមិនទាហាន ក៏ខ្ញុំបាទអត់ដឹងដែរ ព្រោះមកគាត់ជាប្រជាជនធម្មតាមកនៅភូមិខ្ញុំបាទហ្នឹង។

**ស៖** សំណួរចុងក្រោយអំពីគាត់ ថាតើគាត់បានចូលរួមនៅក្នុងការរត់ពន្ធទំនិញពីវៀតណាម ចូលមកដីខ្មែរដែរឬទេ? ដូច្នេះគឺថា ចង់សួរថាក្នុងរបបនុ៎ង តើគាត់មានរត់ពន្ធទំនិញពីដីម្ខាង ចូលមកដីម្ខាងទៀតទេ?

**ឆ៖** បាទ រឿងអស់ទាំងហ្នឹង ខ្ញុំបាទអត់ដឹងទេ មិនបានដឹងដែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ សហការីជាតិរបស់ខ្ញុំមានសំណួរមួយចំនួន សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១៥:២៦:៤៣]

**លោក លីវ សុវណ្ណា៖**

បាទ សូមជម្រាបសួរលោកប្រធាន និងអង្គជំនុំជម្រះ។ សូមជម្រាបសួរភាគីទាំងអស់។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំបាទឈ្មោះ លីវ សុវណ្ណា ជាមេធាវីជាតិការពារក្ដីនៅក្នុងក្រុមលោក នួន ជា។ ខ្ញុំបាទសូមតាំងសំណួរពីរបីសំណួរ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលដែលលោក ឡាច នី ជាបងរបស់លោកនាំប្រពន្ធគាត់ទៅរស់នៅស្រុកកំណើតវិញនោះ ពេលនោះតើឪពុកម្ដាយក្មេករបស់លោក ឡាច នី មានបានទៅជាមួយដែរឬទេ?

**លោក ឡាច គ្រី៖**

**ឆ៖** ខ្ញុំសូមជម្រាប លោក ឡាច នី ដែលរត់នៅស្រុកកំណើតពីភ្នំពេញមកនៅពោធិ៍ចិន្ដាំនេះ ជាឪពុកម្ដាយរបស់ខ្ញុំបាទ ឪពុកម្ដាយរបស់ ឡាច នី ហ្នឹង។ ហើយវាគ្មានបញ្ហាអី ធ្វើឲ្យទំនាស់ ទាស់ទែងដល់កូន អត់មានទេ អត់មានសោះ។

**ស៖** ប្រហែលជាលោក ខ្ញុំសួរសំណួរមិនច្បាស់លាស់។ ខ្ញុំចង់សួរថា នៅពេលដែលឆ្នាំ១៩៦៨ ដែលលោកបានថា លោក ឡាច នី ត្រឡប់ទៅវិញជាមួយប្រពន្ធគាត់ហ្នឹង តើពេលនោះឪពុកម្ដាយរបស់លោកស្រី សាន ដែលជាប្រពន្ធរបស់លោក ឡាច នី គាត់បានទៅជាមួយនឹងកូនគាត់ដែរឬទេ?

[១៥:២៨:១៦]

**ឆ៖** បាទ លោក អត់មានទៅ អត់មានទៅជាមួយទេ។ មិនទៅជាមួយ ខ្ញុំបាទក៏អត់ស្គាល់ទេទៀត មិនដែលស្គាល់ មិនដែលឃើញទៀត។

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ឆ្នាំ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើធ្វើម៉េចបានជាគេដឹងថា លោកស្រី សាន ដែលជាប្រពន្ធរបស់លោក ឡាច នី នោះជាជនជាតិវៀតណាម?

**ឆ៖** បាទ ដែលគេដឹងគ្រប់គ្នាហ្នឹង ដោយសារគាត់មកនៅក្នុងភូមិពោធិ៍ចិន្ដាំហ្នឹង គាត់រកស៊ីលក់បន្លែៗ លក់ត្រី ហើយប្ដីលក់ទឹកកក ឡាច នី លក់ទឹកកក។ ដូច្នេះហើយក្នុងការនិយាយស្ដីអី ពេលណាវៀតណាមទៅទិញបន្លែ ទិញអី គាត់ច្រើននិយាយវៀតណាម។ បានប្រជាជនទាំងអស់ហ្នឹង គេអាចដឹងថា គាត់សន្និដ្ឋានថាគាត់វៀតណាម ពីព្រោះគាត់ចេះនិយាយវៀតណាម ហើយនិយាយប៉ែឡាំរបៀបវៀតណាម។

**ស៖** សំណួរខ្ញុំមួយទៀត គឺទាក់ទងនឹងលោក មុននេះលោកបានថ្លែងថា ពេលដែលគេចាប់កូន

របស់ប្អូននាក់របស់ កូនរបស់លោក ឡាច នី ប្អូននាក់ ជាមួយនឹងប្រពន្ធនៅផ្ទះ។ តើលោកៗនឹកមើលថា តើមានកូនណាមួយដែលត្រូវបានយកទៅផ្ញើនៅផ្ទះឪពុកម្ដាយរបស់លោក ដែលជាយាយតារបស់កូន ឡាចៗ នី ទាំងប្អូននាក់ហ្នឹងដែរទេបាទ?

**ឆ៖** ខ្ញុំសូមជម្រាប រឿងកូនម្នាក់ហ្នឹង មិនមែនយកទៅផ្ញើឪពុកម្ដាយទេ ខ្ញុំបាទក៏នៅនឹងដែរ ពីព្រោះកូនហ្នឹងទៅច្រូតចម្ងាយពីផ្ទះហ្នឹងប្រហែលជា២គីឡូ គេហៅថានៅក្នុងកុមារ នៅមណ្ឌលកុមារ។ បាទ អត់មាននៅផ្ញើមាតាបិតាទេ អត់មានទេ គឺកូនហ្នឹង បងបំផុតហ្នឹងយកទៅនៅមណ្ឌលកុមារ ហើយ កូនមួយទៀតហ្នឹង វានៅលេងផ្ទះធម្មតាលេងផ្ទះហ្នឹង កូនតូចៗហ្នឹងអាយុ២ឆ្នាំ ៣ឆ្នាំ ៤ឆ្នាំនៅៗលេងផ្ទះ ហ្នឹងទេ អត់មានទៅណាទេ។ ផ្ទះៗរបស់ខ្លួនគាត់ហ្នឹង ពីព្រោះគាត់ជាប់ផ្ទះខ្ញុំ។

[១៥:៣០:៤២]

**សៈ** បាទ តើលោកនៅចាំឈ្មោះកូនទាំងប្រាំរបស់គាត់ទេ? ហើយពេលនោះ តើកូននីមួយៗ មានអាយុប៉ុន្មានដែរបាទ?

**ឆ៖** បាទ កូនបងទី១ ឈ្មោះ ដាលីត។ ដាលីត កាលទៅនោះអាយុ១៤ឆ្នាំ ដាលីត។ ហើយ ដា ឡា នោះអាយុ១២ឆ្នាំ កូនទី២។ កូនទី៣ ឈ្មោះ ស្រីម៉ៅៗ អាយុប្រាំ៧ឆ្នាំ។ ហើយបើកូនទី៤នោះ អាយុ វាអាយុ៣ឆ្នាំៗ កូនទី៤។ កូនទី៥ ២ឆ្នាំ កូនតូចនេះតូច នៅកំពុងបៅ។

**សៈ** បាទ ឥឡូវចូលដល់អារឿងដែលលោកថា គេបានចាប់ឈ្មោះ ង៉ាង បានចាប់ខ្លួនឈ្មោះ ង៉ាង។ អ៊ីចឹងខ្ញុំចង់ដឹងថា តើឈ្មោះ ង៉ាង នេះត្រូវបានចាប់ខ្លួនមុនលោកស្រី សាន ដែលជាប្រពន្ធរបស់ ឡាច នី ឬមួយក៏ក្រោយពេលដែលគេចាប់ប្រពន្ធរបស់ ឡាច នី ហើយ?

**ឆ៖** បាទ ឡាច នី ប្រពន្ធ ឡាច នី គឺគេចាប់នៅៗឆ្នាំ៧៧ ប៉ុន្តែ វ៉ាន់ ង៉ាង ហ្នឹងគេចាប់នៅតាំងពី ឆ្នាំ៧៥មក កំពុង ចុងឆ្នាំ៧៥ ចុងឆ្នាំ ប្រហែលជាខែ១២ ឬមួយក៏ចូលៗៗខែ១២, ១១, ១២ហ្នឹង។ ហ្នឹង យកទៅមុនគេបំផុត វ៉ាន់ ង៉ាង ហ្នឹងតែម្ដង។ យកទៅកាប់ៗរពាក់ហ្នឹង។

**សៈ** បាទ ចុះឈ្មោះជុយ វិញ តើគេចាប់ខ្លួនពេលណាដែរបាទ?

[១៥:៣៣:៣៥]

**ឆ៖** បាទ ឈ្មោះ ជុយ ចាប់ឆ្នាំ នែ៎!ចាប់ខ្លួននៅឆ្នាំ៧៦។ រយៈពេលឃ្លាតគ្នាប្រហែលជាជិត មួយឆ្នាំ ធ្វើស្រែបានមួយវស្សា ឬបានមួយឆ្នាំ បានគេយក ជុយ ហ្នឹងទៅ។ ជុយ ទៅឲ្យទៅកាប់ឈើ នៅ ព្រៃកក្របៅដូចគ្នា ទៅពីផ្ទះទៅចម្ងាយ៣០, ថា៤០ – សាមសែសិបគីឡូទៅពីផ្ទះទៅ។

**ស៖** បាទ តើប្រពន្ធរបស់ឈ្មោះ ង៉ាង ហ្នឹងគាត់ឈ្មោះអីដែរបាទ?

**ឆ៖** បាទ សូមអត់ទោសប្រពន្ធហ្នឹង ខ្ញុំភ្លេចឈ្មោះហើយ ប្រពន្ធមិត្ត ង៉ាង នេះ។ ប៉ុន្តែបើប្រពន្ធ ជុយ ហ្នឹងឈ្មោះ ឌុក អឿន។ ប្រពន្ធមិត្ត ង៉ាង ខ្ញុំបាទភ្លេចឈ្មោះហើយ ខ្ញុំបាទ។ មិនចាំឈ្មោះ។

**ស៖** លោកបានរៀបរាប់ពីការជម្លៀសរបស់លោក ជម្លៀសខ្លួនលោកចេញពីភូមិកំណើតទៅដីខ្លាញ់។ អ៊ីចឹងខ្ញុំចង់ដឹងថាតើប៉ុន្មានខែក្រោយពីការចាប់ខ្លួនរបស់គ្រួសារ ប្រពន្ធ និងកូនរបស់ ឡាច នី ហើយ ទើបគេជម្លៀសលោកទៅដីខ្លាញ់ហ្នឹង?

**ឆ៖** បាទ ពេលដែលជម្លៀសខ្ញុំបាទទៅហ្នឹង គឺថាមុនៗ ឡាច នី ការ -- ក្រោយ ឡាច នី ការៗ ហើយបានខ្ញុំបាទ គេជម្លៀសទៅៗនៅដីខ្លាញ់ហ្នឹង។ បាទរយៈពេលប្រហែលជាប្រាំប្រាំមួយខែ បានគេឱ្យទៅ ការប្រពន្ធ ឡាច នី ហើយហ្នឹង។ ព្រោះប្រពន្ធ ឡាច នី គាត់មានផ្ទៃពោះ ប្រពន្ធនុំង មានផ្ទៃពោះប្រហែលបួនប្រាំខែ បានគេជម្លៀសទៅ ទៅដីខ្លាញ់នោះនៅអាងទុំលែង។

**ស៖** ឥឡូវខ្ញុំទុករឿងនេះបន្តិច ចាំខ្ញុំត្រឡប់មកសួរវិញបើមានពេល។ ហើយខ្ញុំចង់ដឹងថាតើពេលបន្ទាប់ពីគេចាប់ប្រពន្ធកូនគាត់ទៅហើយ តើស្ថានភាពរបស់ ឡាច នី យ៉ាងម៉េចដែរបាទ?

[១៥:៣៥:៤២]

**ឆ៖** បាទ ពេលដែលគេចាប់ប្រពន្ធកូនរបស់ ឡាច នី គឺថា ឡាច នី ចាប់ភ្លាមហ្នឹងគាត់ដួលសន្លប់នៅៗក្នុងស្រែ ក្នុងច្រូត កន្លែងស្រែច្រូតហ្នឹង។ អស់រយៈពេលប្រហែល១០ ឬ២០នាទីបានដឹងខ្លួនឡើង គាត់ដើរទៅលិចៗហ្នឹងអស់រយៈពេលព្រលប់ៗ បានគាត់អញ្ជើញមកផ្ទះវិញ។ ដល់អញ្ជើញមកផ្ទះវិញ បានគាត់ដូចថា វិលខួរក្បាលពីៗនុំងមក រយៈពេលមួយថ្ងៃហ្នឹង ក៏ៗវិលខួរក្បាលតែម្តង។ ដូច្នេះហើយក៏មិនអាចដឹង មិនអាចដឹងខ្លួន ថាខ្លួនហ្នឹងជាអ្នកជំហររឹងមាំ លែងដឹងជំហររឹងមាំ។ ដើរហៅតែប្រពន្ធគេ អូនអីចុះ កូនគេ កូនៗអីចេះ ដើរអីចុះ រយៈពេល៥ខែ បាន៥ខែបានៗគាត់រាងស្វាងៗទៅវិញ។ ស្វាងហើយ អស់រយៈពេលប្រហែលជាពីរបីខែក្រោយមក បានគេឱ្យយកប្រពន្ធ ដល់នោះក៏ឱ្យយកប្រពន្ធក្រោយ។

**ស៖** អ៊ីចឹងចាប់ពីពេលដែលគាត់ គេយកប្រពន្ធគាត់ទៅ រហូតដល់ពេលដែលគាត់រៀបការថ្មីហ្នឹង មានរយៈពេលប៉ុន្មានខែដែរបាទ?

**ឆ៖** ចាប់ពីគេយកប្រពន្ធទៅហ្នឹង ប្រហែលខ្ទង់ប្រាំពីរប្រាំបីខែដែរ បានគាត់ គេរៀបការឱ្យគាត់។

**សៈ** ខ្ញុំសូមអាននូវ រំឮកការចងចាំរបស់លោក នូវឯកសារមាន E3 លេខ E3/5630 ដែលជាចម្លើយរបស់លោកនៅចំពោះមុខអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ERN ជាភាសាខ្មែរមានលេខ 00895420, ERN ជាភាសាអង់គ្លេសមានលេខ 00678289, ERN ជាភាសាបារាំងមានលេខ 00891891។ ក្នុងហ្នឹងលោកបានឆ្លើយថា លោក ណាច -- លោក ណាច នី ហ្នឹង -- ឡាច នី ហ្នឹងគឺគាត់បានឡប់សតិអស់រយៈពេលមួយឆ្នាំនៅក្នុងឆ្នាំ១៩៧៨។ ហើយមុននេះលោកថា គាត់មានបញ្ហាឡប់សតិហ្នឹងតែបួនប្រាំខែទេ។ តើលោករកនឹកឡើងវិញមើល ថាតើគាត់ ចម្លើយរបស់លោកទាំងពីរហ្នឹងតើមួយណាដែលសមរម្យជាង?

[១៥:៣៧:១៩]

**ឆៈ** ខ្ញុំបាទសូមជម្រាប។ រយៈពេលដែលគាត់ឡប់សតិ៥ខែហ្នឹង គឺអត់ដឹងៗសោះ អត់ដឹងទេ។ ពេលកន្លងមកដែលៗគាត់ ខ្លួនបន្តិចៗឡើងមក ចាប់ពីបួនប្រាំខែហ្នឹង ចេះដឹងខ្លួនបន្តិចៗៗមកទាល់ការប្រពន្ធហ្នឹង។ នេះខ្ញុំសូមជម្រាប។ បើតាមនិយាយ ថាឡប់សតិមិនដឹងខ្លួន៥ខែ ហើយដែលដឹងខ្លួនហើយដល់ដឹងខ្លួន ដឹងថា វាៗនៅតិចតួច គ្រាន់តែដឹងខ្លួនវង្វេងខ្លះៗអ៊ីចឹងទៅ រយៈពេលពីរបីខែទៀត បានបួនប្រាំខែបានៗជាៗ ជាច្បាស់តែម្តង ហើយបានគាត់ទៅយកប្រពន្ធនុ៎ង អង្គការដណ្តឹងប្រពន្ធឲ្យ។

**លោក លីវ សុវណ្ណៈ**

បាទ សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណ ខ្ញុំបាទអស់សំណួរ។

**ប្រធានអង្គជំនុំៈ**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេៈ**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេៈ**

**សៈ** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនចំពោះលោក។ សំណួរទី១ គឺពាក់ព័ន្ធទៅនឹងការសម្ភាសរបស់លោក ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំចង់ដឹងថា លោកធ្លាប់បានផ្តល់បទសម្ភាសន៍ប៉ុន្មានដង ពាក់ព័ន្ធទៅនឹងបទពិសោធន៍

របស់លោក និងអ្វីដែលបានកើតឡើងចំពោះបងប្រុសរបស់លោក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

[១៥:៣៩:០៥]

**លោក ឡាច គ្រី៖**

**ឆ៖** បាទ ខ្ញុំបាទបានចូលរួមក្នុងការប្រជុំនុំងបានបីដង ហើយក្នុងការរួមរស់ជាមួយរបបប្រជាធិបតេយ្យនេះ ជាមួយ ឡាច នី ហ្នឹងគឺថាបានជួបជាមួយគ្នា ជិតស្និទ្ធជាមួយគ្នាជារាល់ថ្ងៃអាហ្នឹង។

**ស៖** ខ្ញុំដូចជាមិនសូវយល់ចម្លើយរបស់លោក។ លោកថា លោកបានផ្តល់បទសម្ភាសន៍បីដងពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាមួយមនុស្សបីនាក់ផ្សេងគ្នា។ លោកអាចបញ្ជាក់អំពីចំណុចនេះ ឲ្យបានច្បាស់បានទេ?

**ឆ៖** បាទ ទី១ នៅខាងសាលាច្បាប់ហ្នឹងម្តង ហើយនៅជិតផ្ទះខ្ញុំបាទម្តង។ ហើយម្តងទៀត ខ្ញុំបាទអត់ស្គាល់ៗឈ្មោះទេ ប៉ុន្តែគ្រាន់តែដឹងថា នៅកន្លែងខាងឯកសារហ្នឹង។ ខ្ញុំបាទដឹងតែប៉ុណ្ណឹងទេ បីដងហ្នឹង។

**ស៖** ខ្ញុំនឹងព្យាយាមរំឭកឲ្យលោកចងចាំឡើងវិញ។ តើលោកធ្លាប់ផ្តល់បទសម្ភាសន៍ជូនមជ្ឈមណ្ឌលឯកសារកម្ពុជាទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់។

**ស៖** ពេលហ្នឹងជា គឺជាពេលលើកដំបូងដែលលោកបានផ្តល់បទសម្ភាសន៍ពាក់ព័ន្ធនឹងហេតុការណ៍នៅរបបកម្ពុជាប្រជាធិបតេយ្យមែនទេ?

**ឆ៖** បាទ មែន។ សម្ភាសដំបូងបំផុតហើយនុំង ឯកសារ*(ឮមិនច្បាស់)*។

**ស៖** លោកចាំថា ការសម្ភាសហ្នឹងនៅឆ្នាំណាទេ?

**ឆ៖** បាទ សូមអត់ទោស ខ្ញុំអត់ចាំឆ្នាំទេ អត់ចាំឆ្នាំ ភ្លេចឆ្នាំហើយ។

**ស៖** ភាគី គឺឯកសារនេះមានលេខ E3/5640 គឺនៅទំព័រទី១ គឺថានៅក្នុងនោះមានការបញ្ជាក់ថា នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០០។ តើលោកនឹកឃើញទេ អំពីកាលបរិច្ឆេទនេះ?

**ឆ៖** បាទ ខ្ញុំបាទនឹកមិនឃើញទេ ព្រោះយូរណាស់ហើយ នឹកអត់ឃើញ។

**លោក គង់ សំអុន៖**

លោកប្រធាន សុំអនុញ្ញាត ដោយសារនៅក្នុងជាភាសាខ្មែរ គឺថ្ងៃទី១១ ខែមីនា ឆ្នាំ២០០០។ ខុសកាលបរិច្ឆេទគ្នា។

[១៥:៤២:៥០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី មិនបាច់គិតពីខែទេឥឡូវនេះ។ អ៊ីចឹងលោកចាំថា លោកបានផ្ដល់បទសម្ភាសន៍នៅឆ្នាំ២០០០ទេ?

**លោក ឡាច គ្រី៖**

**ឆ៖** អ៊ីចឹងឆ្នាំ២០០០នុ៎ង ដូចថាក្រុមការងារហ្នឹងចុះទៅជាច្រើនលើកច្រើនសា ប៉ុន្តែសម្ភាសខ្លះមិនសម្ភាសខ្លះអ៊ីចឹងដែរ វាច្រើនដែរ។ ប៉ុន្តែដែលសម្ភាសផ្ទាល់ៗនុ៎ងគឺបី ៗកន្លែង។ កន្លែងច្បាប់ ខាងគាំទ្រច្បាប់ មួយកន្លែង ហើយមួយកន្លែងទៀតខាងឯកសារហ្នឹង ហើយម្ដងទៀតគឺនៅតាមផ្ទះខ្ញុំបាទ។

**ស៖** ឥឡូវនេះខ្ញុំសូមសួរលោកអំពីបទសម្ភាសន៍លើកទី២។ លោកចាំថា លោកបានផ្ដល់បទសម្ភាសន៍លើកទី២នេះទៅអ្នកណាទេ?

**ឆ៖** ខ្ញុំបាទ អត់ៗស្គាល់ៗ មិនស្គាល់ឈ្មោះផង។

**ស៖** លោកដឹងថាជាបុគ្គលិកនៃតុលាការខ្មែរក្រហម ដែលសម្ភាសលោកក្នុងក្របខ័ណ្ឌនៃកិច្ចស៊ើបសួររបស់តុលាការទេ?

[១៥:៤៤:១៥]

**ឆ៖** បាទ គាត់ទៅសម្ភាសហ្នឹង គឺថានៅធ្វើការនៅក្នុង នឹងតុលាការហ្នឹង ប៉ុន្តែដឹងលោកណាខ្ញុំបាទអត់ស្គាល់។

**ស៖** គឺយើងមានឯកសារដែលមានលេខ E3/9340 ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨។ ខ្ញុំនិយាយអ៊ីចឹងលោកមាននឹកឃើញឡើងវិញទេ?

**ឆ៖** បាទ វាយូរទៅហើយ ខ្ញុំបាទនឹកមិនឃើញទេ វាភ្លេចភ្លាំងទៅហើយ។ វាយូរដែរហើយនឹកមិនឃើញទេ។

**ស៖** ហើយបទសម្ភាសន៍លើកទី៣ ដែលលោកថា លោកមិនចាំថា លោកធ្វើនៅកន្លែងណា ប៉ុន្តែខ្ញុំចង់សួរលោកថា ពេលលោក ពេលហ្នឹងលោកផ្ដល់បទសម្ភាសន៍ជូនអ្នកណាដែរលើកទី៣ហ្នឹង លើកចុងក្រោយ?

**ឆ៖** បាទ លើកចុងក្រោយហ្នឹង គឺសម្ភាសនៅផ្ទះខ្ញុំបាទហ្នឹង។ ឯផ្ទះហ្នឹងគឺថាមិនស្គាល់ឈ្មោះអ្នកទៅសម្ភាសហ្នឹងទេ ប៉ុន្តែខ្ញុំដឹងថាជាក្រុមខាងតុលាការហ្នឹង ដែលទៅហ្នឹង។

**ស៖** លោកដឹងទេថា អ្នកដែលសម្ភាសលោកហ្នឹង គឺជាមេធាវីដែលចាំជួយលោកក្នុងនីតិវិធីដែលដាក់ពាក្យសុំតាំងខ្លួនហ្នឹង លោកចាំអ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំបាទមិនចាំទេ ព្រោះវាអស់ស្គាល់ អត់ស្គាល់ដូចថាគាត់ទៅសម្ភាសខ្ញុំ ខ្ញុំអត់ស្គាល់គាត់។ បើអត់ស្គាល់គាត់ទៅហើយ គ្រាន់ថា ដឹងតែសម្ភាស គាត់សួរ ចេះតែនិយាយទៅ ប៉ុន្តែត្រង់ថា ឲ្យគាត់ឋានៈជាអ្វី ខ្ញុំបាទអត់ស្គាល់។--

[១៥:៤៦:៤៣]

**ស៖** ចំពោះភាគីទាំងអស់ គឺខ្ញុំសំដៅទៅលើឯកសារ E3/5630។ នៅក្នុងសំណុំរឿង លោកដើមបណ្តឹងរដ្ឋប្បវេណី យើងមានព័ត៌មានបន្ថែមដែលចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ តាមរយៈឯកសារនេះ គឺយើងឃើញថា លោកបានផ្តល់បទសម្ភាសន៍ជូនមេធាវីដែលបានជួយលោកក្នុងនីតិវិធីនេះ គឺមានមេធាវី លីម៉ា ង្វៀន និងម្នាក់ទៀតឈ្មោះ ប៊ុត ម៉ៅ ខ្ញុំមិនដឹងថាជាមេធាវី ឬក៏អត់ទេ។ លោកចាំទេ ពេលហ្នឹង លោកបានផ្តល់បទសម្ភាសន៍ជូនមេធាវី លីម៉ា ង្វៀន និងលោក ប៊ុត ម៉ៅ?

**ឆ៖** បាទ ខ្ញុំបាទចាំ។ ចាំៗលោក លោកស្រី ខ្ញុំបាទចាំ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងសួរសំណួរលោកពាក់ព័ន្ធទៅនឹងចម្លើយផ្សេងៗរបស់លោក នៅក្នុងឯកសារទាំងបីនេះ។ ប៉ុន្តែឥឡូវនេះខ្ញុំចង់ត្រឡប់មកនិយាយអំពីអ្វីដែលលោកបានឆ្លើយជូនមេធាវីលោក នួន ជា។ តាមរយៈចម្លើយរបស់លោក ខ្ញុំយល់ថា ក្នុងចំណោមមនុស្សទាំងបីនាក់ដែលជាជនជាតិវៀត-ណាម ដែលត្រូវបានចាប់ខ្លួននៅក្នុងភូមិរបស់លោក ខ្ញុំយល់ថា បងថ្លៃរបស់លោកហ្នឹងត្រូវបានគេចាប់ខ្លួន គិតចុងក្រោយគេបង្អស់មែនទេ?--

**ឆ៖** បាទ មែន។

**ស៖** ពីព្រោះថាគាត់ត្រូវបានគេចាប់ខ្លួននៅឆ្នាំ៧៧ សូមទោស ខ្ញុំមិនទាន់សួរចប់ទេ សូមលោកចាំសិន។

**ឆ៖** បាទ។

[១៥:៤៨:៥០]

**ស៖** បងថ្លៃរបស់លោកហ្នឹង គេចាប់នៅក្នុងឆ្នាំ៧៧ ហើយពីរនាក់ទៀតហ្នឹង គេចាប់ខ្លួននៅឆ្នាំ៧៥, ៧៦។ ដូច្នេះបងថ្លៃរបស់លោកហ្នឹង ត្រូវបានគេចាប់ខ្លួនក្រោយគេបង្អស់មែនទេ ក្នុងចំណោមអ្នកទាំងបីហ្នឹង?

**ឆ៖** បាទ អ្នកទាំងបីហ្នឹង គឺបងខ្ញុំបាទហ្នឹងហើយ អ្នកចាប់ក្រោយគេបំផុត។

**ស៖** លោកប្រាកដទេថា ឈ្មោះ ង៉ាង ដែលលោកឆ្លើយថា ត្រូវបានគេចាប់ខ្លួននោះ ពិតជាត្រូវបានគេចាប់នៅចុងឆ្នាំ៧៥ លោកប្រាកដទេ?

**ឆ៖** បាទ កាលហ្នឹងខ្ញុំបាទកំពុងធ្វើស្រែៗ ទៅ ប្រធានភូមិមកហៅទៅ។ ដល់ប្រធានភូមិមកហៅទៅ ៗថាឲ្យនែឈ្មោះ វ៉ាន់ ង៉ាង ហ្នឹងទៅកាប់រពាត់យកមកធ្វើបង្គី។ ហ្នឹងក៏បាន ង៉ាង ហ្នឹងរៀបចំខោអាវហ្នឹងទៅ ៗតែម្តងទៅ។

**ស៖** ចំណុចមួយទៀតដែលខ្ញុំចង់ពិភាក្សាជាមួយលោក គឺខ្ញុំចង់សួរលោក លោកថា បងថ្លៃរបស់លោកឈ្មោះ សាន នេះនិយាយភាសាវៀតណាម។ ហើយនៅពេលដែលគាត់លក់ដូរហ្នឹង គឺគាត់និយាយវៀតណាម ជាមួយអ្នកមកទិញដែលជាជនជាតិវៀតណាមដូចដដែល។ លោកច្បាស់ទេ ត្រង់ចំណុចនេះ ថាគាត់ពិតជានិយាយវៀតណាម?

**ឆ៖** ខ្ញុំបាទច្បាស់។ ពេល បានដែលខ្ញុំបាទច្បាស់ហ្នឹង គឺថាប្តីរបស់គាត់ ព្រោះ ឡាច នី ក៏ចេះវៀតណាមដែរ ចេះភាសាវៀតណាមដែរ។ ពេលណាល្ងាចទៅផ្ទះហ្នឹង ជួនកាលគាត់និយាយលេងប្តីប្រពន្ធគាត់ វៀតណាម និយាយវៀតណាមលេង។ ជួនកាលអ្នកដទៃទៅ និយាយជាមួយអ្នកដទៃអ៊ីចឹងវៀតណាម។ ខ្ញុំបាទដឹងច្បាស់ថាគាត់ហ្នឹង ប៉ុន្តែនិយាយភាសាខ្មែរ វាងវៃឡាំបន្តិច គាត់ហ្នឹង។

[១៥:៥១:៣១]

**ស៖** ខ្ញុំសួរសំណួរនេះ ពីព្រោះថានៅក្នុងបទសម្ភាសន៍ដែលលោកបានផ្តល់ជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០០៨ គឺឯកសារ E3/9340 ERN ជាភាសាបារាំង 00325249, ERN ជាភាសាអង់គ្លេស 00233282 និង ERN ជាភាសាខ្មែរ 00225206។ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ឡាច នី បានរៀននៅភ្នំពេញ គាត់បានរៀបការតាំងពីមុនរបបខ្មែរក្រហម។ ប្រពន្ធរបស់គាត់ជាកូនកាត់វៀតណាម ម្តាយវៀតណាម ឪពុកខ្មែរ។ ប្រពន្ធរបស់គាត់អត់ចេះនិយាយភាសាវៀតណាមទេ ហើយនិយាយខ្មែរច្បាស់។ គាត់ឈ្មោះសាន។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់សួរលោក អ្វីដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតកាលពីឆ្នាំ ២០០៨នោះ លោកថា សាន អត់ចេះនិយាយភាសាវៀតណាមទេ។ ឥឡូវលោកថា គាត់និយាយភាសាវៀតណាម សូមលោកបញ្ជាក់។

**ឆ៖** ខ្ញុំសូមជម្រាប ឈ្មោះ សាន ហ្នឹងគឺថាក្រែងអ្នក គាត់ខាងកត់ហ្នឹង គាត់ថាមិនច្បាស់លាស់

ម៉េចមិនដឹងទេ ខ្ញុំបាទអត់ដឹងទេ។ ប៉ុន្តែឈ្មោះ សាន ហ្នឹងគឺសម្ភាសមួយណា ក៏ខ្ញុំបាទនិយាយតែរឿងវៀតណាមដែរ។ គាត់វៀតណាម ប៉ុន្តែនិយាយភាសាខ្មែររាងប៉ៃឡាំ។ តែឯកសារក្រែងលោ លោកខាងឯកសារហ្នឹង លោកភ័ន្តច្រឡំយ៉ាងម៉េចៗ ខ្ញុំបាទអត់ដឹងដែរ។ ប៉ុន្តែខ្ញុំបាទស្គាល់ច្បាស់ហើយយ៉ាងពីព្រោះបងថ្លៃឯងបង្កើត មិនស្គាល់ច្បាស់ថាគាត់វៀតណាម ឬខ្មែរគាត់ អាចស្គាល់ច្បាស់ណាស់។ ហើយសម្ភាសទៅ ថាក្រែងលោខាងបងៗខាងឯកសារហ្នឹងគាត់ច្រឡំសរសេរ ឬភ័ន្តច្រឡំយ៉ាងម៉េចៗ ខ្ញុំបាទអត់ដឹងដែរ។

[១៥:៥៤:១២]

**ស៖** លោកក៏បានឆ្លើយថា លោកចាំអំពីបទសម្ភាសន៍ដែលលោកបានផ្ដល់ជូនមេធាវីដែលបានជួយលោកក្នុងនីតិវិធីតុលាការនេះ។ ខ្ញុំសូមដកស្រង់នូវឃ្លាមួយនៅក្នុងឯកសារនេះ គឺជាចម្លើយរបស់លោក។ ជាដំបូងនៅពេលដែលលោកឆ្លើយទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី លោកបានឆ្លើយថា លោកមិនចាំទេ ថាលោកបានចូលរួមប្រជុំ ឬក៏អត់ ដែលពេលប្រជុំនោះគេប្រកាសអំពីការនាំបងថ្លៃរបស់លោកទៅអប់រំរៀនសូត្រ។ ដូច្នេះខ្ញុំចង់សួរបញ្ជាក់ឲ្យបានច្បាស់ ថាលោកពិតជាមិនដែលបានដឹង ឬក៏មិនធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំដែលគេប្រាប់អំពីការនាំបងថ្លៃរបស់លោកទៅរៀនសូត្រទេ មែនទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** នៅក្នុងចម្លើយរបស់លោកគឺឯកសារ E3/5630, ERN ជាភាសាបារាំង 00891890, ERN ជាភាសាខ្មែរគឺ 00895419 និង ERN ជាភាសាអង់គ្លេស 00678289។ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ក្នុងឆ្នាំ១៩៧៧ នៅមុនពេលប្រពន្ធ និងកូនៗរបស់ ឡាច នី ត្រូវគេចាប់ខ្លួន គេមានកិច្ចប្រជុំប្រចាំភូមិដែល ឆែម បានបញ្ជាឲ្យ ង៉ុយ នាំយកកូនៗ និងប្រពន្ធរបស់ ឡាច នី ទៅកសាង។ អ្នកភូមិទាំងអស់ រួមទាំងខ្លួនខ្ញុំមានវត្តមាននៅក្នុងកិច្ចប្រជុំនេះដែរ។ ខ្ញុំមិនចាំអំពីកាលបរិច្ឆេទនៃកិច្ចប្រជុំនេះទេ។ នៅក្នុងកិច្ចប្រជុំដដែលនេះ មានគ្រួសារចំនួនបីគ្រួសារត្រូវបានគេបញ្ជាឲ្យយកទៅកសាងផងដែរ គឺគ្រួសាររបស់ ឡាច នី ជាគ្រួសារមួយនៅក្នុងភូមិពោធិ៍ចិន្តាំ ចំនួនប្រាំពីរនាក់ ហើយនិងគ្រួសារពីរទៀតនៅភូមិស្វាយអន្ទរ។" សូមបញ្ចប់ការដកស្រង់។ សំណួរទី១ពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំចង់សួរលោកថាតើលោកចាំថាលោកបានឆ្លើយបែបនេះជូនមេធាវីរបស់លោកទេ?

[១៥:៥៧:៣២]

**ឆ៖** បាទ ខ្ញុំបាទរឿងជួបគ្នាអីហ្នឹង ខ្ញុំបាទអត់ដឹងទេៗ អត់ដឹងសោះ។ ពេលប្រជុំហ្នឹង អត់ដឹង។

**សៈ** អ៊ីចឹងក្រោយពេលដែលបងថ្លៃរបស់លោកត្រូវបានគេនាំយកទៅនោះ លោកចាំថាមានការប្រជុំទេ ក្រោយពីគេយកគាត់ចេញទៅនោះ?

**ឆៈ** ពេលដែលគេយកគាត់ទៅហ្នឹង វារដ្ឋអំណាចភូមិមានការប្រជុំ ប្រជុំភូមិៗ ប្រជុំអ៊ីចេះទេ ប្រជុំមិនមែនយក និយាយអំពីការយកទៅទេ ប្រជុំអំពីការបង្កបង្កើនផល ប្រឹងប្រែងបង្កបង្កើនផល អត់មានប្រជុំយកបញ្ហាដែលយកប្រពន្ធ ឡាច នី ទៅទេ អត់មាននិយាយរឿងហ្នឹងផង។ បើប្រជុំពីរឿងការងារខាងកសិកម្ម អាហ្នឹងមាននិយាយមែន មានប្រជុំ ប៉ុន្តែបើត្រង់ប្រជុំសម្ងាត់ឯណាផ្សេងទៀត ខ្ញុំបាទអត់ដឹង។

**សៈ** សូមអភ័យទោសដែលខ្ញុំជជីកសួរបន្តទៅទៀត។ លោកច្បាស់ទេ ថាអត់មានការប្រជុំអំពីការនាំខ្លួនបងថ្លៃរបស់លោកទៅហ្នឹង?

**ឆៈ** បាទ ខ្ញុំច្បាស់ ព្រោះខ្ញុំបាទអត់ចូលរួម ក្រែងតែខ្ញុំបាទមិនបាននៅម៉េចមិនដឹងអីមិនដឹងទេ ប៉ុន្តែបើថាខ្ញុំបាទអត់បានចូលរួមប្រជុំទេ។

[១៥:៥៩:៣៦]

**សៈ** លោកបាននិយាយថាលោកមិនបានចូលរួមប្រជុំ។ ទោះបីជាលោកមិនបានចូលរួមក៏ដោយ លោកមានបានស្តាប់ឮថាមានការប្រជុំ ដែលគេនិយាយគ្នាអំពីការនាំបងថ្លៃរបស់លោកទៅអប់រំទេ?

**ឆៈ** បាទ ពេលដែលមុនយកបងថ្លៃខ្ញុំទៅហ្នឹង គេអត់មានប្រជុំទេ គឺខ្ញុំអត់ដឹងៗ។ ដល់ក្រោយមកបានប្រជុំ ដូចខ្ញុំជម្រាបខាងដើម ទៅប្រជុំ និយាយពីការបង្កបង្កើតផល ខាងដីអីទេ អត់មាននិយាយពីរឿងប្រពន្ធ ឡាច នី ហ្នឹងយ៉ាងម៉េចៗ អត់មានដែលឮនិយាយទេ។ ក្រោយមកមានប្រជុំជាបន្តបន្ទាប់ មានប្រជុំមែន។

**សៈ** សំណួរចុងក្រោយ លោកប្រធាន ពីព្រោះថាដល់ម៉ោងសម្រាកហើយ។ នៅក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោកៗបានថា លោកចាំថាបានសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារE3/5640, ERNជាភាសាបារាំង00657820, ERNជាភាសាអង់គ្លេសគឺ00645404 និង ERN ជាភាសាខ្មែរ 00034406។ ពេលនោះគេសួរលោកថា៖ “ពេលនោះ ពេលដែលគេនាំបងថ្លៃរបស់លោកទៅនោះ តើអង្គការ ឬក៏ថ្នាក់ដឹកនាំណា បាននិយាយអំពីការនាំខ្លួនគ្រួសារហ្នឹងក្នុងប្រជុំទេ? លោកក៏បានឆ្លើយថា៖ គេបានប្រាប់យើងនៅក្នុងពេលប្រជុំ គេប្រជុំយើងទាំងអស់គ្នា ហើយគេអប់រំមនោគមន៍វិជ្ជា។ គេប្រាប់ថា មិនមែននាំយកទៅសម្លាប់ទេ គេយកទៅឲ្យរៀនសូត្រ យកទៅឲ្យកសាង

ខ្លួន។" សូមបញ្ចប់ការដកស្រង់។ តើលោកនៅរក្សាចម្លើយរបស់លោកដដែលទេថា មិនមានការប្រជុំអីទេ ក្រោយពេលគេនាំបងថ្លៃរបស់លោកចេញទៅនោះ?

**ឆ៖** បាទ។ អត់។ដឹងផង អត់ដឹង ខ្ញុំបាទអត់ចូលរួមផង។

[១៦:០២:១៧]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមផ្អាកត្រឹមនេះសិន ពីព្រោះថាដល់ម៉ោងហើយ។ សូមបន្តនៅថ្ងៃស្អែកទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកថ្ងៃព្រហស្បតិ៍ ទី២១ ខែមករា ឆ្នាំ២០១៦ ដែលចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការជាអសាធារណៈ បន្តស្ដាប់សក្ខីកម្មសាក្សី 2-TCW-938 នៅពេលព្រឹក និងបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី ពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តព្រៃវែង ជាមួយនឹង អ.វ.ត.ក។ ហើយសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។ ហើយអង្គជំនុំជម្រះអរគុណ លោក ឡាច គ្រី។ ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោក នៅក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅទីកន្លែងដែលគាត់កំពុង -- ដែលលោកកំពុងតែផ្ដល់សក្ខីកម្មនេះ នៅវេលារសៀលថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងមួយ និងសាមសិបនាទី។ ឥឡូវនេះលោកអាចសម្រាកបានហើយ។

[១៦:០៣:៣២]

**លោក ឡាច គ្រី៖**

បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអរគុណលោក ញ៉ែម សំណាង បុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលបានសម្របសម្រួលផ្ដល់ ការផ្ដល់សក្ខីកម្ម ឡាច នី តាមរយៈប្រព័ន្ធសោតទស្សន៍បានល្អ។ ហើយលោក

អាចសម្រាកបាន។ អង្គជំនុំជម្រះសូមឲ្យលោកជួយសម្របសម្រួលលើការងារនេះ នៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងមួយកន្លះ។

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូប ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ជាកំណត់។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*

ឯកសារដើម